# ករណីសិក្សាក្រុមប្រឹក្សាឃុំ

## ការចងក្រងឯកសារលើការអនុវត្តប្លែកៗ




និពន្ធដោយៈ លោក អ៊ឹម សុខធី

ជំនួយការស្រាវជ្រាវៈ លោក ឈឹម សុភាគ


គំរោងគាំទ្រ ក្រុមប្រឹក្សាឃុំ សង្កាត់

COMMUNE COUNCIL SUPPORT PROJECT


ចេញផ្សាយដោយ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់

ឧបត្ថម្ភដោយ អង្គការទិហារកូតូលីកការណាជាសម្រាប់ការអភិវឌ្ឍ និង សន្តិភាព (CCODP)

ខែធ្នូ ឆ្នាំ ២០០៧ ភ្នំពេញ កម្ពុជា

# សេចក្តីថ្លែងអំណរគុណ

បេសកកម្មមួយអាចសម្រេចទៅបានដោយមានកិច្ចសហការ ការចូលរួម និង ការជួយគាំទ្រពីសហការី និងតួអង្គពាក់ព័ន្ធទាំងអស់។ ដូចគ្នាដែរ ការចងក្រងករណីសិក្សាអំពីក្រុមប្រឹក្សាឃុំនេះ អាចសម្រេចទៅបាន ដោយជោគជ័យដ៏ត្រចះត្រចង់នេះ ក៏ដោយសារមានការជ្រោមជ្រែង និង កិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើន ពីៈ

១. ក្រុមប្រឹក្សាឃុំទាំងបួន នៅក្នុងឃុំតាជេស និង ឃុំរលាប្អៀរ ក្នុងខេត្តកំពង់ឆ្នាំង ឃុំខ្នាពោធិ៍ និង ឃុំល្វា ក្នុងខេត្តសៀមរាប ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការរៀបចំការប្រជុំនៅសាលាឃុំ ការផ្តល់សម្ភាស និងសម្របសម្រួលដទៃទៀត ដូចជា ការចុះទៅមើលទីតាំងគម្រោង ការផ្តល់ឯកសារបន្ថែម ។ល។

២. អង្គភាពរដ្ឋបាលមូលដ្ឋានខេត្តកំពង់ឆ្នាំង និង ខេត្តសៀមរាប ដែលបានផ្តល់ឯកសារ និង មតិយោបល់ ល្អៗទាក់ទងនឹងស្ថានភាពការអនុវត្តគម្រោងសេវាកម្ម ការងាររបស់ក្រុមប្រឹក្សាឃុំ ការជ្រើសរើសឃុំគោលដៅសម្រាប់ការចងក្រងករណីសិក្សា ការជួយសម្រួលរៀបចំការចុះទៅសម្ភាសនៅសាលាឃុំ ការផ្តល់មតិត្រឡប់អំពីខ្លឹមសារករណីសិក្សា និង ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយករណីសិក្សា។

៣. ទន្ទឹមគ្នានេះដែរ អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះកិច្ចសហការយ៉ាងល្អ និងយ៉ាងជិតស្និតរបស់អង្គការដៃគូរពីរ គឺសមាគមភ្នំនាងកង្រី នៅខេត្តកំពង់ឆ្នាំង និង សមាគមមិត្ត អ្នកត្រួសត្រាយនៅខេត្តសៀមរាប ដែលបានជួយសម្របសម្រួលធ្វើឱ្យការចងក្រងករណីសិក្សានេះ ទទួលបានលទ្ធផលជាផ្លែផ្កា។ សមាគមទាំងពីរបានបំពេញតួនាទីសម្របសម្រួលដូចគ្នានឹងអ្វីដែល អង្គភាពរដ្ឋបាលមូលដ្ឋានក្នុងខេត្តទាំងពីរបានជួយអ្នកនិពន្ធផងដែរ។

៤. អ្នកសម្របសម្រួលស្រុកប្រចាំឃុំតាជេស ឃុំរលាប្អៀរ ឃុំខ្នាពោធិ៍ និង ឃុំល្វា ដែលបានជួយរៀបចំ ការជួបជុំដ៏សំខាន់ និង ចាំបាច់នៅសាលាឃុំ សម្រាប់ការសម្ភាសន៏ជាមួយប្រធានក្រុមប្រឹក្សា ជំទប់ សមាជិកក្រុមប្រឹក្សា សមាជិកគណៈកម្មាធិការកសាងផែនការ និង ថវិកា ថ្នាក់ដឹកនាំភូមិ និង ប្រជាពលរដ្ឋ។ អ្វីដែលសំខាន់ជាងនេះទៀតគឺពេលវេលាដ៏មានតម្លៃរបស់ពួកគេ ដែលបានផ្តល់ ព័ត៌មាន និង គំនិតល្អៗ ដល់អ្នកនិពន្ធ ពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ។

៥. គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានជួយចាត់ចែង និង សម្របសម្រួលដំណើរការទាំងស្រុង នូវកិច្ចការនិពន្ធករណីសិក្សាអំពីក្រុមប្រឹក្សាឃុំនេះ ជាពិសេសចំពោះ លោក **ម្ជូរ៉ាវី អាប់ដេឌីយ៉ៀ** និង លោក **ឈឹម សុភាគ** ។

# អារម្ភកថា

ក្រោយការបង្កើតរដ្ឋាភិបាលមូលដ្ឋាន( ក្រុមប្រឹក្សាឃុំ សង្កាត់) ជ្រើសរើសតាមលទ្ធិប្រជាធិបតេយ្យលើកដំបូងក្នុងឆ្នាំ ២០០២ រហូតមកដល់បច្ចុប្បន្ននេះ មានគំនិតផ្តួចផ្តើមជាច្រើនដោយក្រុមប្រឹក្សាឃុំ សង្កាត់ខ្លួនឯង និង ក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ។ ក្នុងរយៈពេលនេះ បានប្រមូលផ្តុំ ដោយបទពិសោធ និងមេរៀនពិសោធន៍វិជ្ជមានមួយចំនួនធំដែលក្រុមប្រឹក្សាឃុំ សង្កាត់និងអង្គការសង្គមស៊ីវិលទូទាំងប្រទេសបានបង្កើត ដែលជាផលប្រយោជន៍សំរាប់អ្នកដ៏ទៃទៀតផងដែរ ។ បទពិសោធន៍ទាំងនេះជាធាតុ ដ៏មានតម្លៃ ក្នុងការរៀបចំនិងធ្វើឱ្យប្រសើរឡើងវិញចំពោះដំណើរការកែទម្រង់អភិបាលកិច្ចមូលដ្ឋាន ។

ទោះជាយ៉ាងណា ក្រៅពីការខិតខំប្រឹងប្រែងរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ និងការចូលរួមដ៏ស្វិតស្វាញពីអ្នកពាក់ព័ន្ធផ្សេងទៀត មានគំនិតផ្តួចផ្តើមតិចតួចក្នុងការចងក្រងការអនុវត្តល្អរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គការសង្គមស៊ីវិលក្នុងអភិបាលកិច្ចមូលដ្ឋាន ។ ដោយយល់ដឹងពីតំរូវការក្នុងការរក្សាទុក បទពិសោធន៍សម្បូរបែប តែលំបាករកទាំងនេះ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំ ២០០៥ បានចងក្រង ករណីសិក្សាក្រុមប្រឹក្សាឃុំចំនួនបួន ដែលបានធ្វើការបង្ហាញនិងពិភាក្សាក្នុងសិកាសាលាផ្សព្វផ្សាយថ្នាក់ជាតិ ។ គំរោងចងក្រងករណីសិក្សានេះបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍ សង្គមស៊ីវិល ។ ដោយទទួលបានជោគជ័យ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់សំរេចចិត្តបន្តចងក្រងករណីសិក្សាពី ការអនុវត្តល្អជាមធ្យមចំនួនបួនករណីជារៀងរាល់ឆ្នាំ ដើម្បីលើកទឹកចិត្តឱ្យមានការពិភាក្សាការអនុវត្តអភិបាលកិច្ចមូលដ្ឋានក្នុងប្រទេសកម្ពុជា និងលើកស្ទួយការអនុវត្តបន្តតាមរយៈកម្មវិធីផ្សព្វផ្សាយទូលំទូលាយ ។

ដូចនេះក្នុងឆ្នាំ ២០០៧ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ បានចងក្រងករណីសិក្សាចំនួនបួនលើវិស័យ សំខាន់ៗក្នុងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺពីរក្នុងខេត្តសៀមរាបនិងពីរទៀតក្នុងខេត្តកំពង់ឆ្នាំងពី ផលប្រយោជន៍នៃការអនុវត្តគំរោងមិនមែនហេដ្ឋារចនាសម្ព័ន្ធ ឃុំគំរូ និងភាពជាអ្នកដឹកនាំក្រុមប្រឹក្សាឃុំ ។ លោក **អ៊ុំ សុខធី** អ្នកឯកទេសវិមជ្ឈការ កំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន ត្រូវអញ្ជើញឱ្យធ្វើការប្រមូលព័ត៌មាននិង សសេររបាយការណ៍ លោក **ឈឹម សុភាគ** មន្ត្រីព័ត៌មាននិងផ្សព្វផ្សាយគំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់បានជួយ ជ្រោមជ្រែងក្នុងរយៈពេលប្រមូលព័ត៌មានពីករណីសិក្សានេះ ។

ករណីសិក្សានេះត្រូវបានបង្ហាញ និងពិភាក្សាក្នុងសិក្ខាសាលាថ្នាក់ខេត្តដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ សំខាន់ៗក្នុងវិមជ្ឈការនិងវិសហមជ្ឈការ ក៏ដូចជាអ្នករៀបចំនិងអនុវត្តគោលនយោបាយពីខេត្តផ្សេងៗ និងក្រុង ភ្នំពេញផងដែរ ។ ឯកសារក្នុងដៃលោកអ្នកនេះត្រូវបានបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេសដើម្បីផ្សព្វផ្សាយជា ផលប្រយោជន៍សហគមន៍ពាក់ព័ន្ធ ។

ខ្ញុំសូមកោតសរសើរនិងថ្លែងអំណរគុណលោក **អ៊ឹម សុខធី** និង លោក **ឈឹម សុភាគ** ចំពោះការផលិតករណីសិក្សានេះប្រកបដោយជោគជ័យ ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរអង្គការវិហារកូតូលីកកាណាដា សម្រាប់ការអភិវឌ្ឍ និង សន្តិភាព CCODP ចំពោះការគាំទ្រនូវធនធានដ៏មានតម្លៃក្នុងការងារសំខាន់នេះ ។

មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាលនិងក្រុមប្រឹក្សាឃុំ ក្នុងខេត្តកំពង់ឆ្នាំងនិងសៀមរាបបានរួមចំណែកជាច្រើនក្នុងខ្លឹមសារក្នុងករណីសិក្សា និងការកំណត់តំបន់ប្រមូលព័ត៌មាន ។ ខ្ញុំសូមឆ្លៀតឱកាសនេះសំដែងនូវការកោតសរសើរ និងអរគុណដោយស្មោះ អស់ពីដួងចិត្ត ។

ជាចុងបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកគំរោងគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់ក្នុងការចាត់ចែងភ័ស្តុភាដើម្បីអនុវត្តគំរោងនេះដោយជោគជ័យ ។

លោក **ម្ញូរ៉ារី អាផាត់ឌីយ៉ៃ**
នាយកប្រតិបត្តិ

ភ្នំពេញ ខែធ្នូ ឆ្នាំ២០០៧

# មាតិកា

ទំព័រ


សេចក្តីថ្លែងអំណរគុណ ........................................ i

អារម្ភកថា ........................................ ii

មាតិកា ........................................ iii

១. សេចក្តីផ្តើម ........................................ ១

២. ការផ្តត់ផ្គង់គម្រោងសេវាកម្មរបស់អង្គការ បង្កើតតម្រូវការនៅក្នុងផែនការឃុំ៖ ករណីសិក្សាឃុំតាជេស ខេត្តកំពង់ឆ្នាំង ........................................ ៣

៣. ឃុំគំរូ ឬជា ឃុំដំបូង? ករណីសិក្សាឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ........................................ ១៤

៤. ត្រូវការអ្នកដឹកនាំខ្លាំង ឬ ប្រព័ន្ធខ្លាំង? ករណីសិក្សាឃុំខ្នាពោធិ៍ ខេត្តសៀមរាប ........................................ ២៣

៥. ក្រុមប្រឹក្សាឃុំល្វា ដើរក្នុងទិសដៅត្រូវ៖ សាកល្បងធ្វើគម្រោងសេវាកម្មមុនគេ ........................................ ៣១

ឧបសម្ព័ន្ធៈ ឯកសារយោង ........................................ ៤២

ឧបសម្ព័ន្ធៈ រូបភាព ........................................ ៤៤

# ១. សេចក្ដីផ្ដើម

បច្ចុប្បន្ន នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ និង អង្គការសង្គមស៊ីវិលជាច្រើនទៀត បានចងក្រងករណីសិក្សាជាច្រើនស្ដីអំពីការអនុវត្តការងារ និង គំនិតផ្ដួចផ្ដើមនានារបស់ក្រុមប្រឹក្សាឃុំ ក៏ប៉ុន្តែនៅមានកម្រិតនៅឡើយ។ ដោយហេតុនេះ គេត្រូវការចងក្រងករណីសិក្សានេះបន្ថែមទៀត ដើម្បីផ្សព្វផ្សាយអំពីក្រុមប្រឹក្សាឃុំ ទាំងករណីសិក្សាល្អ និង មិនល្អ ដល់ក្រុមប្រឹក្សាឃុំ រដ្ឋាភិបាល និង អង្គការ សង្គមស៊ីវិល ដើម្បីបានរៀនសូត្រពីបទពិសោធន៍ គម្រោងច្នៃប្រឌិត និង សកម្មភាពនានា សម្រាប់ជាទុនជាមូលដ្ឋានក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ នៅក្នុងដំណើរការវិមជ្ឈការ និង កំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន។

គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ បានផ្ដួចផ្ដើមគំនិតចងក្រងបទពិសោធន៍ និង មេរៀននានា ស្ដីពី ក្រុមប្រឹក្សាឃុំ តាំងពីឆ្នាំ ២០០៥ ដោយបានផលិត ចងក្រង និង ផ្សព្វផ្សាយករណីសិក្សាអំពីក្រុមប្រឹក្សាឃុំ ចំនួនពីរ ទាក់ទងនឹងការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំ នៅក្នុងខេត្តសៀមរាប និង តាកែវ និង ពីរទៀត ទាក់ទងនឹង ដំណើរការកសាងផែនការ និង ថវិកា នៅខេត្តបាត់ដំបង និង កំពង់ចាម។ ករណីសិក្សាទាំងបួននេះ ត្រូវបាន ផ្សព្វផ្សាយ នៅក្នុងសិក្ខាសាលាមួយរយៈពេលពីរថ្ងៃនៅទីក្រុងភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណ ១០០ នាក់ ពីអង្គការសង្គមស៊ីវិល ក្រុមប្រឹក្សាឃុំ និង អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។

ដោយហេតុនេះហើយបានជាគំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ចងក្រងករណីសិក្សានេះបន្តទៀត ក្នុងឆ្នាំ២០០៧នេះ។ គោលដៅរួមគឺចងក្រងករណីសិក្សាចំនួនបួន ស្ដីពីការងារ និង គំនិតផ្ដួចផ្ដើមរបស់ក្រុមប្រឹក្សាឃុំ ក្នុងការផ្ដល់សេវាកម្មសាធារណៈ ទាក់ទងនឹងដំណើរការកសាងផែនការនិងថវិកា ការអនុវត្តគម្រោង ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ។ ករណីសិក្សានេះផ្ដោតលើគម្រោងសេវាកម្មដែលក្រុមប្រឹក្សាឃុំបានប្រើថវិការបស់ខ្លួនទោះបីជាថវិកាផ្ដល់ឱ្យដោយអង្គការ ឬ ដោយមូលនិធិឃុំ សង្កាត់។

ករណីសិក្សានេះធ្វើនៅឃុំបួន ក្នុងខេត្តពីរ គឺ ឃុំតាជេស និង ឃុំរលាប្អៀរ ក្នុងខេត្តកំពង់ឆ្នាំង និង ឃុំខ្នាពោធិ៍ និង ឃុំល្វា ក្នុងខេត្តសៀមរាប ខេត្តដែលគំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ធ្លាប់អនុវត្តគម្រោង មតិពលរដ្ឋចំពោះអភិបាលកិច្ចមូលដ្ឋានធ្លាប់រៀបចំវេទិកាថ្នាក់ស្រុកស្ដីពីការអនុវត្តវិមជ្ឈការនៅថ្នាក់ឃុំនិងបានបង្កើតបណ្ដាញអង្គការមិនមែនរដ្ឋាភិបាលស្ដីពីវិមជ្ឈការ និង វិសហមជ្ឈការ។ ការសិក្សានេះជ្រើសរើសយក ឃុំ ដែលមានភាពជោគជ័យ ឬ មានបទពិសោធន៍ល្អ និង ឃុំដែលមិនមានភាពជោគជ័យ ឬ បទពិសោធន៍មិនសូវល្អ ដោយផ្អែកលើទីតាំងភូមិសាស្ត្រ តូចធំ និង មានក្រ។

វិធីសាស្ត្រប្រើក្នុងការសិក្សានេះរួមមានៈ

- សិក្សាលើទិន្នន័យទី២ ដូចជា ច្បាប់ លិខិតបទដ្ឋាន របាយការណ៍ លទ្ធផលស្រាវជ្រាវ និង ករណីសិក្សា ដែលមានប្រភពពីគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ (គជវវ) គម្រោងគាំទ្រ

ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាមរយៈ វិមជ្ឈការ និង វិសហមជ្ឈការ អង្គការមិនមែនរដ្ឋាភិបាល និង ក្រុមប្រឹក្សាឃុំ

- ទិន្នន័យបឋម តាមរយៈការពិភាក្សានិងសម្ភាសជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត អ្នកសម្របសម្រួលស្រុក ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការកសាងផែនការ និង ថវិកា (គផថ) អង្គការមិនមែនរដ្ឋាភិបាល និង ប្រជាពលរដ្ឋ
- ការចុះពិនិត្យមើលផ្ទាល់ដល់ទីតាំងគម្រោង ព្រមទាំងការទទួលយកយោបល់ត្រឡប់ទាក់ទងនឹង ខ្លឹមសារករណីសិក្សាពីក្រុមប្រឹក្សាឃុំ និង អ្នកពាក់ព័ន្ធ

ករណីសិក្សានេះមិនគ្របដណ្តប់លើបញ្ហា ឬ គំនិតផ្តួចផ្តើមទាំងឡាយណា ដែលស្ថិតនៅក្រោមកម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ និងគម្រោងកិច្ចសហប្រតិបត្តិការរវាងឃុំសង្កាត់និងឃុំសង្កាត់។ វាគ្របដណ្តប់តែលើគម្រោង ឬ គំនិតផ្តួចផ្តើម ដែលធ្វើឡើងដោយក្រុមប្រឹក្សាឃុំផ្ទាល់ និង ឬ ដោយមានកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល។



# ការផ្តត់ផ្គង់គម្រោងសេវាកម្មរបស់អង្គការ បង្កើតគម្រូការនៅក្នុងផែនការឃុំ៖ ករណីសិក្សាឃុំតាជេស ខេត្តកំពង់ឆ្នាំង[១]

## ស្ថានភាពទូទៅរបស់ឃុំតាជេស

ឡានតូចមួយគ្រឿងបានមកដល់សាលាឃុំតាជេស ក្រោយពីបានធ្វើដំណើរពីទីរួមខេត្តកំពង់ឆ្នាំង ប្រមាណ ៣០ នាទី មក ។ ចុះពីផ្លូវជាតិប្រហែល ១៥ នាទី នៅលើផ្លូវលំដីក្រហម ចម្ងាយប្រមាណ ៥ គ.ម គេនឹងបានឃើញ ថា ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងមូលដ្ឋាន មានសភាពខុសគ្នា ពេលដែលគេធ្វើដំណើរកាន់តែឆ្ងាយទៅ ។ ប្រជាជន ដែលនៅខាងលើជិតទីប្រជុំជន និង ជិតផ្លូវជាតិ មានជីវភាពល្អជាងប្រជាជន ដែលនៅឆ្ងាយពីទីប្រជុំជន និង ពីផ្លូវជាតិ ។ តំបន់ឆ្ងាយនេះ គឺជាទីតាំងសាលាឃុំតាជេស ដែលមានសភាពទ្រុឌទ្រោមទៅហើយ ។

ឃុំតាជេស ស្ថិតនៅចម្ងាយផ្លូវ ៣ គ.ម និង ស្ថិតនៅខាងជើង នៃសាលាស្រុកកំពង់ត្រឡាច និង មាន ចម្ងាយ ៣៥ គ.ម ពីទីរួមខេត្តកំពង់ឆ្នាំង ។ មកដល់ឆ្នាំ ២០០៦ ប្រជាជនក្នុងឃុំតាជេសបានកើនឡើងដល់ ២.៣៧៥ គ្រួសារ ស្មើនឹង ១២.៦៥៤ នាក់ ក្នុងនោះគ្រួសារ ដែលមានមុខរបរធ្វើស្រែជាចំបងមានចំនួន ២.២៣១ នៅលើផ្ទៃដី បង្កបង្កើនផលស្រូវសរុប ២.៦៥០ ហ.ត និង គ្រួសារ ដែលប្រកបមុខរបរសេវាកម្មជាចំបង (ដូចជា ជំនួញ ជាង ដឹកជញ្ជូន សេវាកម្ម និង ផ្សេងៗ) មាន ១០២ គ្រួសារ ។ ក្នុងឃុំ ដែលមានតែផ្លូវលំក្រាលក្រួសក្រហម ខ្សាច់ភ្នំ និង ផ្លូវលំដីស ប្រវែងជាង ២ ម៉ឺនម៉ែត្រនេះ ទាមទារឱ្យប្រជាជនធ្វើដំណើរចម្ងាយ ៤.៩៥ គ.ម ជាមធ្យមពីភូមិទៅ សាលាឃុំ ។ ក្នុងឃុំនេះទាំងមូលមានផ្សារស្ថិតនៅក្នុងភូមិពីរ គឺភូមិកំពង់តាជេស និង ភូមិស្វាយក្រោម បម្រើឱ្យ ប្រជាជន ១៥ ភូមិ ។

នៅក្នុងឃុំតាជេស ស្ថានភាពដីមានពីរប្រភេទ គឺតំបន់វាលរាប ៦៥% និង តំបន់វាលទំនាប ៣៥% ។ ផ្ទៃដីមួយភាគធំជាដីខ្សាច់ស ខ្សោះជីជាតិ ហើយខ្វះប្រភពទឹកនៅជិត ។ ចំណែកឯដីមួយផ្នែកទៀត ក្នុងភូមិត្រពាំងព្រាល

[១] ករណីសិក្សានេះសរសេរដោយលោក អ៊ឹម សុខធី សម្រាប់គំរោងគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ (CCSP) ដើម្បីផ្សព្វផ្សាយអំពីបទពិសោធន៍ និង មេរៀន ដែលក្រុមប្រឹក្សាឃុំទទួលបានកន្លងមក ទាក់ទងនឹងដំណើរការកសាងផែនការ និង ថវិកា ការអនុវត្តគម្រោង និង ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ ។ ករណីសិក្សានេះផ្តោតលើគម្រោងសេវាកម្ម ដែលក្រុមប្រឹក្សាឃុំបានប្រើថវិការបស់ខ្លួន ទោះបីជាថវិកាផ្តល់ឱ្យដោយអង្គការ ឬ ដោយមូលនិធិឃុំ សង្កាត់ ។ ករណីសិក្សានេះបង្ហាញនូវស្ថានភាពជាក់ស្តែង ហើយអ្នកនិពន្ធសន្មតទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារនៃករណីសិក្សានេះ ។ ជំនួយការស្រាវជ្រាវគឺលោក ឈឹម សុភាគ មន្ត្រីព័ត៌មានរបស់ CCSP ។ ករណីសិក្សានេះមិនអាចចម្លងទោះជាដោយផ្នែក ឬ ទាំងមូលនោះទេ បើគ្មានការអនុញ្ញាតពីគំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ។ រក្សាសិទ្ធិ©គំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ខែ ធ្នូ ឆ្នាំ ២០០៧ ។

វត្តថ្មី ធ្លកយល់ សំព័រ ស្វាយបាការ តាជេស និង ស្វាយក្រោម គឺជាដីល្បាប់ សំបូរជីជាតិ ហើយមានទឹកលិចនៅ រដូវវស្សា។ ដីនៅតំបន់នេះ មានអំណោយផលសម្រាប់ការធ្វើស្រែប្រាំង និង ដាំឈូក។ ជាមធ្យម ក្នុងដី ១ ហិកតា ប្រជាជនធ្វើស្រែបានទិន្នផលជាង ១ តោន បន្តិចបន្តួច។

## អំពីក្រុមប្រឹក្សាឃុំតាជេស

ព្រឹត្តិការណ៍ដ៏សំខាន់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាខែកុម្ភៈ ឆ្នាំ២០០២ និង នាខែ មេសា ឆ្នាំ២០០៧ បានកំណត់នូវការអនុវត្តលទ្ធិប្រជាធិបតេយ្យ ដែលមានការចូលរួមបែបវិមជ្ឈការ ក្នុងការគ្រប់គ្រង នៅមូលដ្ឋាន ដោយបាននាំយកអភិបាលកិច្ចទៅដាក់ឱ្យនៅជិតប្រជាពលរដ្ឋ។ ដូចគ្នានឹងឃុំ សង្កាត់ ចំនួន ១.៦២០ ទៀតដែរ ការបោះឆ្នោតនេះតម្រូវឱ្យមន្ត្រីដែលបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៅក្នុងឃុំតាជេស បានបំពេញតួនាទី និង មុខងារទាក់ទងនឹងការផ្ដល់សេវាសាធារណៈ ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម នៅមូលដ្ឋាន ការការពារធនធានធម្មជាតិ និង ការឆ្លើយតបចំពោះសេចក្ដីត្រូវការរួមរបស់ប្រជាពលរដ្ឋ។

### ប្រវត្តិលោកមេឃុំ

លោកមេឃុំ បានមានប្រសាសន៍ថា *"ខ្ញុំចង់ដោះស្រាយបញ្ហាការខ្វះខាតទឹក ការស្រោចស្រព ដូចជា ទំនប់ ប្រឡាយ ដើម្បីដោះស្រាយជីវភាព ពោលគឺធ្វើយ៉ាងមេចឱ្យបានប្លែកពីមួយអាណត្តិទៅមួយអាណត្តិទៀត"*។

កើតក្នុងឆ្នាំ១៩៥៩ ជាឪពុកមានកូនបីនាក់ លោក**ឌី ឌឿន** គឺជាប្រធានក្រុមប្រឹក្សានិងជាមេឃុំតាជេស ស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ លោក **ឌី ឌឿន** ជាមនុស្សប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យ ក្នុងការដឹកនាំ មូលដ្ឋានភូមិ ឃុំ ហើយអាចបែងចែកដាច់ពីគ្នារវាងការងារក្រុមប្រឹក្សា និង ការងារគណបក្ស។ លោកស្រីជំទប់ទី ១ មកពី គណបក្សសមរង្ស៊ី រៀបរាប់អំពីចរិតលក្ខណៈរបស់លោកមេឃុំថា គាត់ជាមនុស្សមានសិលធម៌ល្អជាងគេ។ទោះជាយ៉ាង ណាក៏ដោយ លោកមេឃុំទទួលស្គាល់ថា គាត់គឺជាមនុស្សម្នាក់ ដែលមានចំណេះដឹងតិចជាងគេ ក្នុងចំណោមសមាជិក ក្រុមប្រឹក្សាទាំងអស់។ លោកក៏បានប្រាប់ដែរថា លោកមានជំងឺ ដែលមិនសូវទៀងទាត់ទេ ជួនឈឺ ជួនជា ប៉ុន្តែវាមិនធ្ងន់ធ្ងរ ទេ។ លោកមេឃុំរៀនបានត្រឹមថ្នាក់ទី ១០ ចាស់ (សំដៅលើប្រព័ន្ធអប់រំនៅមុនទសវត្សរ៍ឆ្នាំ ១៩៨០)។ ក្រោយឆ្នាំ ១៩៧៩ លោកបានចូលបម្រើការងារជាកងឈ្លប រហូតដល់ឆ្នាំ១៩៨៥ គាត់បានក្លាយជាប្រធានយោធាភូមិ។ ពីឆ្នាំ ១៩៨៩ រហូតដល់ ឆ្នាំ ២០០២ គាត់គឺជាប្រធានយោធាឃុំ។ នៅឆ្នាំ ២០០២ គាត់បានឈរឈ្មោះក្នុងបញ្ជីបេក្ខជនរបស់គណបក្សប្រជាជន កម្ពុជា ដើម្បីចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ អាណត្តិទី១ ហើយបានជាប់ជាប្រធានក្រុមប្រឹក្សាឃុំ ដែលមាន សមាជិក ៩ រូប។ ក្នុងអាណត្តិទី ២ នេះ គាត់បានជាប់ឆ្នោតម្តងទៀត ជាប្រធានក្រុមប្រឹក្សាឃុំ។

ក្រុមប្រឹក្សាឃុំក្នុងអាណត្តិទី១ មានសមាជិកចំនួន ៩ រូប មកពីគណបក្សប្រជាជនកម្ពុជា គណបក្ស ហ៊្វុនស៊ិនប៉ិច និង គណបក្សសមរង្ស៊ី។ សមាជិកទាំង ៩ រូប ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិធ្លកយល់ ភូមិសំរោង ភូមិតាជេស ភូមិសំព័រ និង ភូមិស្នាយ ហើយដូច្នេះនៅភូមិចំនួន១០ទៀត ពុំមានតំណាងរបស់ខ្លួន នៅក្នុងក្រុមប្រឹក្សា ឃុំទេ។ ទោះបីយ៉ាងនេះក៏ដោយ ក៏សមាជិកក្រុមប្រឹក្សាឃុំបញ្ជាក់ថា វាមិនធ្វើឱ្យមានការលំបាក ក្នុងការប្រាស្រ័យ ទាក់ទងគ្នា នៅក្នុងភូមិ ដែលពុំមានតំណាងក្រុមប្រឹក្សាឡើយ ព្រោះគេអាចទំនាក់ទំនង ឬ អញ្ជើញតាមទូរស័ព្ទ។

## ការគិតដំបូងអំពីសមិទ្ធិផលរបស់ក្រុមប្រឹក្សាឃុំ គឺហេដ្ឋារចនាសម្ព័ន្ធ

ខណៈពេលដែលសួរអំពីថាតើមានសមិទ្ធិផលអ្វីខ្លះ ដែលសម្រេចបាននៅក្នុងឃុំតាជេស? ភ្លាមនោះ ក្រុមប្រឹក្សាឃុំបានឆ្លើយ ហើយ រៀបរាប់អំពីសមិទ្ធិផលហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដែលសម្រេចបាននៅក្នុងឃុំ។ លោកមេឃុំ និង សមាជិកក្រុមប្រឹក្សាបានពិពណ៌នាថា ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅ ក្នុងអាណត្តិទី ១ រវាងឆ្នាំ ២០០២ ដល់ឆ្នាំ២០០៧ ឃុំតាជេសសម្រេចបានសមិទ្ធិផលហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដូចជា ផ្លូវលំ ស្ពាន លូកាត់ផ្លូវ សាលារៀន ទ្វារទឹក ទំនប់ ប្រឡាយ ។ល។ ដោយថវិការបស់ឃុំផង និង ថវិការបស់មន្ទីរ អង្គការ និង ស្ថាប័ននានាផង។ ទាំងនេះគឺបានមកពីការកំណត់អាទិភាពរបស់ឃុំ ដែលផ្តោតជាសំខាន់លើការស្តារ ការកសាង និង ការជួសជុល ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសប្រព័ន្ធធារាសាស្ត្រ។ ជាក់ស្តែង ក្នុងឆ្នាំ ២០០៥ ក្រុមប្រឹក្សាឃុំបានប្រើប្រាស់ថវិកា មូលនិធិឃុំ ធ្វើប្រឡាយមួយខ្សែប្រវែង ២.៧០០ ម សម្រាប់បម្រើសេចក្តីត្រូវការនៅប្រាំភូមិ ក្នុងចំណោមភូមិទាំង ១៥។ ប្រឡាយនេះបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់កសិករ ដូចជា (១) ចំណាយពេលវេលាក្នុងការ ស្រោចស្រពតិចជាងមុន ដោយសារទីតាំងប្រឡាយនៅក្បែរដីស្រែរបស់កសិករ (២) មិនបណ្តាលឱ្យខូចស្រូវ (៣) ចំណាយថវិកាសម្រាប់ចាក់សាំងម៉ាស៊ីនបូមទឹកអស់តិចជាងមុន និង (៤) កសិករអាចមានទឹកប្រើប្រាស់របូត។

ជាទូទៅ គម្រោងហេដ្ឋារចនាសម្ព័ន្ធ ច្រើនប្រើកញ្ចប់ថវិកាឃុំ ចំណាយច្រើន មានទ្រង់ទ្រាយធំ ហើយបម្រើសេចក្តីត្រូវការដល់ប្រជាជនបានយ៉ាងច្រើន។ ដូច្នេះ សមិទ្ធិផលនេះងាយរាប់ និង ចងចាំជាងសមិទ្ធិផលបែប សេវាកម្ម ដែលភាគច្រើនមិនមែនក្រុមប្រឹក្សាឃុំជាអ្នកអនុវត្តផ្ទាល់។ តាមពិត ចំណុចនេះមិនមែនបញ្ជាក់ថា ក្រុមប្រឹក្សាបំភ្លេច ឬមើលរំលងគម្រោងសេវាកម្មឡើយ។ ក្រុមប្រឹក្សាឃុំបានលើកយកគម្រោងសេវាកម្មជាច្រើន ដាក់ក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ ដើម្បីស្វែងរកការគាំទ្រពីមន្ទីរ អង្គការ ស្ថាប័ន និង សប្បុរសជន នៅក្នុង សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដែលគេរៀបចំរៀងរាល់ឆ្នាំ ជាទូទៅក្នុងរវាងពីខែសីហា ដល់ ខែវិច្ឆិការ នៅតាមស្រុកនីមួយៗ។ ចំពោះការលើកផែនការដាក់បញ្ចូលគម្រោងសេវាកម្មទាំងនេះ ក្រុមប្រឹក្សាឃុំហាក់ដឹង ច្បាស់ថា ក្រុមប្រឹក្សាឃុំនឹងមិនប្រើថវិកាឃុំដើម្បីអនុវត្តគម្រោងនេះទេ បើសិនគ្មានមន្ទីរ អង្គការ ឬ សប្បុរសជន គាំទ្រ។

## អាទិភាពរបស់គម្រោងមួយ បានជួយដល់គម្រោងផ្សេងទៀត

អាទិភាពគម្រោងក្នុងអាណត្តិទី១និងអាណត្តិទី២នឹងមិនខុសគ្នាប៉ុន្មានទេពេលដែលឃុំតាជេសនៅតែសំលឹងឃើញថា ការកសាងហេដ្ឋារចនាសម្ព័ន្ធ ក្នុងផ្នែកធារាសាស្ត្រ និង ផ្លូវលំជាអាទិភាពត្រូវយកចិត្តទុកដាក់ បន្តទៀត។ លោកមេឃុំបានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំចង់បន្តធ្វើប្រឡាយ ទំនប់បន្ថែមទៀត និង ចង់ធ្វើផ្លូវលំឱ្យ បានឆ្លងកាត់នៅគ្រប់ភូមិទាំង ១៥ របស់ឃុំតាជេស។ ក៏ប៉ុន្តែ លោកមេឃុំហាក់មានភាពស្ទាក់ស្ទើរ ក្នុងការកំណត់យកគម្រោងសេវាកម្មជាអាទិភាព។

ទាំងលោកមេឃុំនិងសមាជិកក្រុមប្រឹក្សាបានមើលឃើញដូចគ្នាថាគម្រោងសេវាកម្មជាច្រើនដែលបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងឃុំនេះភាគច្រើនពុំទទួលបានជោគជ័យល្អខ្លាំងទេដោយសារប្រជាជនមិនសងប្រាក់ខ្ចីដែលអង្គការបានផ្តល់ឱ្យ។ ក្នុងន័យនេះ ក្រុមប្រឹក្សាឃុំចង់ទុកថវិកាឃុំ សម្រាប់អនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ហើយ ទុកឱ្យគម្រោងសេវាកម្មអនុវត្តផ្ទាល់ដោយអង្គការចុះ។ពោលគឺ ក្រុមប្រឹក្សានឹងសម្របសម្រួល និង សហការជាមួយអង្គការ ក្នុងការអនុវត្តគម្រោងសេវាកម្មវិញ។ តើមានកត្តា ឬ បញ្ហាអ្វីខ្លះលើសពីនេះ ដែលនាំឱ្យក្រុមប្រឹក្សាយល់ឃើញបែបនេះ?

គម្រោងសេវាកម្មជាច្រើនដែលក្រុមប្រឹក្សាបានលើកឡើងនៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលបានទទួលចំណាត់ថ្នាក់អាទិភាពខ្ពស់ ហើយ ត្រូវបានដាក់បង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការ ថ្នាក់ស្រុកដើម្បីស្វែងរកការគាំទ្រពីស្ថាប័នផ្សេងៗ។ ចំណុចនេះបញ្ជាក់ថា មិនមែនត្រឹមតែគម្រោងហេដ្ឋារចនាសម្ព័ន្ធ ប៉ុណ្ណោះទេ ប៉ុន្តែគម្រោងសេវាកម្មក៏មានសារៈសំខាន់សម្រាប់បំពេញសេចក្តីត្រូវការ និង ការលើកកម្ពស់ជីវភាព រស់នៅរបស់ប្រជាជនដែរ។ ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាឃុំមិនបានគិតទុកជាមុនថា ក្រុមប្រឹក្សាឃុំនឹងអនុវត្ត គម្រោងសេវាកម្ម ដោយប្រើកញ្ចប់ថវិការបស់ខ្លួន ហើយអនុវត្តដោយខ្លួនឯងទេ។ ក្រុមប្រឹក្សាឃុំទទួលស្គាល់ថា ក្រុមប្រឹក្សាខ្វះចំណេះដឹង និង បទពិសោធន៍ និង មិនស៊ីជម្រៅអំពីគោលគំនិត និង របៀបអនុវត្តគម្រោងសេវាកម្ម ហើយបញ្ជាក់ថា អង្គការមានសមត្ថភាពជាង មានគោលនយោបាយល្អ ហើយមានការចងចាំបានល្អជាង។

ក្រុមប្រឹក្សាឃុំយល់ឃើញថាគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលសម្រេចបានកន្លងមក ពិតជាបានជួយដល់ ការគិតគូរអំពីគម្រោងសេវាកម្មផ្សេងៗនៅក្នុងឃុំ។ ឧទាហរណ៍ថា ឥឡូវនេះ ឃុំមានផ្លូវសម្រាប់ធ្វើដំណើរ និង ការដឹកជញ្ជូន ហើយមានប្រឡាយនិងទំនប់សម្រាប់ធ្វើស្រែដូច្នេះឃុំអាចលើកយកគម្រោងសេវាកម្មដើម្បី លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដូចជា គម្រោងផ្តល់ឥណទានពូជមេគោ គម្រោងធ្វើជីកំប៉ុស្ត មុខរបរ ខ្នាតតូច (ចិញ្ចឹមមាន់ ជ្រូក) ។ល។ទឹកគឺសម្រាប់ធ្វើស្រែ ហើយផ្លូវគឺសម្រាប់ដឹកជញ្ជូនស្រូវ អង្ករ និង ឥវ៉ាន់ផ្សេងៗ ទៅលក់នៅផ្សារ។ ពោលគឺគម្រោងហេដ្ឋារចនាសម្ព័ន្ធ និង គម្រោងសេវាកម្មបាន និង កំពុងបំពេញឱ្យគ្នាទៅវិញ ទៅមក ឆ្ពោះទៅរកគោលបំណងតែមួយគឺការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និង ការកាត់បន្ថយភាពក្រីក្រ។ សមាជិកក្រុមប្រឹក្សាឃុំមួយរូបបានមានប្រសាសន៍ថា ក្នុងមួយអាណត្តិ បើយើងផ្តោតលើធារាសាស្ត្រនោះជីវភាពប្រជាពលរដ្ឋនឹងអាចធានាបាន ។សេវាកម្មធ្វើជីកំប៉ុស្តដើម្បីកែប្រែគុណភាពដីក៏ជាគម្រោងលើកកម្ពស់ជីវភាពរស់នៅដែរ។

## ការបង្ហាញអំពីផែនការផ្គត់ផ្គង់គម្រោង បានបង្កើតតម្រូវការ

តម្រូវការគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅតែចាំបាច់ខ្លាំងសម្រាប់ប្រជាជន។ ទោះបីជាមានការបំផុសគំនិត អំពីការលើកយកគម្រោងសេវាកម្មក៏ដោយ ក៏ប្រជាជន ដែលចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំ នៅតែមាន ទំនោរទៅរកគម្រោងហេដ្ឋារចនាសម្ព័ន្ធដែរ។ ប្រជាជន ដែលចូលរួមប្រជុំភូមិនៅជំហាន២ នៃដំណើរការរៀបចំ កម្មវិធីវិនិយោគឃុំ មានចំនួនក្រោម ៦0% ដែលភាគច្រើនគឺជាស្ត្រី។ ក្នុងចំណោមអ្នកចូលរួមទាំងនេះ គេពុំបាន សង្កត់ធ្ងន់លើអ្នកចូលរួមជាគ្រួសារក្រីក្រទេ។

ជាទូទៅ ការចូលរួមរបស់ប្រជាជនពុំបានបន្ថែម ឬ លុបចេញនូវ គម្រោង ដែលកំណត់ និង ពិភាក្សានៅថ្នាក់ឃុំ ក្នុងជំហាន១ឡើយ ។ ស្ថានភាពបែបនេះហាក់ដូចជាឆ្លុះបញ្ចាំងថា ឥឡូវនេះ ក្រុមប្រឹក្សាឃុំមានគម្រោងជាច្រើនដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដូច្នេះ តើប្រជាពលរដ្ឋ ត្រូវការទំនិញ និង សេវាកម្ម ដែលក្រុមប្រឹក្សាឃុំបានរៀបចំហើយនេះ ឬទេ ។ វាទំនងជាបញ្ជាក់ថា ការផ្គត់ផ្គង់ បង្កើតតម្រូវការ ។ ប្រជាជនបានចូលរួមធ្វើផែនការជារៀងរាល់ឆ្នាំ ហើយគម្រោង ដែលបានលើកឡើងពុំមាន ខុសគ្នាច្រើនទេ ពីមួយឆ្នាំទៅមួយឆ្នាំ ខណៈពេលដែលតម្រូវការរបស់ប្រជាជនមានការប្រែប្រួល ។

ដូចគ្នានឹងឃុំជាច្រើនទៀតនៅក្នុងទូទាំងប្រទេសដែរ ក្រុមប្រឹក្សាឃុំបានលើកយកគម្រោងយ៉ាងច្រើន ទៅដាក់បង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដោយសង្ឃឹមថា មន្ទីរ អង្គការ និង សប្បុរសជន នានា គាំទ្រគម្រោងឃុំ ទោះបីឃុំខ្លួនឯងដឹងថា ឃុំពុំមានថវិកាគ្រប់គ្រាន់ដើម្បីធ្វើគម្រោងទាំងនោះក៏ដោយ ។ ក្នុងសិក្ខាសាលានេះ មន្ទីរនិង អង្គការ បានគាំទ្រគម្រោងសេវាកម្មច្រើនជាងគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលភាគច្រើន ជាថវិកាវិភាជន៍ពីមូលនិធិឃុំសង្កាត់ ។

អ្វីដែលគួរឱ្យកត់សម្គាល់លើសពីនេះគឺថា នៅមានប្រភេទគម្រោងសេវាកម្មជាច្រើនទៀត ដែលក្រុមប្រឹក្សាឃុំអាចលើកឡើងនៅក្នុងកម្មវិធីវិនិយោគរបស់ខ្លួន នៅក្នុងខណៈពេលដែលក្រុមប្រឹក្សាឃុំបានដឹងថា មានអង្គការណាមួយ នឹងអនុវត្តគម្រោងសេវាកម្មនៅក្នុងភូមិឃុំរបស់ខ្លួន ។ ការដឹងថា មានអង្គការណាមួយនឹងដាក់ (ផ្គត់ផ្គង់) គម្រោង នោះក្រុមប្រឹក្សាឃុំនឹងគិតថា យើងនឹងមានតម្រូវការមួយ គឺដាក់ប្រភេទគម្រោងនោះទៅក្នុងកម្មវិធី វិនិយោគរបស់ឃុំ ។ ជាក់ស្តែងក្នុងឆ្នាំ ២០០៦ នៅពេលដែលក្រុមប្រឹក្សាឃុំបានដឹងថា សមាគមភ្នំនាងកង្រីបានចុះ ទៅពិនិត្យស្ថានភាព និងលទ្ធភាពអនុវត្តគម្រោងឥណទានពូជមេគោនៅក្នុងឃុំតាជេស ក្រុមប្រឹក្សាឃុំក៏បានរៀបចំ សម្រួលដាក់គម្រោងនេះ ទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ ។ ហើយបន្ទាប់មក ក្រុមប្រឹក្សាឃុំបានដាក់សំណើគម្រោង ឥណទានពូជមេគោទៅសមាគមភ្នំនាងកង្រី ។ សមាជិកក្រុមប្រឹក្សាឃុំមួយរូបបានឱ្យដឹងថា បើសិនដឹងថា មាន អង្គការណាមួយនឹងធ្វើគម្រោងសេវាកម្មណាមួយក្នុងឃុំនោះក្រុមប្រឹក្សាឃុំនឹងហ៊ានលើកក្នុងកម្មវិធីវិនិយោគឃុំ ។ សូមបញ្ជាក់ថា ជាទូទៅ អង្គការមិនមែនរដ្ឋាភិបាលមានចេតនាអនុវត្តកម្មវិធីតាមរយៈក្រុមប្រឹក្សា ក្នុងការបង្កើត ប្រាក់ចំណូលនៅមូលដ្ឋាន និង ការកែលំអផលិតកម្ម ។

## ដំណើរការកសាងផែនការ និង ថវិកាឃុំ នៅតែត្រូវការអ្នកជួយ

ការធ្វើកម្មវិធីវិនិយោគឃុំ គឺជាដំណើរការដដែលៗ ហើយត្រូវធ្វើឡើងវិញទាំង១១ ជំហាន ជារៀងរាល់ឆ្នាំ ។ ក្នុងអាណត្តិទី២ នៃក្រុមប្រឹក្សាឃុំ សង្កាត់ ២០០៧-២០១១ ដំណើរការរៀបចំកម្មវិធីវិនិយោគឃុំត្រូវបាន កែសម្រួលមកត្រឹម

[2] មូលនិធិឃុំ សង្កាត់ គឺជាយន្តការលំហូរមូលនិធិពីរាជរដ្ឋាភិបាល ម្ចាស់ជំនួយ និង ប្រភពធនធានផ្សេងទៀត ដើម្បីផ្តល់ ហិរញ្ញប្បទានដល់ការចំណាយរបស់ឃុំ ។

៥ ជំហាន ដែលជំហាននីមួយៗចែកជាដំណាក់កាល។ បើពិនិត្យជារួម គេសង្កេតឃើញថា មានការកែសម្រួល ប៉ុន្តែបើពិនិត្យឱ្យលម្អិត ដំណើរការថ្មីនេះមិនខុសគ្នាប៉ុន្មានទេពីដំណើរការចាស់។ មានន័យថា ការធ្វើកម្មវិធីវិនិយោគឃុំពុំមែនថ្មី ហើយក្រុមប្រឹក្សាឃុំត្រូវរៀនឡើងវិញទាំងស្រុងនោះទេ។ ប៉ុន្តែក្រុមប្រឹក្សាឃុំ នៅតែបង្ហាញថា ខ្លួនពុំអាចរៀបចំកម្មវិធីនេះបានដោយខ្លួនឯង ប្រសិនបើពុំមានការជួយយោបល់ពីក្រុមសម្របសម្រួល និង អ្នកបច្ចេកទេស។

**មាត្រា ៦០.**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័ត និង អនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និង កិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។

**មាត្រា ៦២.**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រម ដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី១ នៃអាណត្តិរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញ ដើម្បីផ្តល់ទិន្នន័យថ្មីៗ ជារៀងរាល់ឆ្នាំដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

ប្រភព: ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

អ្នកសម្របសម្រួលស្រុក ប្រចាំឃុំតាជេស ពន្យល់អំពីចំណុចនេះថា មកពីក្រុមប្រឹក្សាឃុំពុំ សូវស៊ីជម្រៅ ហើយយល់មិនច្បាស់អំពីដំណើរការ និងរបៀបធ្វើកម្មវិធីវិនិយោគឃុំ ហើយម្យ៉ាងវិញទៀត ក្រុមប្រឹក្សាឃុំខ្លាចធ្វើទៅខុសពីគោលការណ៍ណែនាំ។ក្រុមប្រឹក្សាឃុំអាចមានអារម្មណ៍ទទួលការពឹងពាក់ ឬ មានទម្លាប់រង់ចាំការជំរុញនិង ការណែនាំឱ្យធ្វើកម្មវិធីវិនិយោគឃុំ ទើបចាប់ផ្តើមចាត់ចែងធ្វើ។ លោកស្រីសម្រប- សម្រួលស្រុកបានបន្តថា ចំណុចនេះអាចមកពីសមត្ថភាពដឹកនាំមានកម្រិតរបស់លោកមេឃុំ ដែលមានអារម្មណ៍ ខ្លាចធ្វើខុស ហើយមិនច្បាស់លាស់ និង ស្ទាក់ស្ទើរក្នុងការធ្វើសេចក្តីសម្រេចចិត្តអ្វីមួយ។ រីឯសមត្ថភាពរបស់ សមាជិកក្រុមប្រឹក្សាដទៃពូកែជាងគាត់។ សមត្ថភាពមានកម្រិតនេះអាចបណ្តាលឱ្យមានផលប៉ះពាល់មិនល្អ មកលើ ដំណើរការកសាងផែនការ និង ថវិកា។

ពិតមែនហើយ ដំណើរការកសាងផែនការមានភាពស្មុគស្មាញ ហើយ មិនសមស្របនឹងសមត្ថភាពមាន កម្រិតរបស់ក្រុមប្រឹក្សាឃុំឡើយ។ ប្រជាពលរដ្ឋ មន្ទីរ និង អង្គការនានា ដែលមិនមែនជាអ្នកប្រឡូកផ្ទាល់ក្នុង ដំណើរការនេះ ក៏អាចពិបាកយល់ និង ធ្វើផែនការឱ្យបានល្អដែរ។ ដោយហេតុនេះ ជាទូទៅ គេសង្កេតឃើញថា ដំណើរការនេះត្រូវមានការជំរុញ និង ការជួយសម្របសម្រួលពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុមសម្របសម្រួលខេត្ត ស្រុក អ្នកបច្ចេកទេស មន្ទីរផែនការ និង អ្នកពាក់ព័ន្ធដទៃទៀត។ ដំណើរការនេះត្រូវការទាំងពេលវេលា និង ថវិកា ព្រមទាំងឆន្ទះ និង ការចូលរួមពីតួអង្គពាក់ព័ន្ធជាច្រើន ហើយ ងាយធ្វើឱ្យប្រជាពលរដ្ឋមានក្តីសង្ឃឹមច្រើន។ ទាំង ក្រុមប្រឹក្សាឃុំ និង ប្រជាពលរដ្ឋ បានចូលរួមក្នុងដំណើរការកសាងផែនការ ហើយ បានលើកយកគម្រោងជាច្រើន ជាមធ្យម យ៉ាងតិច ៣០ គម្រោង ក្នុង១ឃុំ ដែលនៅទីបញ្ចប់អាចធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ទំនុកចិត្តមកលើ ក្រុមប្រឹក្សា នៅពេលដែលគម្រោង ដែលស្នើឡើង គ្មានការគាំទ្រ។

អាទិភាព ដែលលើកឡើងក្នុងកម្មវិធីវិនិយោគ ឃុំមានច្រើន ទោះបីក្រុមប្រឹក្សាឃុំ និង អ្នកដទៃបានដឹងថា ធនធានរបស់ឃុំមានកម្រិតក៏ដោយ ។ វាមានភាពខុសគ្នា ជាខ្លាំងរវាងធនធាន ដែលមាន និង អាទិភាពនៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ។

ដំណើរការកសាងផែនការ និង ថវិកាឃុំ ត្រូវស្ថិតនៅការគ្រប់គ្រងគណៈកម្មាធិការមួយ ជាជំនួយការឱ្យ ប្រធានក្រុមប្រឹក្សាឃុំ ។ គណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំ គឺជាមធ្យោបាយសម្របសម្រួលតំណាង ផលប្រយោជន៍របស់អ្នកភូមិ និងជួយកំណត់អាទិភាពសម្រាប់គោលនយោបាយ និង កម្មវិធីអភិវឌ្ឍន៍ឃុំ ព្រមទាំង នៅក្នុងការផ្តល់យោបល់អំពីការចាត់ចែងធនធាន ដែលមានដោយកម្រនៅក្នុងឃុំ ។

គណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំ មាន ភារកិច្ច និង ការទទួលខុសត្រូវ ដូចខាងក្រោមៈ

- ជួយមេឃុំក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគ និង ថវិកាប្រចាំឆ្នាំរបស់ឃុំ
- ត្រូវអនុវត្តវិធីសាស្ត្រកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និង គម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ តាមអភិក្រមមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ
- ជួយមេឃុំ ក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់ឃុំ

ប្រភពៈ សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំតាជេស ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៧ ។

គ.ផ.ថ ឃុំតាជេសមានសមាជិក ៣៥រូប ដឹកនាំដោយមេឃុំ មាន សមាសភាពមកពីក្រុមប្រឹក្សា ឃុំ ៧រូប និង គ្រប់ភូមិ ដូចជា មេភូមិអនុភូមិនិងសមាជិកភូមិ ។ជាធម្មតា គ.ផ.ថ មានតួនាទីផ្តល់យោបល់តិចតួច ដោយសារ គ.ផ.ថ លែងមាន សកម្មភាព ក្រោយពេលរៀបចំ ផែនការអភិវឌ្ឍន៍រួច ។

## ឃុំនឹងមានការរីកចម្រើន ឱ្យតែហ៊ានចាប់ដៃជាមួយអង្គការ

អង្គការទស្សនៈពិភពលោកបានធ្វើសកម្មភាពនៅក្នុងឃុំតាជេស តាំងពីក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មកម្លេះ ប៉ុន្តែសព្វថ្ងៃនេះ អង្គការទស្សនៈពិភពលោកបានដកចេញសកម្មភាពអស់ជាច្រើន ហើយនៅសល់តែគម្រោងគាំពារ កុមារងាយរងគ្រោះប៉ុណ្ណោះ ។ ក្រៅពីនេះ មានសមាគមភ្នំនាងកង្រី និង កម្មវិធីអប់រំសុខភាពសុខភាពសហគមន៍ ដែលទើបចូលមកក្នុងឃុំ ក្នុងឆ្នាំថ្មីៗនេះ ។

ជាធម្មតា ឃុំតែងតែប្រឹងប្រែងស្វែងរកដៃគូអភិវឌ្ឍន៍ តែនៅពេលសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកប៉ុណ្ណោះ ។ នៅពេលដែលសួរថាតើក្រុមប្រឹក្សាឃុំមានយុទ្ធសាស្ត្រ ឬ សកម្មភាពអ្វីខ្លះ ដើម្បីទាក់ទាញឱ្យមាន អង្គការស្ថាប័ននានា ចូលមកធ្វើសកម្មភាពនៅក្នុងឃុំ ក្រុមប្រឹក្សាឃុំហាក់ដូចជាគ្មានផែនការច្បាស់លាស់ទេ អំពីបញ្ហានេះ ។ គេតែងសង្កេតឃើញថា ច្រើនតែអង្គការ ឬ ស្ថាប័នទៅវិញទេ ដែលបានមកធ្វើសកម្មភាពនៅក្នុងឃុំ ដែលអង្គការ ឬ ស្ថាប័នទាំងនោះ

បានកំណត់ជាតំបន់គោលដៅរួចទៅហើយ ។ ទោះជាបែបនេះក៏ដោយ ក្រុមប្រឹក្សាឃុំតាជេសបានបង្ហាញពីចេតនារបស់ខ្លួនក្នុងការធ្វើកិច្ចសហការជាមួយអង្គការនានា ដែលបានមកធ្វើសកម្មភាពក្នុងឃុំ ។ និយាយដោយឡែក ដោយបន្តកម្មវិធីរបស់អង្គការខុនសឺន សមាគមភ្នំនាងកង្រីបាន និង កំពុងធ្វើសកម្មភាព និង មានកិច្ចសហការល្អជាមួយក្រុមប្រឹក្សាឃុំតាជេសតាមរយៈគម្រោងគាំទ្រជីវភាពរស់នៅ (ជាគម្រោង សេវាកម្ម) ។ ក្នុងឆ្នាំ ២០០៦ សមាគមភ្នំនាងកង្រីបានផ្តល់ថវិកាចំនួន ៤.០០០ ដុល្លារសហរដ្ឋអាមេរិក ដល់ក្រុមប្រឹក្សាឃុំតាជេស សម្រាប់គម្រោងលើកស្ទួយជីវភាពសហគមន៍ ដែលមានរយៈពេល ខែ (ខែសីហា ដល់ ខែធ្នូ ឆ្នាំ ២០០៦) ។ គម្រោងនេះបានផ្តល់ឱ្យឃុំតាជេស ក្រោយពីក្រុមប្រឹក្សាឃុំបានដាក់សំណើគម្រោង[៣] ទៅសមាគម ភ្នំនាងកង្រី ។

ជារួម តាមរយៈគម្រោងនេះ ក្រុមប្រឹក្សាបានរៀនសូត្រ និង ទទួលបានបទពិសោធន៍ជាច្រើន ។ ក្រុមប្រឹក្សាអាចរៀបចំសំណើគម្រោង អាចមានលទ្ធភាពអនុវត្តគម្រោងឱ្យឆ្លើយតបនឹងតម្រូវការរបស់អ្នកភូមិ អាចគ្រប់គ្រងថវិកា (យកតាមប្រព័ន្ធហិរញ្ញវត្ថុរបស់សមាគមភ្នំនាងកង្រី) ដោយផ្អែកលើអនុស្សារណៈ នៃកិច្ចព្រមព្រៀងរវាង ក្រុមប្រឹក្សាឃុំ និង សមាគមភ្នំនាងកង្រី និង អាចសរសេររបាយការណ៍ ដោយមានការណែនាំពីសមាគម ។ លើសពីនេះទៀត ពីមុនមកក្រុមប្រឹក្សាឃុំពុំចេះធ្វើចំណាត់ថ្នាក់ទ្រព្យធន ដើម្បីកំណត់រកក្រុមគោលដៅ ដែលជា អ្នកក្រីក្របំផុតក្នុងភូមិឡើយ ។ ប៉ុន្តែនៅពេលដែលបានប្រឡូកការងារនេះជាមួយសមាគមភ្នំនាងកង្រី ក្រុមប្រឹក្សា ឃុំ បានយល់ដឹងអំពីរបៀបធ្វើចំណាត់ថ្នាក់ទ្រព្យធន ។ សមាជិកក្រុមប្រឹក្សាឃុំមួយរូប ដែលក្រុមប្រឹក្សាបានចាត់ឱ្យ ទទួលខុសត្រូវ និង ធ្វើសហការក្នុងការអនុវត្តគម្រោងឥណទានពូជមេគោនេះ បានមានប្រសាសន៍ថា ក្រោយពេល ធ្វើចំណាត់ទ្រព្យធនហើយ ក្រុមប្រឹក្សាបានរកឃើញ និង កំណត់ក្រុមអ្នកទទួលផល ដែលជាគ្រួសារក្រីក្របំផុតបាន ហើយគ្រួសារផ្សេងទៀតក៏យល់ព្រមតាមទាំងស្រុង ។ សមាជិក ក្រុមប្រឹក្សារូបនោះបានមានប្រសាសន៍យ៉ាងច្បាស់ថា " ឱ្យតែឃុំហ៊ានចាប់ដៃជាមួយអង្គការមិនមែនរដ្ឋាភិបាល គឺឃុំរីកចម្រើន" ។

ទន្ទឹមនឹងគ្នានេះដែរ ការអនុវត្តគម្រោងក៏បានជួបប្រទះនឹងការលំបាកដែរ ។ សមាជិកក្រុមប្រឹក្សាឃុំពីររូប ត្រូវបានប្រគល់ភារកិច្ចជាអ្នកអនុវត្តគម្រោងនេះ ដោយមានម្នាក់ជាមន្ត្រី និង ម្នាក់ទៀតជាបេឡាករ (អ្នកកាន់ លុយ) ។ គាត់បានទទួលការបណ្តុះបណ្តាលពីសមាគម ដើម្បីមានសមត្ថភាពអនុវត្តគម្រោងឱ្យទទួលបានជោគជ័យ ។

[៣] ក្នុងសំណើគម្រោងនេះរួមមានសកម្មភាព ការងារកសិកម្ម ជំនួញខ្នាតតូច ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ និង សហគមន៍ ការបញ្ជ្រាបយេនឌ័រ ការតស៊ូមតិ និង ការត្រៀមបង្ការគ្រោះមហន្តរាយ ។ គម្រោងនេះធ្វើនៅពីរភូមិ គឺភូមិអូររូង និង ភូមិ ឡពាង ។ គួរបញ្ជាក់ថា សកម្មភាពគម្រោងសំខាន់ៗ ដូចមានសរសេរក្នុងសកម្មភាពគម្រោងតូចៗរបស់សំណើគម្រោង ដូចជា គម្រោងឥណទានពូជមេគោ ធ្វើជីកំប៉ុស្ត អប់រំជំងឺអេដស៍ ។ល ។ ត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅកម្មវិធីវិនិយោគ ៣ ឆ្នាំ រំកិល ២០០៦-២០០៨ របស់ឃុំតាជេស ។

ប៉ុន្តែគាត់មានភាពមមាញឹកខ្លាំង[៤] ក្នុងនាមជាសមាជិកក្រុមប្រឹក្សាឃុំហើយដូច្នេះមិនសូវបានចុះតាមដានត្រួតពិនិត្យគម្រោងនៅតាមភូមិឱ្យបានជិតដល់ឡើយ ។ ចំណែកឯការគ្រប់គ្រងលំហូរសាច់ប្រាក់របស់ឃុំ ក្នុងគម្រោងឥណទាន ពូជមេគោ ក៏ជាការលំបាកមួយទៀតដែរ ។ ក្រោយពីមានការធ្វើសវនកម្មពីអង្គការខុនសឺន អ្នកកាន់លុយ ដែលជាសមាជិកក្រុមប្រឹក្សាត្រូវដូរមកស្មៀនឃុំវិញ ព្រោះស្មៀនជាបេឡាករឃុំ ។ដូច្នេះ នៅពេលដែលក្រុមប្រឹក្សាឃុំស្នើដកថវិកាពីសមាគមភ្នំនាងកង្រី បានហើយ ថវិកានោះត្រូវទុកនៅនឹងស្មៀនឃុំ ហើយនៅពេលដែលមន្ត្រីអនុវត្តគម្រោងរបស់ឃុំត្រូវការថវិកាចំណាយលើសកម្មភាពគម្រោងផ្សេងៗ មន្ត្រីនោះត្រូវស្នើទៅមេឃុំ ដើម្បីដកថវិកា ។ ក្រោយពីមេឃុំយល់ព្រមហើយ មន្ត្រីអនុវត្តគម្រោងនោះអាចទៅដកលុយពីស្មៀនឃុំបាន ។ គួរកត់សម្គាល់ថា ក្រោយពីក្រុមប្រឹក្សាឃុំបញ្ជូនរបាយការណ៍រីកចម្រើន និងរបាយការណ៍ហិរញ្ញវត្ថុទៅសមាគមភ្នំនាងកង្រីហើយ តាមជំហានទីមួយៗ សមាគមនឹងចេញមូលប្បទានបត្រធនាគារឱ្យទៅក្រុមប្រឹក្សាឃុំ ដើម្បីដកប្រាក់នៅធនាគារ អេស៊ីលីដា ក្នុងទីរួមខេត្តកំពង់ឆ្នាំង ។ អង្គការខុនសឺនផ្តល់យោបល់ថា គួរបើកគណនីធនាគារមួយសម្រាប់ ក្រុមប្រឹក្សាឃុំ ដើម្បីធ្វើការផ្ទេរលុយពីធនាគារក្នុងទីរួមខេត្ត ទៅធនាគារក្នុងស្រុកកំពង់ត្រឡាច ដែលស្ថិតនៅជិត ទីតាំងសាលាឃុំជាង ។ ដំណើរការដើម ក្នុងការដកប្រាក់នៅធនាគារក្នុងទីរួមខេត្ត ធ្វើឱ្យចំណាយថវិកា និងពេលវេលាច្រើន ពិសេសក្នុងការធ្វើដំណើរ ។

## ការតាមដានត្រួតពិនិត្យ និង វាយតម្លៃៈ បញ្ហាថវិកា ឬ សមត្ថភាព?

ក្រុមប្រឹក្សាឃុំបានតែងតាំងមនុស្សពីរនាក់នៅក្នុងឃុំឱ្យធ្វើជាជនបង្គោលតាមដានត្រួតពិនិត្យ និង វាយតម្លៃ ដែលម្នាក់ជាសមាជិកក្រុមប្រឹក្សា និង ម្នាក់ទៀតជាប្រជាពលរដ្ឋនៅភូមិ ( តែបានស្លាប់ទៅ ហើយ មិនទាន់មាន អ្នកជំនួស) ដើម្បីតាមដានត្រួតពិនិត្យគម្រោងទាំងអស់ដែលមាននៅក្នុងឃុំ ។ ការជ្រើសរើសនេះផ្អែកលើសមត្ថភាព និង ឆន្ទះរបស់អ្នក ដែលត្រូវគេជ្រើសរើសឱ្យធ្វើជាជនបង្គោល ។ជនបង្គោលទាំងពីររូបនេះបានទទួលការបណ្តុះបណ្តាល អំពីការតាមដានត្រួតពិនិត្យ និង វាយតម្លៃរបស់ឃុំ សង្កាត់ លើការងារអភិវឌ្ឍមូលដ្ឋានតែម្តងគត់នៅដើមអាណត្តិ ទី១ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពីអ្នកសម្របសម្រួល ហើយក្រៅពីនេះ គឺការរៀនពីបទពិសោធន៍ ។ ការងារតាមដាន ត្រួតពិនិត្យមិនមែនត្រូវការត្រឹមតែមនុស្សមានសមត្ថភាព និង ជំនាញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថវិកាគាំទ្រផង ។ ក៏ប៉ុន្តែ អ្នកសម្របសម្រួលស្រុកហាក់ដូចជារារែកក្នុងការអះអាងថា ការបន្ថែមថវិកាសម្រាប់គាំទ្រប្រតិបត្តិការ តាមដានត្រួតពិនិត្យ និង វាយតម្លៃពិតជាអាចជួយឱ្យការតាមដានត្រួតពិនិត្យ និង វាយតម្លៃទទួលបានលទ្ធផលល្អ ឬ មានប្រសិទ្ធភាព ។ លោកស្រីបាននិយាយថា *"បើតំឡើងថវិកាក៏នៅតែមិនអាចតាមដានបានទាំងអស់ដែរ ដោយសារគាត់ត្រូវការពេលវេលាសម្រាប់ជីវភាពប្រចាំថ្ងៃ"* ។ពេលវេលាសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ប្រហែលជា អាទិភាពខ្ពស់ជាង ។

---

[៤] មានសេចក្តីរាយការណ៍ខ្លះថា បញ្ហានេះគឺមកពីគាត់យល់ឃើញថា ផលប្រយោជន៍ទទួលបានពីការអនុវត្តន៍នេះមានតិច ហើយគាត់បានចំណាយពេលវេលា ដើម្បីជីវភាពរស់នៅផ្ទាល់របស់គាត់ ។

តើជនបង្គោលតែពីរនាក់អាចជួយតាមដានត្រួតពិនិត្យ និង វាយតម្លៃលើគម្រោងទាំងអស់របស់ឃុំបាន ដែរឬទេ? ជំនួសដោយជនបង្គោលតែពីរនាក់ តើក្រុមប្រឹក្សាឃុំអាចបង្កើតជាគណៈកម្មាធិការតាមដានត្រួតពិនិត្យ និង វាយតម្លៃឬទេ? ក្នុងខណៈពេលដែលពុំមានការណែនាំពីក្រសួង ឬ ពីអាជ្ញាធរខេត្ត គំនិតក្នុងការបង្កើត គណៈកម្មាធិការរបៀបនេះដោយក្រុមប្រឹក្សាឃុំ ពុំទាន់មាននៅឡើយទេ បើទោះបីជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ អនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំអាចបង្កើតគណៈកម្មាធិការនានាក៏ដោយ។ ផ្ទុយទៅវិញ ក្រុមប្រឹក្សាឃុំអាច ពិចារណាទៅលើជម្រើសផ្សេងវិញ ដូចជាការបង្កើតគណៈកម្មការអ្នកប្រើប្រាស់ ឬ អ្នកទទួលផល ដើម្បីពិនិត្យ តាមដានមើលការអនុវត្តគម្រោង។

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា ២៧**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និង ជួយកិច្ចការនានាតាមការចាំបាច់។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬ អាចយកប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

## ក្នុងការដឹកនាំ ឱ្យតែមានការព្យាយាមរបស់ក្រុមប្រឹក្សាឃុំ អ្វីៗអាចធ្វើបាន

នៅពេលដែលលោកមេឃុំបានទទួលស្គាល់ថាខ្លួនគាត់មានចំណេះដឹងតិចជាងសមាជិកក្រុមប្រឹក្សាដទៃវាបានបង្ហាញឱ្យឃើញរួចទៅហើយថា ការដឹកនាំនៅក្នុងក្រុមប្រឹក្សានេះត្រូវការយ៉ាងខ្លាំងនូវការជួយជ្រោមជ្រែងពី សំណាក់ជំទប់ទាំងពីរ សមាជិកក្រុមប្រឹក្សា និង អ្នកសម្របសម្រួល។ សមាជិកក្រុមប្រឹក្សាអាចមានយោបល់ល្អជាង និង ច្រើនជាងប្រធានក្រុមប្រឹក្សា។ យោបល់របស់សមាជិកក្រុមប្រឹក្សា ដែលមកពីគណបក្សចំរុះ អាចមិនសូវ ស៊ីសង្វាក់គ្នា ហើយគ្របដណ្តប់មកលើប្រធានក្រុមប្រឹក្សា នៅពេលមានការពិភាក្សា និង ធ្វើសេចក្តីសម្រេចក្នុង កិច្ចការណាមួយ។ ផ្ទួបផ្សំនឹងសមត្ថភាពដឹកនាំនៅមានកម្រិតរបស់ប្រធានក្រុមប្រឹក្សា ការពិភាក្សា ឬ ការជជែក វែកញែកលើកិច្ចការនានារបស់ឃុំ អាចមានច្រើនជាងលទ្ធផលជាក់ស្តែង។ ប៉ុន្តែ ការពិភាក្សាទាំងនេះ គឺជាចំណុចល្អ ក្នុងរបបប្រជាធិបតេយ្យ ដែលលោកមេឃុំបានប្រកាន់យក។ លោកស្រីជំទប់ទី១បានមានប្រសាសន៍ថា *"ឃុំតាជេស មានសំណាង ដោយសារលោកមេឃុំផ្តល់ឱកាសឱ្យយើងផ្តល់យោបល់។ គាត់មិនប្រកាន់ទេ។ ប៉ុន្តែ ភាពចន្លោះគឺ តម្លាភាព"*។ លោកមេឃុំក៏បានទទួលស្គាល់ដែរថា *"មិនមែនយើងគ្រប់គ្រងបានទាំងអស់ទេ វាតែងតែមាន ការខ្វះខាត ហើយយើងបំពេញការខ្វះចន្លោះ យើងស្តាប់គេ។ យើងជាមេ មិនមែនយើងចេះទាំងអស់ទេ។ ការចន្លោះ ប្រហោងមកពីយើង ជួនកាលយើងមិនចាប់ភ្លឹក។ ជួនកាល យើងមានបញ្ហាពីគ្រួសារបន្តិចបន្តួច"* ។

ក្នុងទិដ្ឋភាពបែបនេះ ការណែនាំ និង ការជួយតម្រង់ទិសពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ពិសេសពី អ្នកសម្របសម្រួលស្រុក អាចជួយធ្វើឱ្យការដឹកនាំ និង ការគ្រប់គ្រងនៅក្នុងឃុំតាជេសមានសភាពប្រសើរឡើង ពិសេសនៅពេលដែលលោកមេឃុំហាក់មានភាពសោះអង្គើយ ឬ មិនសូវយកចិត្តទុកដាក់ក្នុងការដឹកនាំ។ កាលពី ប៉ុន្មានខែកន្លងទៅ បន្ទាប់ពីការចូលកាន់តំណែងក្នុងក្រុមប្រឹក្សាឃុំអាណត្តិទី២ អ្នកសម្របសម្រួលស្រុកបានមាន ប្រសាសន៍ថា មានការលំបាកក្នុងការកំណត់កាលវិភាគច្បាស់លាស់ជាមួយលោកមេឃុំ ដើម្បីរៀបចំការប្រជុំមួយ ដើម្បីចាប់ផ្តើមដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ ៥ ឆ្នាំ និង កម្មវិធីវិនិយោគឃុំ។ ការកំណត់កាលវិភាគដើម្បី រៀបចំការប្រជុំម្តងៗ កម្របានសមាសភាពចូលរួមឱ្យបានច្រើនពោលគឺច្រើនតែមកមិនជុំគ្នា។ វិធីសាស្រ្តមួយរបស់ អ្នកសម្របសម្រួលស្រុក ដែលទើបផ្លាស់មកថ្មី ដើម្បីជួយឃុំតាជេសបានពីរបីខែ គឺការព្យាយាមមកសាលាឃុំ ឱ្យ បានញឹកញាប់ ដើម្បីពិភាក្សាជាមួយលោកមេឃុំអំពីការរៀបចំធ្វើផែនការអភិវឌ្ឍន៍ ២០០៧-២០១១ និង កម្មវិធី វិនិយោគឃុំឆ្នាំ ២០០៨។ អ្នកសម្របសម្រួលស្រុកបានពន្យល់លោកមេឃុំថា *"លោកមេឃុំត្រូវយកចិត្តទុកដាក់នឹង ការងារនេះ ពីព្រោះលោកមេឃុំនឹងមានតម្លៃ និង ប្រកបដោយកិត្តិយសក្នុងអាណត្តិរបស់លោកមេឃុំ "*។ ក្រោយមក លោកមេឃុំបានទទួលយកគំនិតនេះ ហើយបានកោះប្រជុំសមាជិកក្រុមប្រឹក្សា និង សមាជិកគណៈកម្មាធិការកសាង ផែនការ និង ថវិកា មកប្រជុំ។

ការដឹកនាំនៅក្នុងក្រុមប្រឹក្សាឃុំក៏ត្រូវការផងដែរនូវការព្យាយាម។ សមាជិកក្រុមប្រឹក្សាមួយរូបបាននិយាយយ៉ាងច្បាស់ថា *" ឱ្យតែមានការព្យាយាមរបស់ក្រុមប្រឹក្សាឃុំ អ្វីៗអាចធ្វើបាន "*។ ការព្យាយាមរបស់ក្រុមប្រឹក្សាឃុំ គឺពុំមែនជាការព្យាយាមរបស់លោកមេឃុំ ឬ ជំទប់ទេ។ ការដឹកនាំនេះត្រូវការភាពជាអ្នកដឹកនាំ ឆន្ទៈ និង សាមគ្គីផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ។ សមត្ថភាពរបស់អ្នកដឹកនាំ និង តម្លាភាព ក៏ចាំបាច់ដែរ។

*".... ខ្ញុំយល់ថា សមាជិកក្រុមប្រឹក្សាឃុំអាចធ្វើការជាក្រុមបាន តាមរយៈការប្រជុំក្រុមប្រឹក្សាប្រចាំខែ ការលើកយកចំណុចខ្វះខាត ឬ ការលំបាកនានា មកពិភាក្សាដើម្បីកែលម្អ ឬ ដោះស្រាយ និង ការបែងចែកតួនាទីភារកិច្ចឱ្យច្បាស់លាស់ ។ ខ្ញុំនឹងចូលរួមប្រជុំក្រុមប្រឹក្សា ហើយផ្តល់មតិ យោបល់ដល់សមាជិកក្រុមប្រឹក្សាឃុំ "* ។
*សម្ភាសជាមួយអ្នកសម្របសម្រួលស្រុក ថ្ងៃទី ១២ ខែ វិច្ឆិការ ឆ្នាំ ២០០៧ នៅទីរួមខេត្តកំពង់ឆ្នាំង ។*

# ឃុំគំរូ ឬជា ឃុំដំបូង?
# ករណីសិក្សាឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង[៥]

## ព័ត៌មានទូទៅអំពីឃុំរលាប្អៀរ

ឃុំមួយ ដែលមានឈ្មោះដូចស្រុករបស់ខ្លួន គឺឃុំរលាប្អៀរ ក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានចម្ងាយមធ្យម ពីភូមិទៅសាលាខេត្ត ១៣.១៧ គ.ម ។ ឃុំនេះមិនឆ្ងាយពីទីប្រជុំជន មានប្រជាជនរស់នៅសរុប ៧.៨៨៤ នាក់ ស្មើនឹង ១.៧៥៩ គ្រួសារ ក្នុងនោះមនុស្ស ដែលមានអាយុចាប់ពី ១៨ ឆ្នាំ ទៅ ៦០ ឆ្នាំ មានចំនួន ៤.២២៣ នាក់ (ឯកសារព័តិមានឃុំ ឆ្នាំ ២០០៦) ។ស្ថានភាពដីក្នុងឃុំរលាប្អៀរ ចែកជាពីរសណ្ឋានដាច់ពីគ្នា គឺដីវាលទំនាប គ្របដណ្តប់ ៥ ភូមិ មានប្រព័ន្ធស្រោចស្រព តែខ្វះជីជាតិ និង ដីខ្ពង់រាបគ្របដណ្តប់ ១ ភូមិ ។ ថ្វីត្បិតតែក្នុងឃុំនេះ មានប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែ (១.៧០៨ គ្រួសារ) ក៏ដោយ ក៏ជីវភាពប្រជាជនជាទូទៅមិនក្រីក្រទេ ។ ក្រៅពីធ្វើស្រែ ប្រជាជននៅមានមុខរបរបន្ទាប់បន្សំទៀត ដូចជា ធ្វើចង្អេរ ធ្វើកញ្ជ្រែង ឡើងត្នោត ។ល ។ នៅពេល ដែលគេធ្វើដំណើរកាត់ក្នុងឃុំរលាប្អៀរ ហើយធ្វើការសង្កេតនោះ គេនឹងឃើញថា ប្រជាជនក្នុងឃុំរលាប្អៀរមានផ្ទះ ប្រក់សង្កសី ហ្វីប្រូស៊ីម៉ងត៍ ប្រក់ក្បឿង និង ជាផ្ទះល្វែង ហើយមាន អគ្គិសនីប្រើប្រាស់ និង មានទូរទស្សន៍ ម៉ូតូ កង់ រឺម៉ក ទៀតផង ។

ប្រជាជនក្នុង៦ភូមិបានធ្វើដំណើរមកផ្សារដែលមានតែមួយគត់ស្ថិតក្នុងភូមិអណ្តូងស្នាយស្ថិតនៅតាមដងផ្លូវជាតិលេខ ប្រាំ ។ការធ្វើដំណើរនិងការដឹកជញ្ជូនទំនិញពីភូមិមួយទៅភូមិមួយទៀតនិងមកកាន់ផ្សារ មិនពិបាកទេដោយសារក្នុងឃុំនេះ មានផ្លូវលំក្រាលក្រួសក្រហម ដែលនៅមានសភាពល្អ ។ ដូចគ្នានឹងឃុំដទៃដែរ ឃុំនេះមានការអភិវឌ្ឍន៍ក្នុងផ្នែកហេដ្ឋារចនា សម្ព័ន្ធ ។ គម្រោងហេដ្ឋារចនាសម្ព័ន្ធ ក្នុងឃុំរលាប្អៀរ មានតិចជាងគម្រោង ធារាសាស្ត្រ ។ ប្រការនេះធ្វើឱ្យឃុំរលាប្អៀរ មានភាពខុសគ្នាពីឃុំដទៃទៀត ដែលមានគម្រោងហេដ្ឋារចនាសម្ព័ន្ធ ច្រើនជាង ដូចជា ផ្លូវលំដីស ផ្លូវក្រាលក្រួសក្រហម ដាក់លូកាត់ផ្លូវ និង សាលារៀន ។

---

[៥] ករណីសិក្សានេះសរសេរដោយលោក អ៊ឹម សុខធី សម្រាប់គំរោងគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ (CCSP) ដើម្បីផ្សព្វផ្សាយអំពីបទពិសោធន៍ និង មេរៀន ដែលក្រុមប្រឹក្សាឃុំទទួលបានកន្លងមក ទាក់ទងនឹងដំណើរការកសាងផែនការ និង ថវិកា ការអនុវត្តគម្រោង និង ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ។ ករណីសិក្សានេះផ្តោតលើគម្រោងសេវាកម្ម ដែលក្រុមប្រឹក្សាឃុំបានប្រើថវិការបស់ខ្លួន ទោះបីជាថវិកាផ្តល់ឱ្យ ដោយអង្គការ ឬ ដោយ មូលនិធិឃុំ សង្កាត់ ។ ករណីសិក្សានេះបង្ហាញអំពីស្ថានភាពជាក់ស្តែង ហើយអ្នកនិពន្ធសន្មតទទួលខុសត្រូវទាំងស្រុង ចំពោះខ្លឹមសារនៃករណីសិក្សានេះ ។ អ្នកជំនួយការស្រាវជ្រាវគឺលោក ឈឹម សុភាគ មន្ត្រីព័តិមានរបស់ CCSP ។ ករណីសិក្សានេះមិនអាច ចម្លង ទោះជាដោយផ្នែកឬទាំងមូលនោះទេ បើគ្មានការអនុញ្ញាតពីគំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ។ រក្សាសិទ្ធិ © គំរោងគាំទ្រក្រុមប្រឹក្សា ឃុំ សង្កាត់ ខែ ធ្នូ ឆ្នាំ ២០០៧ ។

ដោយសារឃុំរលាប្អៀរបាន ទទួលរងគ្រោះដោយសារភាពរាំងស្ងួត និង កង្វះទឹកធ្វើស្រែនៅមុនដើម និង នៅចុងរដូវវស្សា កាលពីឆ្នាំ ២០០៤ ហើយបន្តរហូតដល់ឆ្នាំ ២០០៦ ទើបឃុំរលាប្អៀរទទួលបានសមិទ្ធិផល ជាសំណង់ធារាសាស្ត្រយ៉ាងច្រើនដូចជា ទ្វារទឹក សំណង់ស្ទាក់ទឹក ការស្តាយប្រឡាយ ការលើកទំនប់ ។ល។ ពីមន្ទីរ ធនធានទឹក រាជរដ្ឋាភិបាល និង ក្រុមប្រឹក្សាឃុំខ្លួនឯង។ ក៏ប៉ុន្តែ សមិទ្ធិផលសំណង់ធារាសាស្ត្រទាំងនេះ នៅតែពុំអាច បំពេញសេចក្តីត្រូវការទាំងអស់ទេ។ សំណង់ធារាសាស្ត្រកើតមាននៅខាងជើង តែនៅខ្វះខាងត្បូង។

## សមាសភាពក្រុមប្រឹក្សាឃុំ និង ការដឹកនាំ

ឃុំរលាប្អៀរគឺជាឃុំមួយ ក្នុងចំណោមឃុំទាំង ៦៩ របស់ខេត្តកំពង់ឆ្នាំង មានសមាជិក ៧ រូប ក្នុងចំណោមសមាជិកក្រុមប្រឹក្សាទាំងអស់ ៤១៩ នាក់ នៅទូទាំងខេត្ត។ សមាសភាពក្រុមប្រឹក្សាឃុំមានមកពីភូមិគ្រួស ៣នាក់ ភូមិព្រៃខ្មែរ ៣នាក់ និង ភូមិអណ្តូងច្រោះ ១នាក់។ ដូច្នេះ ភូមិ៣ទៀត ពុំមានតំណាងរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាឃុំទេ។ សមាជិកក្រុមប្រឹក្សាឃុំចេញមកពីចំរុះគណបក្សនយោបាយចំនួន ៣ គឺ គណបក្សប្រជាជនកម្ពុជា គណបក្ស សមរង្ស៊ី និង គណបក្សនរោត្តមរណឫទ្ធិ ដែលជាគណបក្សទើបបង្កើតថ្មី នៅចុងឆ្នាំ ២០០៦ ហើយដែលបានជំនួស អសនៈក្រុមប្រឹក្សាឃុំមកពីគណបក្សហ៊្វុនស៊ិនប៉ិច ក្នុងអាណត្តិទី១។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺប្រធានក្រុមប្រឹក្សា អាណត្តិមុនបានក្លាយជាសមាជិកក្រុមប្រឹក្សា ហើយជំទប់ទី១ កាលពីអាណត្តិទី១ បានក្លាយជាប្រធានក្រុមប្រឹក្សា អាណត្តិទី២។ ពួកគាត់ទាំងពីរមកពីគណបក្សនយោបាយតែមួយ។

ស្មៀនឃុំឧស្សាហ៍មកសាលាឃុំ បើធៀបនឹងលោកមេឃុំ និង សមាជិកក្រុមប្រឹក្សា ក្នុងអាណត្តិទី១។ ឥឡូវនេះ លោកមេឃុំឧស្សាហ៍មកសាលាឃុំ ដោយសារទឹកចិត្តរបស់គាត់ ផ្ទួបផ្សំនឹងការជំរុញពីអ្នកពាក់ព័ន្ធផង។ លោក មេឃុំបានចាត់ចែងឱ្យសមាជិកក្រុមប្រឹក្សាឃុំទទួលភារកិច្ចក្នុងកិច្ចការជាក់លាក់ ដូចជា ការទទួលភារកិច្ចអនុវត្ត គម្រោងជាមួយសមាគមភ្នំនាងកង្រី។ ប៉ុន្តែលោកមេឃុំក្តាប់ព័ត៌មានមិនជុំទេ។ លោកមេឃុំអាចនិយាយបានភ្លាមថា ក្រុមប្រឹក្សាឃុំអាចយកបទពិសោធន៍ ដែលទទួលបានពីការអនុវត្តគម្រោងជាមួយសមាគម ទៅអនុវត្តនៅក្នុងភូមិ ដទៃក្នុងការកសាងផែនការជាមួយអ្នកក្រីក្រ។ ប៉ុន្តែលោកមិនបានដឹងអំពីរបៀប និង ដំណើរការធ្វើចំណាត់ថ្នាក់ ទ្រព្យធនឱ្យបានច្បាស់ទេ។ លោកចូលចិត្តឱ្យមានការចូលរួមមតិ ហើយបានអនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សាដែល ទទួលភារកិច្ចធ្វើការជាមួយសមាគមនិយាយជាជាងខ្លួនគាត់និយាយ ពីព្រោះគាត់ពុំបានដឹងទាំងអស់អំពីគម្រោងនោះទេ។

## លោកមេឃុំគិតប្រយោជន៍រួមជាធំ ហើយនិយាយត្រង់ៗ

លោក សោម ហុង មេឃុំរលាប្អៀរ បានមានប្រសាសន៍ថា "ខ្ញុំសម្រេចចិត្តឈរឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ ព្រោះខ្ញុំចង់បម្រើ និង លើកស្ទួយជីវភាពប្រជាពលរដ្ឋ តាមលទ្ធិប្រជាធិបតេយ្យ" ។ ជីវិត របស់លោក សោម ហុង ឆ្លងកាត់ការលំបាក ប៉ុន្តែជោគជ័យ ក្នុងលក្ខណៈជាប្រជាជនស៊ីវិលផង និង ជាទាហាន ផង។ លោក សោម ហុង មានអាយុ ៤៥ ឆ្នាំ ធ្លាប់បានបួសរៀនរយៈពេល ១ ឆ្នាំ។ គាត់គឺជាប្រជាជនរស់នៅ ក្នុងភូមិគ្រួស បានរៀនចប់អនុវិទ្យាល័យថ្នាក់ទី ៦ នៅក្នុង ឆ្នាំ ១៩៧៤ មុនពេលរបបខ្មែរក្រហមបានចូលមកដល់ ១ ឆ្នាំ។ ក្រោយពីរបបខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាចនៅឆ្នាំ ១៩៧៩ លោកបានធ្វើជាសេនាជនឃុំ។ រយៈពេល៥ឆ្នាំ ពីឆ្នាំ ១៩៨០ ដល់ ឆ្នាំ ១៩៨៤ លោកគឺជាប្រធានក្រុមសាមគ្គី ហើយ ក្រោយមកបានក្លាយជា សេនាជនឃុំវិញ ក្នុងចន្លោះឆ្នាំ ១៩៨៤ ដល់ ឆ្នាំ ១៩៨៦។ ចេញពីផ្នែកកងទ័ព លោកបានវិលត្រឡប់មកកាន់ ជីវភាពជាប្រជាជនស៊ីវិលវិញ ក្នុងនាមជាបុគ្គលិកពាណិជ្ជកម្មប្រចាំឃុំ ដែលកាលនោះលោកធ្លាប់លីស្រូវបាវ។ ចាប់ពីឆ្នាំ ១៩៨៩ រហូតដល់ឆ្នាំ ១៩៩៣ លោកគឺជាអនុប្រធានកសិកម្មឃុំ។ ចាប់ពីឆ្នាំ ១៩៩៣ រហូតដល់មុន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ឆ្នាំ ២០០២ លោកគឺជាជំទប់ទី២។ ដោយឡើងឋានៈជាបន្តបន្ទាប់ លោក បានជាប់ឆ្នោតជាជំទប់ទី១ ឃុំរលាប្អៀរ ក្នុងអាណត្តិទី១ នៃក្រុមប្រឹក្សាឃុំ ពីឆ្នាំ ២០០២ ដល់ ២០០៧។ ជោគជ័យក្នុងជីវិតរបស់លោក សោម ហុង បានបន្តទៀត នៅពេលរូបលោកបានជាប់ឆ្នោតជាថ្មីជាប្រធានក្រុមប្រឹក្សាឃុំ រលាប្អៀរ សម្រាប់រយៈពេល៥ ឆ្នាំ ២០០៧-២០១១។ តើកត្តាអ្វីខ្លះ ឬ អំណោយទានអ្វីខ្លះ ដែលធ្វើឱ្យលោក សោម ហុង ទទួលបានជោគជ័យក្នុងជីវិតរបស់គាត់? លោកបានប្រាប់ដោយទឹកមុខសប្បាយ និង ដោយឥតលាក់លៀមថា កត្តាដែលនាំឱ្យគាត់បានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ ព្រោះគាត់ចូលចិត្តនិយាយត្រង់ៗ និយាយអ្វីធ្វើហ្នឹង គាត់គិតប្រយោជន៍រួមជាធំ ហើយ ទុកប្រយោជន៍ឯកជនជាតូច ពិសេសនោះ គឺគាត់មានភាពរាក់ទាក់ និង ស្និទ្ធស្នាល ជាមួយប្រជាជន។

## ធារាសាស្ត្រសិន សឹមសេវាកម្ម

អ្វីដែលត្រូវការហាក់បីដូចជាអាទិភាពសម្រាប់ការអភិវឌ្ឍទាំងអស់សម្រាប់ឃុំរលាប្អៀរ។ លោកមេឃុំ មានបំណងចង់ឃើញការអភិវឌ្ឍលើវិស័យទាំងប្រាំ ដូចមានចែងក្នុងផែនការអភិវឌ្ឍន៍ឃុំ រយៈពេល៥ ឆ្នាំ និង កម្មវិធីវិនិយោគរំកិលបីឆ្នាំរបស់ឃុំ។ វិស័យទាំងប្រាំនោះ រួមមាន សេដ្ឋកិច្ច សង្គមកិច្ច រដ្ឋបាល និង សន្តិសុខ ធនធានធម្មជាតិ និង បរិស្ថាន និង យេនឌ័រ។ បើទោះបីជាលោកមេឃុំចង់បានច្រើនយ៉ាងដូចនេះក៏ដោយ ជាក់ស្តែង សមិទ្ធិផលហេដ្ឋារចនាសម្ព័ន្ធ ដែលជួយធ្វើឱ្យសេដ្ឋកិច្ចក្នុងឃុំមានការរីកចម្រើនបានកើតឡើងច្រើនជាងសមិទ្ធិផល ក្នុងវិស័យផ្សេងទៀត។ វាជានិន្នាការមួយកើតឡើងនៅទូទាំងប្រទេស ទន្ទឹមពេលដែលរាជរដ្ឋាភិបាលបានប្រកាស ខ្លួនឯងថាជារាជរដ្ឋាភិបាលផ្លូវថ្នល់ រាជរដ្ឋាភិបាលធារាសាស្ត្រ។

និន្នាការនេះនឹងនៅតែមានបន្តទៀត នៅក្នុងឃុំ រលាប្អៀរ ។ លោកមេឃុំអះអាងថា ក្រុមប្រឹក្សាឃុំនឹងនៅតែយកចិត្តទុកដាក់ខ្លាំងទៅលើហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវថ្នល់ និង សំណង់ធារាសាស្ត្រ ។ លោកបានមានប្រសាសន៍ថា " ខ្ញុំគិតធារាសាស្ត្រសិនសឹមទៅសេវាកម្មក្រោយ " ។ សេវាកម្មគឺជាអាទិភាពបន្ទាប់ ហើយវាអាស្រ័យលើការគាំទ្រពីសមាគមភ្នំនាងកង្រី ។ គួរបញ្ជាក់ថា សមាគមភ្នំ នាងកង្រីបានផ្តល់ថវិកាចំនួន ១.០០០ ដុល្លារសហរដ្ឋអាមេរិក ដល់ក្រុមប្រឹក្សាឃុំរលាប្អៀរ ដើម្បីអនុវត្តគម្រោងមួយ មានឈ្មោះថា "គម្រោងបង្កើនប្រាក់ចំណូលដល់គ្រួសារក្រីក្រក្នុងសហគមន៍" ។

បើតាមទស្សនៈរបស់អ្នកសម្របសម្រួលស្រុក ប្រចាំឃុំរលាប្អៀរ អាទិភាពគម្រោងសេវាកម្មស្ថិតក្នុង លំដាប់ទីបី ។ លោកស្រីសម្របសម្រួលស្រុកយល់ឃើញថា អាទិភាពរបស់ក្រុមប្រឹក្សាឃុំក្នុងអាណត្តិទី២ គួរផ្តោតលើ (១) សាងសង់ស្ពាន (២) សាងសង់សាលារៀន និង បន្ទប់សិក្សា និង (៣) បណ្តុះបណ្តាលធ្វើជីកំប៉ុស្ត ផ្សព្វផ្សាយ ការរីករាលដាលនៃជំងឺអេដស៍ ការចាក់វ៉ាក់សាំងដល់សត្វគោ និង ជ្រូក និង កិច្ចការពារបរិស្ថាន ។ លោកស្រីបាន ពន្យល់បន្ថែមអំពីការបណ្តុះបណ្តាលធ្វើជីកំប៉ុស្តថា ជីកំប៉ុស្តនឹងជួយកែប្រែគុណភាពដី ព្រោះសព្វថ្ងៃ គេបានដាក់ជី គីមីជាច្រើនទៅក្នុងដីស្រែ ។ ម្យ៉ាងវិញទៀត កសិករពិតជាត្រូវការជីកំប៉ុស្ត ព្រោះ ឃុំមានប្រព័ន្ធធារាសាស្ត្រច្រើន ហើយសម្រាប់ធ្វើស្រែ ។ ការធ្វើជីកំប៉ុស្តនឹងជួយដល់ការដាំដុះដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ។

ទស្សនៈរបស់លោកមេឃុំ និង អ្នកសម្របសម្រួលស្រុក គឺសំដៅលើហេដ្ឋារចនាសម្ព័ន្ធដូចគ្នា ។ ប៉ុន្តែ ទស្សនៈរបស់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមានទំនោរទៅរកគម្រោងសេវាកម្មនានា ដែលទាក់ទងទៅនឹងជីវភាព ផ្ទាល់របស់ប្រជាពលរដ្ឋ ។ លោកប្រធានសមាគមភ្នំនាងកង្រីពន្យល់ថា នៅពេលធ្វើកម្មវិធីវិនិយោគឃុំ ក្រុមប្រឹក្សា ឃុំពុំសូវបានលើកយកគម្រោង ដែលទាក់ទងនឹងជីវភាពផ្ទាល់របស់ប្រជាពលរដ្ឋទេ ជាឧទាហរណ៍ គម្រោងដោះស្រាយ ការខ្វះដីបង្កបង្កើនផល ខ្វះបច្ចេកទេសធ្វើកសិកម្ម ខ្វះប្រភពទឹកប្រើប្រាស់ ។ល។ ផ្ទុយទៅវិញ ក្រុមប្រឹក្សាឃុំ ច្រើនលើកយកគម្រោង ដែលទាក់ទងនឹងជីវភាពប្រយោលរបស់ប្រជាពលរដ្ឋ ដូចជា ផ្លូវ សាលារៀន ។ល។ លោក បានបន្តពន្យល់បន្ថែមថា បញ្ហានេះគឺដោយសារ (១) ក្រុមអ្នកសម្របសម្រួលមានសមត្ថភាព គិតទៅខាងផ្នែក ហេដ្ឋារចនាសម្ព័ន្ធ (២) របៀបប្រមូលព័ត៌មានអត់បានគ្រប់ជ្រុងជ្រោយដើម្បីវិភាគតម្រូវការ និង ធ្វើការឆ្លើយតប ។ លោកបានមានប្រសាសន៍បន្ថែមទាក់ទងនឹងការប្រមូលព័ត៌មានថា (១) នៅឃុំ ខ្វះព័ត៌មានសម្រាប់ការធ្វើផែនការ (២) សមត្ថភាពវិភាគព័ត៌មានរបស់ក្រុមប្រឹក្សាឃុំ និង អ្នកពាក់ព័ន្ធមានកម្រិត ជាហេតុធ្វើឱ្យការវិភាគមិនបាន ដិតដល់ ហើយមិនច្បាស់លាស់ និង (៣) ការចូលរួមក្នុងការធ្វើផែនការថ្នាក់ភូមិនៅមានកម្រិត ដែលបណ្តាលមកពី ប្រជាពលរដ្ឋខ្វះទំនុកចិត្តមកលើក្រុមប្រឹក្សាឃុំ ។ ទាំងនេះគឺជាករណីទូទៅនៅស្ទើរគ្រប់ភូមិទាំងអស់ក្នុងខេត្តកំពង់ឆ្នាំង ។

ទោះបីជាមានទស្សនៈពុំដូចគ្នាក៏ដោយ ក៏គម្រោងសេវាកម្មនឹងពុំត្រូវក្រុមប្រឹក្សាឃុំមើលរំលងឡើយ ។ ឧទាហរណ៍ ភូមិតានីស ដែលមានដីសោះកក្រោះ ដោយសារការប្រើជីគីមីច្រើននោះ អាចជាភូមិមួយ ដែលក្រុមប្រឹក្សាឃុំអាចអនុវត្តគម្រោងធ្វើរោង និង បណ្តុះបណ្តាលធ្វើជីកំប៉ុស្ត ។

ក្រុមប្រឹក្សាឃុំមានថវិកាតិច ហើយចង់បានគម្រោងច្រើន ដូចនេះ ក្រុមប្រឹក្សាឃុំត្រូវចេះបែងចែកកញ្ចប់ថវិកាដ៏មានកម្រិតនេះឱ្យបានសមស្របទៅតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែង។ លោកស្រីសម្របសម្រួលស្រុក បានផ្តល់យោបល់ថា បើសិនជាគ្មានអង្គការ ឬ មន្ទីរណាគាំទ្រគម្រោងសេវាកម្មរបស់ឃុំទេ ក្រុមប្រឹក្សាឃុំអាច ពិចារណាអំពីការយកថវិកាដែលសល់ពីការដេញថ្លៃគម្រោងហេដ្ឋារចនាសម្ព័ន្ធមកចំណាយសម្រាប់គម្រោងសេវាកម្មដែលមានអាទិភាពខ្ពស់របស់ឃុំឬទេ។ លើសពីនេះទៀត ចំពោះថវិកាអតិរេករបស់ឃុំនៅឆ្នាំមុនៗ ក្រុមប្រឹក្សាឃុំ ក៏អាចប្រើថវិកាអតិរេកនេះសម្រាប់ធ្វើគម្រោងសេវាកម្មដែរ។ តាមទិដ្ឋភាពជាក់ស្តែង មានសក្តានុពលច្រើន ដែលក្រុមប្រឹក្សាឃុំអាចលើកយកគម្រោងសេវាកម្មមកអនុវត្តនៅតាមភូមិនីមួយៗ។ប្រសិនបើបញ្ហានេះត្រូវបានដោះស្រាយមែននោះការលើកយកគម្រោងសេវាកម្មមិនបញ្ចប់ត្រឹមមានថវិកា សម្រាប់ចំណាយ ប៉ុណ្ណោះទេ ពីព្រោះក្រុមប្រឹក្សាឃុំអាចមានការលំបាកក្នុងការអនុវត្តន៍គម្រោងសេវាកម្ម ដោយខ្លួនឯង។ គំនិត និង របៀបអនុវត្តគម្រោងសេវាកម្ម គឺថ្មីសម្រាប់ក្រុមប្រឹក្សាឃុំ ហើយវាពាក់ព័ន្ធនឹងជំនាញបច្ចេកទេសផង និង របៀបតាមដានត្រួតពិនិត្យគម្រោងផង។

## ដំណើរការកសាងផែនការតាមបែបសហការ និង ការចូលរួម

ក្រុមប្រឹក្សាឃុំបានដឹងថា ក្នុងចំណោមភូមិទាំងប្រាំមួយមានតែភូមិត្រពាំងត្រាចមួយទេ ដែលមានស្ថានភាពក្រីក្រជាងគេ ហើយចង់ឱ្យសមាគមភ្នំនាងកង្រីជួយថវិកាដល់ប្រជាជនក្រីក្រទាំងអស់នៅក្នុងភូមិនេះ។ ប៉ុន្តែ ថវិកា ដ៏តិចតួចបានធ្វើឱ្យក្រុមប្រឹក្សាឃុំផ្លាស់ប្តូរ ហើយងាកមកពិភាក្សាជាមួយសមាគមដើម្បីរិះរកវិធីជួយដល់គ្រួសារ ក្រីក្រ។ ក្រោយមកទាំងក្រុមប្រឹក្សាឃុំ និង សមាគមបានធ្វើដំណើរទៅកាន់ភូមិត្រពាំងត្រាចដើម្បីធ្វើចំណាត់ថ្នាក់ ទ្រព្យធន ស្វែងរកគ្រួសារក្រីក្របំផុត ក្នុងចំណោមគ្រួសារក្រីក្រចំនួន ១១៤ គ្រួសារ។ ចំណាត់ថ្នាក់ទ្រព្យធនបានធ្វើ ឡើងដោយមានការចូលរួមពីគ្រួសារក្រីក្រក្នុងភូមិ។ មេភូមិ តាមរយៈការចង្អុលបង្ហាញពីក្រុមប្រឹក្សាឃុំ បានសម្រប សម្រួលកិច្ចការនេះ ហើយ សមាគមបានណែនាំអំពីវិធីសាស្ត្រធ្វើចំណាត់ថ្នាក់ទ្រព្យធនដល់សមាជិកក្រុមប្រឹក្សា និង គ្រួសារក្រីក្រ។ យោងតាមលក្ខណៈវិនិច្ឆ័យ ដូចជា ការពិនិត្យមើលលើទំហំដីស្រែ ទិន្នផលស្រូវ ចំនួនគោ និង ទ្រព្យសម្បត្តិផ្សេងៗក្នុងផ្ទះ ដូចជាម៉ូតូ កង់ វិទ្យុ។ល។ របស់គ្រួសារនីមួយៗ គ្រួសារ ដែលចូលរួមធ្វើចំណាត់ថ្នាក់ ទ្រព្យធន ជាចុងក្រោយ ពួកគេបានកំណត់ជ្រើសរើសបានគ្រួសារក្រីក្របំផុតចំនួន ១២ គ្រួសារ ដែលជាគ្រួសារត្រូវ ទទួលបានឥណទានសម្រាប់បង្កើនប្រាក់ចំណូល និង លើកកម្ពស់ជីវភាពរស់នៅ នៅក្នុងគម្រោងមួយ ដែលសមាគម នឹងផ្តល់ឱ្យតាមរយៈក្រុមប្រឹក្សាឃុំ។ ប៉ុន្តែ តម្រូវការ និង លទ្ធភាពបង្កើតមុខរបរ ឬ ធ្វើសកម្មភាពបង្កើត ប្រាក់ចំណូលរបស់គ្រួសារនីមួយៗពុំដូចគ្នាទេ ម្លោះហើយ ទាំងក្រុមប្រឹក្សា និង សមាគមក៏បានសម្រេចចិត្តពិគ្រោះ យោបល់ជាមួយគ្រួសារទាំងនោះ ហើយអនុញ្ញាតឱ្យពួកគេសម្រេចចិត្តដោយខ្លួនឯងថា តើត្រូវយកឥណទាន ដែល នឹងត្រូវបែងចែកឱ្យគ្រួសារនីមួយៗ ទៅទិញជ្រូក មាន់ គោមេ ចិញ្ចឹម ឬ លក់ចាប់ហួយ ។ល។ ជាលទ្ធផល គ្រួសារ ខ្លះបានយកឥណទានទៅទិញមាន់ ខ្លះយកទៅទិញជ្រូក ។ល។

ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់លើសពីនេះ គឺថា ទោះបីជាក្រុមប្រឹក្សាឃុំដឹងថា ខ្លួនមានថវិកាត្រឹម ១.០០០ ដុល្លារសហរដ្ឋអាមេរិកក៏ដោយ ក៏ក្រុមប្រឹក្សាឃុំនៅតែព្យាយាមប្រើប្រាស់កញ្ចប់ថវិកានេះឱ្យអស់លទ្ធភាពដែរ ដោយបែងចែកថវិកា ដែលនៅសល់ពីការផ្តល់ឥណទានទៅគ្រួសារទាំង១២ ឱ្យទៅគ្រួសារក្រីក្រ ២ ទៀត ។

សកម្មភាពទាក់ទងនឹងការចុះសិក្សា ដើម្បីកសាងផែនការខាងលើនេះ មានការចូលរួមពីប្រជាជនក្រីក្រ និងកិច្ចសហការជាមួយសមាគម ដែលជាលទ្ធផល ជួយក្រុមប្រឹក្សាឃុំឱ្យអាចកំណត់រកក្រុមគោលដៅជាក់លាក់បាន។ ប៉ុន្តែដំណើរការកសាងផែនការនេះ មានលក្ខណៈដោយឡែកពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ ដែលមាន ប្រជាជនចូលរួមដែរ ប៉ុន្តែមិនសូវបញ្ចេញយោបល់ឡើយ ។ នៅក្នុងដំណើរការការកសាងផែនការអភិវឌ្ឍន៍ឃុំ អ្នកក្រីក្រភាគច្រើនមកស្តាប់ ហើយអ្នកមានមិនសូវមក ។ លោកប្រធានសមាគមភ្នំនាងកង្រី បានកត់សម្គាល់ថា កន្លងមក ការធ្វើផែនការថ្នាក់ភូមិពុំសូវមានតំណាងអ្នកក្រីក្រចូលរួមទេ ទាំងនៅក្នុងការប្រជុំភូមិ ទាំងនៅក្នុង គណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំ ដែលការរៀបចំសមាសភាពធ្វើឡើង តាមការចាត់តាំងរបស់ ក្រុមប្រឹក្សាឃុំ ។

ក្រោយពីចុះសិក្សារួច ក្រុមប្រឹក្សាឃុំបានលើកគម្រោងនេះទៅដាក់ក្នុងកម្មវិធីវិនិយោគរំកិល៣ឆ្នាំ២០០៦-២០០៨ ហើយធ្វើសំណើគម្រោងទៅសមាគម ។

## ប្រព័ន្ធថវិកាធ្វើឱ្យមានការលំបាក

ខុសពីឃុំដទៃទៀតនៅក្នុងខេត្ត ឃុំរលាប្អៀរគឺជាឃុំដំបូងគេ ដែលបានយកថវិកា ដែលក្រុមប្រឹក្សាឃុំទទួល បានទៅដាក់បញ្ចូលទៅក្នុងគណនីឃុំ នៅរតនាគារខេត្ត ។ ចំណុចខុសមួយទៀត ប្រហែលដោយសារវាជាថវិកា សម្រាប់ចំណាយលើគម្រោងសេវាកម្ម ហើយអនុវត្តដោយក្រុមប្រឹក្សាឃុំ ។ តើឃុំរលាប្អៀរគឺជាឃុំគំរូឬទេ? [6]

ឥឡូវនេះ គេអាចនិយាយបានថា ឃុំរលាប្អៀរគឺជាឃុំសាកល្បង ដែលបានទទួលថវិកាពីអង្គការមិនមែន រដ្ឋាភិបាល ហើយប្រើប្រព័ន្ធហិរញ្ញវត្ថុឃុំ។ មិនតែប៉ុណ្ណោះ ឃុំរលាប្អៀរក៏ទំនងជាឃុំដំបូងគេដែរ ដែលអនុវត្តន៍ គម្រោងសេវាកម្មដោយថវិការបស់ខ្លួន។ តាំងពីឆ្នាំ ២០០៦ ឃុំរលាប្អៀរបានដាក់សំណើគម្រោង "គម្រោងបង្កើន ប្រាក់ចំណូលដល់គ្រួសារក្រីក្រក្នុងសហគមន៍ " សម្រាប់អនុវត្តពីខែ កញ្ញា ដល់ខែ ធ្នូ ឆ្នាំ ២០០៦ ទៅសមាគម ភ្នំនាងកង្រី ដែលរាយលម្អិតអំពី

[6] កន្លងមក ថវិកាឃុំភាគច្រើន ដែលដកចេញពីរតនាគារខេត្ត គឺជាថវិកាបានមកពីមូលនិធិឃុំ សង្កាត់ ហើយអនុវត្តទៅលើ គម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ជាធម្មតា ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធនេះ ក្រុមប្រឹក្សាឃុំបានចុះកិច្ចសន្យាទៅឱ្យអ្នកទទួលការ ជាអ្នករ៉ាប់រងធ្វើ ហើយក្រុមប្រឹក្សាឃុំគ្រាន់តែជាគណៈកម្មការគ្រប់គ្រងគម្រោង នៅពេលអនុវត្តគម្រោង ហើយជាគណៈកម្មការ លទ្ធកម្ម នៅពេលដេញថ្លៃគម្រោង។ គួរបញ្ជាក់ថា ជាទូទៅគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត កំណត់លក្ខណៈសម្បត្តិអ្នកទទួលការឱ្យចូលរួមក្នុងដំណើរការដេញថ្លៃ និង ជាអ្នករៀបចំពិធីដេញថ្លៃ នៅថ្នាក់ស្រុក។

ការចំណាយថវិកាគិតជាដុល្លារសហរដ្ឋអាមេរិក។ នៅពេលដែល ក្រុមប្រឹក្សាឃុំ និង សមាគមបានយល់ព្រមឱ្យយកថវិកា ១.០០០ ដុល្លារសហរដ្ឋអាមេរិក ទៅដាក់ក្នុងគណនីឃុំ នៃរតនាគារខេត្ត បញ្ហា ស្មុគស្មាញជាច្រើនបានកើតឡើងទាក់ទងនឹងការរៀបចំថវិកា និង ការដកថវិកាចំណាយ។ បញ្ហាស្មុគស្មាញនេះ តម្រូវឱ្យមានការកែតម្រូវថវិកាជាច្រើនលើក រហូតទាល់តែមកដល់ខែសីហា ឆ្នាំ២០០៧ ទើបក្រុមប្រឹក្សាឃុំ សម្រេចបាននូវការកែតម្រូវថវិកាចុងក្រោយ (កែតម្រូវលើកទី៣)។

ការធ្វើថវិកាកែតម្រូវនេះ តម្រូវឱ្យមានការកែប្រែអនុស្សារណៈរវាងក្រុមប្រឹក្សាឃុំ និង សមាគមផងដែរ។ ការកែតម្រូវធ្វើឡើងដោយសារប្រព័ន្ធហិរញ្ញវត្ថុរបស់សមាគមមិនដូចគ្នា ឬ ស៊ីសង្វាក់គ្នានឹងប្រព័ន្ធ ហិរញ្ញវត្ថុឃុំ។ ទី១ ថវិកាក្នុងសំណើគម្រោង គិតជាដុល្លារ ហើយថវិកាសម្រាប់គណនីឃុំគិតជារៀល។ និង ទី២ ខ្ទង់ចំណាយ និង ទំហំចំណាយក្នុងសំណើគម្រោង មិនដូចគ្នា ឬ ក្នុងករណីខ្លះ អត់មានក្នុងខ្ទង់ចំណាយ និង ទំហំចំណាយក្នុងប្រព័ន្ធ ហិរញ្ញវត្ថុឃុំ។ ការសម្រួលខ្ទង់ចំណាយ និង ទំហំចំណាយពីគម្រោងថវិកាក្នុងសំណើគម្រោង ឱ្យស្របគ្នានឹងប្រព័ន្ធ ហិរញ្ញវត្ថុឃុំ ទាមទារការពិភាក្សា និង ការសម្របសម្រួលរវាងសមាគម ក្រុមប្រឹក្សាឃុំ និង ផ្នែកហិរញ្ញវត្ថុ និង ផ្នែករដ្ឋបាលមូលដ្ឋាននៃគណៈកម្មាធិការប្រតិបត្តិខេត្ត។ ការពិភាក្សា និង ការសម្របសម្រួលនេះ បានអូសបន្លាយ ពេលជាច្រើន ហើយជាលទ្ធផល គម្រោងសេវាកម្មរបស់ក្រុមប្រឹក្សាឃុំពុំអាចអនុវត្តបាន ដូចផែនការ (អនុវត្តបាន ត្រឹម៥០% គិតត្រឹមខែវិច្ឆិការ ឆ្នាំ ២០០៧) ដែល គេបានគ្រោងថាត្រូវបញ្ចប់នៅចុងឆ្នាំ ២០០៦។ ហេតុដូច្នេះ ក្រុមប្រឹក្សាឃុំបានយកថវិកា ដែលមិនបានអនុវត្តក្នុងឆ្នាំ ២០០៦ ជាថវិកាអតិរេកសម្រាប់ឆ្នាំ ២០០៧ ដើម្បីអនុវត្ត គម្រោងសេវាកម្មនេះ។

ប៉ុន្តែ បញ្ហាលំបាកមិនទាន់ត្រូវបានដោះស្រាយ ត្រឹមការកែតម្រូវថវិកាបានចប់សព្វគ្រប់ឡើយ។ នីតិវិធីដកថវិកាសម្រាប់ចំណាយលើសកម្មភាព ក៏បានបង្កឱ្យមានការលំបាកដែរ។ ឯកសារភ្ជាប់ជាច្រើនត្រូវតែមានឱ្យ គ្រប់គ្រាន់ជាចាំចាំដើម្បីដកលុយពីរតនាគារខេត្តបាន បើពុំនោះទេ អ្នកទៅដកថវិកា ត្រូវធ្វើដំណើរទៅមកពីសាលាឃុំ ទៅទីរួមខេត្តច្រើនដង ដើម្បីបំពេញបង្គ្រប់ឯកសារភ្ជាប់ ហើយប្រការនេះនឹងធ្វើឱ្យចំណាយថវិកា និង ពេលវេលា ច្រើន ព្រមទាំងអាចនាំឱ្យកកស្ទះ ឬ ពន្យារពេលទូទាត់ថវិកា និង ការពន្យារពេលការអនុវត្តនី សកម្មភាពគម្រោងផង។ ឧទាហរណ៍ ការរៀបចំការប្រជុំមួយត្រូវមានកំណត់ហេតុ វិក័យបត្រចំណាយ និង បញ្ជីវត្តមាន ដែលចំនួន អ្នកចូលរួម ត្រូវឱ្យស្របគ្នានឹងទំហំចំណាយសម្រាប់អាហារសំរ៉ន់ ភ្ជាប់មកជាមួយ។ បុគ្គលិករបស់សមាគម ភ្នំនាងកង្រីមួយរូបបាននិយាយថា នីតិវិធីនេះតឹងរឹង ហើយមិនងាយបត់បែន ព្រោះអ្វីៗទាំងអស់ត្រូវតែអនុវត្តតាម ផែនការថវិកាលម្អិត។ ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីសមាគមបានបង្ហាញអំពីការយល់ឃើញរបស់លោកថា ការរៀបចំបង្គ្រប់ឯកសារភ្ជាប់មិនសូវមានតម្លាភាពទេ វាហាក់ដូចជាកុហកពីព្រោះគេអាចរៀបចំឯកសារ (ដែល តាមពិតវាមិនបានឆ្លុះបញ្ចាំងទៅនឹងការចំណាយជាក់ស្តែងទាំងស្រុង) ឱ្យបានត្រឹមត្រូវតាមក្រិត្យក្រមហិរញ្ញវត្ថុរបស់ ឃុំ។

ម្យ៉ាងវិញទៀត របៀបធ្វើលទ្ធកម្មក៏បានបង្កឱ្យមានការលំបាកផងដែរ ដោយសារវាអាចមានការលំបាក ក្នុងការធ្វើសម្រង់តម្លៃទំនិញ (ឧទាហរណ៍ ចំពោះគោ ឬ មុខទំនិញផ្សេងៗ ដែលមានតម្លៃចាប់ពី ២០០.០០០រៀល ឡើងទៅ) មុននឹងសម្រេចទិញ។ ដោយទំនងជាមានទស្សនៈប្រហែលគ្នា អ្នកសម្របសម្រួលស្រុកយល់ថា នីតិវិធី លទ្ធកម្មអាចធ្វើឱ្យមានការយឺតយ៉ាវក្នុងការអនុវត្តគម្រោង ហើយបានមានប្រសាសន៍បន្ថែមថា ការអនុវត្តថវិកា តាមប្រព័ន្ធហិរញ្ញវត្ថុឃុំមានភាពងាយស្រួលជាង។ ទោះបីយ៉ាងណាក៏ដោយ បើមិនតិចក៏ច្រើន ការសម្របសម្រួល ក្នុងការអនុវត្តថវិកាពីប្រព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុឃុំ ពិតជាបានបង្កឱ្យមាន ការលំបាកសម្រាប់ការអនុវត្ត និង មានផលប៉ះពាល់មកលើប្រសិទ្ធភាពគម្រោង។

## ប្រព័ន្ធតាមដានត្រួតពិនិត្យត្រូវយកចិត្តដាក់ខ្លាំងនៅពេលអនាគត

ដូចគ្នានឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធដែរ ក្រុមប្រឹក្សាឃុំបានចាត់ឱ្យមានជនបង្គោលដើម្បីតាមដានត្រួតពិនិត្យគម្រោងសេវាកម្មមួយនេះ។ ក្រុមប្រឹក្សាឃុំបានគ្រោងថវិកាឧបត្ថម្ភសម្រាប់ការតាមដានត្រួតពិនិត្យទៅក្នុងគម្រោងសំណើរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សាឃុំ ដែលក៏ជាជនបង្គោលតាមដានត្រួតពិនិត្យផងនោះ បានមានប្រសាសន៍ថា *"ថវិកាឧបត្ថម្ភនេះគឺមិនសមស្របសម្រាប់ការចំណាយលើសកម្មភាពតាមដានត្រួតពិនិត្យឡើយ ។ការធ្វើដំណើរទៅទីតាំងគម្រោងចំណាយអស់សាំងមួយលីត្រ។ ពេលខ្លះ ខ្ញុំបានដកលុយផ្ទាល់ខ្លួន"*។ លោកសមាជិកក្រុមប្រឹក្សា បានបន្តថា ប្រសិទ្ធភាពក្នុងការតាមដានត្រួតពិនិត្យផ្សារភ្ជាប់នឹងឆន្ទៈ មិនមែនត្រឹមតែថវិកាឧបត្ថម្ភប៉ុណ្ណោះទេ។

នៅក្នុងឃុំរលាប្អៀរនេះ មានជនបង្គោលតាមដានត្រួតពិនិត្យសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធផង និង គម្រោងសេវាកម្មផង។ ដោយសារគម្រោងនៅក្នុងឃុំមានច្រើន ហើយអាចមានទំនោរកើនឡើងចំពោះគម្រោង សេវាកម្ម ជនបង្គោលតាមដានត្រួតពិនិត្យនឹងត្រូវយល់និងចេះតាមដានត្រួតពិនិត្យគម្រោងទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្ម។ ប៉ុន្តែសមាសភាពជនបង្គោលមានគ្នាតិច (ជាទូទៅពីរនាក់ក្នុងមួយឃុំ)។ ប្រសិនបើគេអាច រៀបចំជាគណៈកម្មាធិការតាមដានត្រួតពិនិត្យ នោះការតាមដានត្រួតពិនិត្យអាចនឹងមានភាពងាយស្រួល ព្រោះមាន គ្នាច្រើន ហើយអាចជួយគ្នាបាន។ គណៈកម្មាធិការនេះគួរមានសមាសភាពមកពីខាងក្រៅផង ។ ក៏ប៉ុន្តែ សមាសភាពច្រើនអាចនាំឱ្យមានផលវិបាកទៅវិញ។ ពីព្រោះនៅក្នុងក្រុមមួយ ម្នាក់ៗគិតថា អ្នកផ្សេងទៀតនឹងធ្វើ កិច្ចការនោះ ហើយមិនមានអារម្មណ៍ថា ខ្លួនមានការទទួលខុសត្រូវឡើយ ដូចជាពាក្យចាស់ពោលថា "គ្នាច្រើន អន្សមខ្លោច" ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រាទី ៦៧

ក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យ និង វាយតម្លៃ ផែនការ កម្មវិធី គម្រោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយ ដែលខ្លួនបានជ្រើសរើស ។

## ព័ត៌មានអំពីអ្នកទទួលផលគម្រោង

អ្នកស្រី **ប៉ែន សម្ផស្ស** អ្នកភូមិត្រពាំងត្រាច បានមានប្រសាសន៍ថា

*"ខ្ញុំមានអារម្មណ៍ត្រេកអរ ដោយគ្រួសារខ្ញុំបានទទួលឥណទានកូនជ្រូកចំនួន១ក្បាល"* ។

ប្រជាជនក្រីក្រក្នុងភូមិត្រពាំងត្រាចគឺជាក្រុមគោលដៅដែលក្រុមប្រឹក្សាឃុំរលាប្អៀរ និងសមាគមភ្នំនាងកង្រី បានសហការគ្នាធ្វើចំណាត់ថ្នាក់ទ្រព្យធន ដើម្បីកំណត់រកអ្នកក្រីក្របំផុតឱ្យចូលរួមស្ម័គ្រចិត្ត ក្នុងគម្រោងបង្កើនប្រាក់ចំណូលដល់គ្រួសារក្រីក្រក្នុងសហគមន៍ ។ ក្នុងទឹកប្រាក់ចំនួន ១.000ដុល្លារសហរដ្ឋអាមេរិក ក្រុមប្រឹក្សាឃុំបានប្រើប្រាស់ធនធាន ដ៏មានកម្រិតនេះ

ដើម្បីបែងចែកទៅឱ្យគ្រួសារក្រីក្រឱ្យមានប្រសិទ្ធភាពខ្ពស់ តាមដែលអាចធ្វើបាន ដោយផ្អែកលើតម្រូវការជាក់ស្តែងរបស់គ្រួសារក្រីក្រនីមួយៗ ។ ដោយសារតម្រូវការរបស់ពួកគេមិនដូចគ្នា ហើយអាស្រ័យលើជំនាញមានស្រាប់ របស់ពួកគេ ក្រុមប្រឹក្សាឃុំបានសម្រេចផ្តល់ឥណទានដល់គ្រួសារក្រីក្រ ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ ។ ដូច្នេះ ហើយបានជាគ្រួសារក្រីក្រទាំងនោះបានទទួលឥណទានខុសៗគ្នាសម្រាប់ការប្រកបមុខរបរ ។ គ្រួសារខ្លះបានទទួលឥណទាន សម្រាប់ចិញ្ចឹមជ្រូក ខ្លះចិញ្ចឹមមាន់ ខ្លះចិញ្ចឹមគោមេ ខ្លះលក់ចាប់ហួយ និង ខ្លះទៀតទទួលបានកង់សម្រាប់រត់ឌុបឥវ៉ាន់ ។

អ្នកស្រី **ប៉ែន សម្ផស្ស** ក្នុងភូមិត្រពាំងត្រាច បានមានប្រសាសន៍ដោយទឹកមុខញញឹមថា គាត់មានអារម្មណ៍ត្រេកអរ ដោយគ្រួសាររបស់គាត់បានទទួលឥណទានកូនជ្រូកចំនួន១ក្បាល ។ គាត់បានឮដំណឹងនេះពីស្វាមីរបស់គាត់ ដែលបានដឹងពី មេភូមិត្រពាំងត្រាច ។ ពួកគាត់ទាំងពីរបានពិភាក្សាគ្នាអំពីថាតើគួរយកឥណទានដើម្បីទិញជ្រូកចិញ្ចឹមឬយ៉ាងណា ។ ក្រោយពីបានពិភាក្សារួច គ្រួសារគាត់បានសម្រេចចិត្តយកឥណទានដើម្បីទិញជ្រូកចិញ្ចឹម ។ គ្រួសារគាត់គឺជាគ្រួសារពីរបន្ថែម ក្រោយគេ ដែលបានទទួលនូវការគិតគូរយ៉ាងខ្លាំងពីសំណាក់ក្រុមប្រឹក្សាឃុំ ។ តាមពិតទៅ គ្រួសារគាត់មិនមែនជាគ្រួសារ ដែលស្ថិតក្នុងបញ្ជីគ្រួសារក្រីក្រដំបូង ដែលត្រូវទទួលឥណទានទេ ប៉ុន្តែដោយសារថវិកាសម្រាប់ផ្តល់ឥណទាននៅសល់ ហើយក្រុមប្រឹក្សាឃុំចង់ប្រើប្រាស់ធនធានដែលមានកម្រិតនេះ ឱ្យអស់លទ្ធភាព ទើបក្រុមប្រឹក្សាឃុំបានសម្រេចយក ថវិកាដែលនៅសល់នេះ ផ្តល់ឱ្យគ្រួសារក្រីក្រពីរបន្ថែមទៀត ។

គ្រួសាររបស់ស្ត្រីរូបនេះ បានទទួលប្រាក់ចំនួន ១២៤.៨00 រៀល សម្រាប់ទិញកូនជ្រូក១ក្បាល ប៉ុន្តែ ដោយសារ ការយឺតយ៉ាវនៅពេលគាត់ទៅទិញ តម្លៃកូនជ្រូកបានឡើងថ្លៃដល់ ១៦0.000 រៀល ។ ហេតុនេះ គាត់ចាំបាច់ត្រូវ បន្ថែមលុយរបស់គាត់ដើម្បីទិញកូនជ្រូកនេះ ។ ក៏ប៉ុន្តែ គាត់ចង់បានកូនជ្រូកពីរក្បាល ។ ហេតុនេះ គាត់ត្រូវខ្ចីលុយគេ បន្ថែមទៀត ដើម្បីទិញកូនជ្រូកមួយទៀតមកចិញ្ចឹម ដើម្បីកាត់បន្ថយការចំណាយលើចំណីជ្រូក ។គាត់បាននិយាយក្នុងទឹកមុខធម្មតាថាបើគាត់ចិញ្ចឹមជ្រូកតែមួយក្បាលនោះគាត់មិនសង្ឃឹមថាចំណេញច្រើនទេ ព្រោះចំណីជ្រូកឡើងថ្លៃ ។ គាត់បានបន្ថែម តាំងពីគាត់បានទទួលឥណទានមក ប្រហែលពីរ បី ខែនេះ គាត់បានឃើញសមាជិកក្រុមប្រឹក្សាឃុំមកពីរ បី ដងដែរ ប៉ុន្តែមិនបាននិយាយច្រើនទេ ។

# ត្រូវការអ្នកដឹកនាំខ្លាំង ឬ ប្រព័ន្ធខ្លាំង? ករណីសិក្សាឃុំខ្នារពោធិ៍ ខេត្តសៀមរាប[៧]

## ស្ថានភាពឃុំ

កូនឡានមួយបានធ្វើដំណើរឆ្លងកាត់ផ្សារ អង្រ្គង ដែលនៅជាប់ផ្លូវជាតិលេខ៦ ហើយ បត់ចូល តាមផ្លូវលំក្រាលក្រួសក្រហម។ មុនទៅដល់សាលាឃុំ ស្ថានភាពផ្លូវនៅមានលក្ខណៈល្អ ប៉ុន្តែចូលដល់ក្នុង ភូមិសាស្រ្តឃុំខ្នារពោធិ៍ ផ្លូវលំមានសភាពអាក្រក់ជាង ។ការធ្វើដំណើរចំណាយពេលអស់ជិត១ម៉ោងទើបមកដល់សាលាឃុំខ្នារពោធិ៍ដែលមានសភាពស្ងាត់ ហើយ មិនសូវមានមនុស្សមកជួបជុំគ្នាឡើយ ។ នៅលើក្តារ ខៀន ដែលគេព្យួរជាប់ជញ្ជាំងសាលាឃុំ គេបាន សរសេរអក្សរថា *"ថ្ងៃទី ១៥-១១-០៧ ភ្ញៀវសមាគម មិត្តអ្នកត្រួសត្រាយ មកទស្សនកិច្ចឃុំខ្នារពោធិ៍"* និង ម្ខាងទៀតសរសេរថា *"ថ្ងៃទី ១៥-១១-០៧ លោក មេឃុំទៅសិក្ខាសាលានៅវត្តសំឡោង"* ។ ដូច្នេះ ភ្ញៀវ សមាគមមិត្តអ្នកត្រួសត្រាយពុំបានជួបលោកមេឃុំទេ ។

ឃុំខ្នារពោធិ៍បានបំបែកចេញពីឃុំចាន់សរ នៅ ឆ្នាំ ១៩៨៦ មានចម្ងាយប្រមាណ ២៤ គ.ម ពីទីរួម ស្រុកសូទ្រនិគម មានទីតាំងស្ថិតនៅខាងជើងផ្សារ អង្រ្គង ចម្ងាយប្រមាណ ៨ គ.ម ។ ឃុំខ្នារពោធិ៍មាន ភូមិ៨ គឺភូមិឈូក បុស្ស ដីរឆ្លង សំបាត សំរោង  បុស្សធំ រំដេង និង ជប់ ។ ឃុំនេះមានផ្ទៃដីសរុប ៥៤ គ.ម២ ភាគច្រើនគ្របដណ្តប់ដោយដីស្រែ និង ដី សហគមន៍ ហើយក្រៅពីនេះគឺដីចំការ និង ដីលំនៅដ្ឋាន ។ ប្រជាពលរដ្ឋប្រមាណ ៨៥% នៃ ៥.២៤៥ នាក់ ស្មើនឹង ៨៤៦ គ្រួសារ ធ្វើស្រែចំការ ផ្គួបផ្សំនឹងរបរ បន្ទាប់បន្សំ ដូចជាដាំបន្លែ ចិញ្ចឹមសត្វ ។ល។ ក្នុងឃុំ នេះមានប្រព័ន្ធធារាសាស្រ្ត និង ប្រភពទឹកសម្រាប់ ប្រើប្រាស់នៅ៥ភូមិ ហើយគ្រួសារនីមួយៗមានគោ ច្រើនជាងមួយក្បាល ។ ជារឿយៗ ប្រជាពលរដ្ឋតែង ជួបប្រទះបញ្ហាខ្វះស្បៀងសម្រាប់ហូបចុក ដែលបណ្តាល មកពីភាពរាំងស្ងួត ចំណេះដឹងផ្នែកបច្ចេកទេសកសិកម្ម ដំណាំស្រូវ និង ការជ្រើសរើសពូជនៅមានកម្រិត ។ ស្ថានភាពនេះ បានបង្ហាញថាជីវភាពរបស់ប្រជាពលរដ្ឋ នៅជួបប្រទះការលំបាក ។

---

[៧] ករណីសិក្សានេះសរសេរដោយលោក អ៊ឹម សុខធី សម្រាប់ គំរោងគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ (CCSP) ដើម្បីផ្សព្វផ្សាយអំពី បទពិសោធន៍ និង មេរៀន ដែលក្រុមប្រឹក្សាឃុំទទួលបានកន្លងមក ទាក់ទងនឹងដំណើរការកសាងផែនការ និង ថវិកា ការអនុវត្ត គម្រោង និង ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ។ ករណីសិក្សា នេះផ្តោតលើគម្រោងសេវាកម្ម ដែលក្រុមប្រឹក្សាឃុំ បានប្រើថវិកា របស់ខ្លួន ទោះបីជាថវិកាផ្តល់ឱ្យដោយអង្គការ ឬ ដោយ មូលនិធិឃុំ សង្កាត់ ។ករណីសិក្សានេះបង្ហាញអំពីស្ថានភាពជាក់ស្តែង ហើយ អ្នកនិពន្ធសន្មតទទួលខុសត្រូវទាំងស្រុង ចំពោះខ្លឹមសារនៃករណី សិក្សានេះ ។ អ្នកជំនួយការស្រាវជ្រាវគឺលោក ឈឹម សុភាគ មន្រ្តីព័ត៌មានរបស់ CCSP ។ ករណីសិក្សានេះមិនអាចត្រូវបានចម្លង ទោះជាដោយផ្នែកឬទាំងមូលនោះទេ បើគ្មានការអនុញ្ញាតពីគំរោង គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ។ រក្សាសិទ្ធិ © គំរោងគាំទ្រក្រុមប្រឹក្សា ឃុំ សង្កាត់ ខែធ្នូ ឆ្នាំ២០០៧ ។

ក៏ប៉ុន្តែ តាមការពិត ស្ថានភាពជាក់ស្តែង នៅក្នុងឃុំនេះ មានការវិវត្តន៍។ ប្រជាពលរដ្ឋជាច្រើន ចាប់ផ្តើមមានជីវភាពធូរធារ មានទ្រព្យសម្បត្តិល្អៗ និង ច្រើនជាងមុន។ ប្រជាពលរដ្ឋបានលក់ដីរបស់ខ្លួន ហើយក្នុងពេលបច្ចុប្បន្ននេះ ទំនាស់ដីធ្លីបានកើតឡើង យ៉ាងច្រើន។ លោកជំទប់ទី២បានអះអាងថា មានពាក្យបណ្តឹងយ៉ាងតិច៥ ក្នុង១ខែ បានបញ្ជូនមកសាលាឃុំ ដែលភាគច្រើនពាក់ព័ន្ធនឹងទំនាស់ព្រំប្រទល់ ការដាក់បញ្ចាំ និង ការដណ្តើមកេរ្តិ៍មរតក នៅលើដីស្រែ និង ដីចំការ។

អង្គការ ដែលធ្វើសកម្មភាពក្នុងឃុំខ្នាពោធិ៍ មានមិនច្រើនប៉ុន្មានទេ ដូចជាអង្គការកសិកម្ម និង ស្បៀង (FAO) អេកូហ្សូន អង្គការជនពិការអង្គរ និង សមាគមមិត្តអ្នកត្រួសត្រាយ។ អង្គការខ្លះបានជួយ គម្រោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ហើយ ខ្លះទៀតបាន ជួយគម្រោងសេវាកម្ម។ ដោយឡែក យុទ្ធសាស្ត្ររបស់ សមាគមមិត្តអ្នកត្រួសត្រាយអាចប្រែប្រួលដោយ បង្វែរពីការជួយលើគម្រោងសេវាកម្ម ទៅគម្រោង ហេដ្ឋារចនាសម្ព័ន្ធវិញម្តង។ ស្របគ្នានេះដែរ មន្ទីរនានាជុំវិញខេត្ត តាមរយៈមូលនិធិវិនិយោគខេត្ត ក៏មាន គម្រោងរបស់ខ្លួនអនុវត្តនៅតាមឃុំដែរ។ ដូច្នេះ ទោះក្នុងពេលបច្ចុប្បន្នក្តី និង ពីពេលនេះទៅមុខក្តី ទាំងក្រុមប្រឹក្សាឃុំ និងអង្គការមិនមែនរដ្ឋាភិបាល មានគម្រោងហេដ្ឋារចនាសម្ព័ន្ធផង និង សេវាកម្មផង។ តើគម្រោងរបស់ក្រុមប្រឹក្សា និងគម្រោងរបស់អង្គការ និងស្ថាប័នផ្សេងៗអាចបំពេញឱ្យគ្នាបានយ៉ាងដូចម្តេច?

## អាណត្តិថ្មី តែមេឃុំចាស់នៅដឹកនាំដដែល

លោកមេឃុំធ្លាប់ជាមេឃុំនៅអាណត្តិទី១។ នៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ នៅក្នុងអាណត្តិទី២ គាត់ត្រូវបានដាក់ឱ្យស្ថិតនៅលេខរៀងទីពីរ នៅក្នុងបញ្ជីបោះឆ្នោតរបស់គណបក្សប្រជាជន កម្ពុជា។ គាត់បានជាប់ឆ្នោតជាជំទប់ទី១វិញ។ក្រោយពីរយៈពេលទើបបានពីរបីខែនៃការប្រកាសសុពលភាពក្រុមប្រឹក្សាឃុំអាណត្តិទី២ ស្រាប់តែលោកមេឃុំ ដែលទើបចូលកាន់តំណែងថ្មី បានស្លាប់។ ដូច្នេះ លោកជំទប់ទី១ ដែលបានធ្លាក់ពីតំណែងមេឃុំ ក្នុង អាណត្តិទី១ បានចូលកាន់តំណែងជាមេឃុំម្តងទៀត នៅអាណត្តិទី២។ លោកមេឃុំមានជីវភាពធូរធារជាង សមាជិកក្រុមប្រឹក្សាដទៃ។ ប៉ុន្តែ ខុសពីលោកមេឃុំ សមាជិកក្រុមប្រឹក្សា ដែលមានជីវភាពអន់ជាង មាន ឆន្ទះ និង ឧស្សាហ៍មកសាលាឃុំ។

មានសេចក្តីរាយការណ៍ថា លោកមេឃុំមិន សូវមកសាលាឃុំទេ ហើយគាត់ក៏មិនសូវធ្វើអ្វីឱ្យខុស ឆ្គងជាមួយប្រជាពលរដ្ឋដែរ។ ដូច្នេះ សមាជិក ក្រុមប្រឹក្សាខ្លះទៀតក៏មិនសូវមក ហើយ បញ្ហា ឬ ទំនាស់ក៏មិនមានកើតឡើង នៅក្នុងជួរក្រុមប្រឹក្សាឃុំ ដែរ។ សមាជិកក្រុមប្រឹក្សាចាស់ៗមិនសូវពូកែ ដូចគ្នា នឹងលោកមេឃុំដែរ ហើយសមាជិកក្រុមប្រឹក្សា ដែលទើបជាប់ឆ្នោតថ្មីពីរនាក់ កំពុងរៀនសូត្រអំពីការងារ ក្រុមប្រឹក្សាឃុំ។ ដោយឡែក ស្មៀនឃុំ និង អ្នកសម្របសម្រួលស្រុក ក៏ទើបមកបម្រើការងារថ្មីដែរ។

សាមគ្គីផ្ទៃក្នុងមើលមួយភ្លែតមានភាពរលូនប៉ុន្តែវាហាក់បីដូចជាមិនមែនធ្វើការជាក្រុមដោយសារសមាជិកក្រុមប្រឹក្សាមិនសូវបានជួបជុំគ្នា។ សមាជិក ក្រុមប្រឹក្សា ដែលមានអាយុច្រើន ហើយមិនសូវបាន ជួបគ្នា ឬ ពិភាក្សាគ្នាជាមួយមេឃុំ ធ្វើឱ្យអ្នកក្រោមបង្គាប់មានអារម្មណ៍ស្ថិតនៅឆ្ងាយពីការងារហើយអាចធ្វើឱ្យការងារមានភាពមិនសូវច្បាស់ ។យ៉ាងណាមិញ សមាជិកក្រុមប្រឹក្សាមានសមាសភាព មកពីគណបក្ស ផ្សេងគ្នា ហើយបើមិនតិចក៏ច្រើន មានទំនោរទៅរក និន្នាការគណបក្សនយោបាយ។ មានសេចក្តីរាយការណ៍ ខ្លះបញ្ជាក់ថា សមាជិកក្រុមប្រឹក្សា ព្រមទាំងមេឃុំផង ទទួលឥទ្ធិពលនយោបាយពីគណបក្សរបស់ខ្លួន។ ដូច្នេះ ទោះយ៉ាងណាក៏ដោយ ក៏ការងារក្នុងជីវិតនយោបាយ និង ជីវិតឯកជន បានលាយឡំជាមួយនឹងការងារជា ក្រុមប្រឹក្សាឃុំដែរ។ យោងតាមបទពិសោធន៍របស់ សមាគមមិត្តអ្នកគ្រូសត្រាយ ដែលកំពុងមានសកម្មភាពនៅក្នុងឃុំខ្នាពោធិ៍ជាច្រើនឆ្នាំមកហើយ លោកប្រធាន សមាគមបានយល់ឃើញថា លោកមេឃុំបានផ្តល់ អាទិភាពទៅលើការងារគណបក្ស។ សកម្មភាពការងារ ខ្លះរបស់ក្រុមប្រឹក្សាឃុំអាចត្រូវបានប្រើ ដើម្បីទាញ យកសន្លឹកឆ្នោត ឬ ដើម្បីចំណេញនយោបាយរបស់ គណបក្ស។ លោកប្រធានសមាគមបានបង្ហាញអំពី ការសង្កេតផ្ទាល់ខ្លួនរបស់លោកក្នុងឃុំខ្លះថា "ការធ្វើ កម្មវិធីវិនិយោគឃុំ ឃុំបានផ្តោតលើនយោបាយច្រើន ជាងតម្រូវការរបស់ប្រជាជន។ កន្លែងដែលមានប្រជាជនគាំទ្រគណបក្សគេច្រើន គេនឹងលើកគម្រោង ទៅដាក់នៅកន្លែងនោះ។ បើសិនកន្លែងណាគេឈ្នះ ឆ្នាត គេជួយជំរុញឱ្យផ្លូវលំនោះឆាប់កើតចេញជា រូបរាង" ។ ដោយសារបញ្ហានេះ នៅក្នុងកំឡុងពេល សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក អង្គការ មិនមែនរដ្ឋាភិបាលអាចមានការបារម្ភថា គម្រោងដែល ខ្លួនគាំទ្រ អាចផ្តល់ប្រយោជន៍ទៅគណបក្សនយោបាយច្រើនជាង។

សមត្ថភាព និង របៀបចាត់ចែងការងារ ក្នុងនាមជាអ្នកដឹកនាំឃុំ ក៏សំខាន់ផងដែរសម្រាប់ការងារ អភិវឌ្ឍន៍នៅមូលដ្ឋាន។ ថ្នាក់ដឹកនាំឃុំដឹងថា ខ្លួនមាន ភារកិច្ចបម្រើប្រជាពលរដ្ឋ ហើយ ជួយឱ្យមាន ការអភិវឌ្ឍនៅមូលដ្ឋាន ប៉ុន្តែ អំពីថាត្រូវធ្វើអ្វីខ្លះ ដោយដូចម្តេច ថ្នាក់ដឹកនាំឃុំមានភាពស្រពិចស្រពិល។ ដោយហេតុនេះ ការសម្រេចចិត្តថា នរណាត្រូវធ្វើអ្វីដោយរបៀបណា ក៏មានភាពមិនច្បាស់លាស់ដែរ។ ការរារែកក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងរឿងនេះ ត្រូវមានគេជួយគំនិត។

ម្យ៉ាងវិញទៀត ការគ្រប់គ្រងបុគ្គលិកក៏មិន សូវបានល្អដែរ។ អ្នកធ្វើការនៅសាលាឃុំ អ្នកសម្របសម្រួល និង អង្គការមិនមែនរដ្ឋាភិបាល បានសង្កេត ឃើញដូចគ្នាថា មានភាពខ្វះចន្លោះក្នុងការគ្រប់គ្រង បុគ្គលិក និងការគោរពវិន័យម៉ោងពេលមកធ្វើការ នៅសាលាឃុំ។ ភាពខ្វះចន្លោះក៏កើតមានចំពោះ ការតាមដានអំពីភាពរីកចម្រើន នៃសកម្មភាពការងារដែរ។ ស្ថានភាពបែបនេះអាចបណ្តាលឱ្យការងារ មានភាពយឺតយ៉ាវនៅក្នុងខណៈពេលដែលធនធានមនុស្ស ពូកែៗមានតិច ហើយសកម្មភាពការងារមានច្រើន។

ចំណែកឯ ការប្រជុំក្រុមប្រឹក្សាឃុំប្រចាំខែ ក៏ មិនសូវបានទៀងទាត់ដែរ ក្នុងពេលថ្មីៗកន្លងមកនេះ។ របៀបវារៈប្រជុំមិនសូវបានលើកយកបញ្ហាប្លែកៗ ឬ ថ្មីៗទេ ដូចជារបៀបវារៈស្ដីអំពីកិច្ចសហការជាមួយ អង្គការមិនមែនរដ្ឋាភិបាល ការងារការតាមដាន ត្រួតពិនិត្យ ជាដើម។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់ បានទទួលស្គាល់ថា ការប្រជុំមិនសូវដែលមានប្រជាជន ចូលរួមទេ ព្រោះពុំសូវបានជូនដំណឹងទៅប្រជាជន។

ចំពោះការយកចិត្តទុកដាក់លើការតាមដាន ត្រួតពិនិត្យគម្រោងវិញ ក្រុមប្រឹក្សាឃុំបានចាត់តាំង ជនបង្គោលពីរនាក់ ដែលម្នាក់ជាសមាជិកក្រុមប្រឹក្សា និង ម្នាក់ទៀតជាប្រជាពលរដ្ឋ។ ជនបង្គោលមិនសូវ មកប្រជុំក្រុមប្រឹក្សាឃុំទេ ហើយការប្រជុំក្រុមប្រឹក្សា ក៏មិនបានលើកយកចំណុចនេះដាក់ក្នុងរបៀបវារៈប្រជុំដែរ។

មាត្រា១៣ ៖ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ ហៅ ថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច ៖

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានា របស់ ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួនដំណើរការបានត្រឹមត្រូវ ទៅតាមវិធាន និង បទបញ្ជា ដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាឃុំ សង្កាត់ និង បទប្បញ្ញត្តិ ដូច មានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ។
- រក្សារបៀបរៀបរយ និង សណ្ដាប់ធ្នាប់ក្នុង ពេលប្រជុំ។

## ដំណើរការកសាងផែនការ

អ្នកសម្របសម្រួលស្រុក ប្រចាំឃុំខ្នាពោធិ៍ មានប្រសាសន៍ថា៖"គម្រោងហេដ្ឋារចនាសម្ព័ន្ធ មានច្រើនជាងគម្រោងសេវាកម្ម។ ... ពេលលើកយក គម្រោងសេវាកម្ម ក្រុមប្រឹក្សាឃុំមិនគិតដល់ថា ត្រូវប្រើថវិកាឃុំទេ។ ... គម្រោងសេវាកម្មពីមុនមក ពុំ សូវមានការគាំទ្រទេ ប៉ុន្តែក្រុមប្រឹក្សាឃុំលើកឱ្យមាន ទៅ" ។

តាំងពីជំហាន១ នៃដំណើរការកសាងកម្មវិធី វិនិយោគឃុំមកម្លេះ ក្រុមប្រឹក្សាឃុំបានលើកយក គម្រោងសេវាកម្មជាច្រើនមកពិភាក្សារួចទៅហើយ។ នៅក្នុងជំហាន២ ប្រជាជន ដែលចូលរួមប្រជុំភូមិ មិន បានលើកគម្រោងសេវាកម្មអ្វីបន្ថែមទៀតទេ។ ទោះបី ប្រជាជនមិនបានផ្ដល់យោបល់អ្វីច្រើនមែន ប៉ុន្តែមាន ប្រជាជនជាច្រើនបានចូលរួម។ តួយ៉ាង នៅភូមិឈូក ប្រជាជនបានចូលរួមប្រមាណ ៨០% នៃគ្រួសារសរុប ចំនួន ១១៥ គ្រួសារ។ ក្នុងប្រជុំភូមិនោះ ពុំសូវមានមនុស្សចាស់ និង អ្នកចេះដឹងចូលរួមទេ។ ផ្ទុយទៅវិញ គេសង្កេតឃើញមានមនុស្សប្រុស ដែលស្រវឹងស្រា ចូលរួមប្រជុំ។

មានសេចក្តីរាយការណ៍បន្ថែមថា មិនត្រឹមតែ សមាជិកក្រុមប្រឹក្សាឃុំមិនយល់ច្បាស់ អំពីដំណើរការ កសាងផែនការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនសូវបាន ចូលរួមប្រជុំធ្វើផែនការទៀតផង។ បើសិនសមាជិក ក្រុមប្រឹក្សាមិនសូវបាន ចូលរួមធ្វើផែនការផង តើអាច មានអង្គការ សមាគម និង មន្ទីរ បានចូលរួមធ្វើ ផែនការឬទេ? ដោយសារអង្គការមិនមែន រដ្ឋាភិបាល ពុំមានដំណឹង ឬ កាលវិភាគអំពីការកសាងផែនការ អង្គការ ឬ ស្ថាប័ន ដែលចង់ចូលរួម មានការពិបាកក្នុង ការស្វះស្វែងដើម្បីចូលរួមទៅក្នុងដំណើរការនោះ។ ក្រុមប្រឹក្សាឃុំហាក់បីដូចជាមិនសូវចាប់អារម្មណ៍ មកលើអង្គការទេ នៅខណៈពេលដំណើរការកសាងផែនការ ដំបូង។ ប៉ុន្តែនៅពេលសិក្ខាសាលាសមាហរណកម្ម ផែនការថ្នាក់ស្រុក ទើបក្រុមប្រឹក្សាឃុំព្យាយាមពន្យល់ និង ប្រឹងប្រែងរកការគាំទ្រគម្រោងរបស់ខ្លួនពីអង្គការ និងស្ថាប័ននានា។

តាមពិតទៅទង្វើខាងលើនេះមិនខុសគ្នាពីអ្វីដែលបានកើតឡើងក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក នៅខេត្តផ្សេងទៀតឡើយ។ ក៏ប៉ុន្តែ និន្នាការកើនឡើងនៃគម្រោងសេវាកម្ម ក្នុងឃុំខ្នាពោធិ៍ អាចមានភាពខុសគ្នា។ គម្រោងសេវាកម្មជាច្រើន ត្រូវ បានលើកឡើង នៅក្នុងដំណើរការកសាងផែនការឃុំ ខ្នាពោធិ៍នៅឆ្នាំ ២០០៦។ លោកប្រធាន សមាគមមិត្ត អ្នកត្រួសត្រាយបានពន្យល់អំពីនិន្នាការនេះថា មកពី លទ្ធផលនៃការអនុវត្តគម្រោងសេវាកម្ម នៅក្នុងឃុំ ពីព្រោះ គម្រោងសេវាកម្មធ្វើឱ្យប្រជាពលរដ្ឋអាច ទទួលយកបាន អាចធ្វើឱ្យប្រជាពលរដ្ឋមានជីវភាព កើនឡើង ហើយ អាចកាត់បន្ថយបញ្ហាស្មុគស្មាញរបស់ សង្គម ដូចជា ការធ្វើចំណាកស្រុក ជាដើម។ អ្វីដែល សំខាន់លើសពីនេះ គឺទាំងអាជ្ញាធរស្រុក និង ឃុំ ហាក់ ដូចជាយល់ឃើញថា បញ្ហា ឬ តម្រូវការផ្ទាល់របស់ ប្រជាពលរដ្ឋ ទាក់ទងនឹងជីវភាពរស់នៅផ្ទាល់របស់ប្រជាពលរដ្ឋ។

ហេតុដូច្នេះហើយ បានជាគេសង្កេតឃើញថា អង្គការបានបញ្ជ្រាបគម្រោងរបស់ខ្លួន ទៅក្នុងផែនការ របស់ឃុំ តាមរយៈសកម្មភាពរួមគ្នាជាមួយក្រុមប្រឹក្សាឃុំ ក្នុងការធ្វើផែនការជ្រើសរើសក្រុមគោលដៅ។ ដើម្បីឱ្យប្រាកដថា គម្រោងបានផ្តល់ផលប្រយោជន៍ ទៅអ្នកក្រីក្រពិតប្រាកដ សមាគមមិត្តអ្នកត្រួសត្រាយ បានណែនាំផង ជួយធ្វើផង ដល់ក្រុមប្រឹក្សាឃុំ។ លោក ជំទប់ទី១ បានចូលរួមយ៉ាងសកម្មក្នុងការងារនេះ។ ប៉ុន្តែ លោកជំទប់ទី១មិនដែលបានគិតគូរថា ត្រូវក្រេប យកចំណេះដឹង ចំណេះធ្វើឱ្យបានច្រើន តាមដែលអាច ធ្វើបាន ដើម្បីអាចម្ចាស់ការធ្វើដោយខ្លួនឯងបាន នៅក្រោយពេលដែលសមាគមមិត្តអ្នកត្រួសត្រាយ ដកខ្លួន ចេញ ឬ លែងធ្វើគម្រោងនេះតទៅមុខទៀត។

លោកជំទប់ទី១ បានរៀនសូត្រអំពីរបៀប វិភាគផែនទីភូមិ ការធ្វើកាលវិភាគតាមរដូវកាល និងចំណាត់ថ្នាក់ទ្រព្យធន។ លោកជំទប់ទី១ អាចយក វិធីសាស្ត្រនេះទៅប្រើ ដើម្បីធ្វើផែនការ និងកំណត់ រកក្រុមគោលដៅ សម្រាប់ដំណើរការកសាងផែនការ អភិវឌ្ឍន៍ឃុំ។ ទោះបីជាមានបទពិសោធន៍ក៏ដោយ ដោយសារស្ថានភាពរបស់អង្គការ និង ក្រុមប្រឹក្សាមិនដូចគ្នា លោកជំទប់ទី១អាចមានការពិបាកក្នុង ការអនុវត្តវិធីសាស្ត្រនេះ។ អង្គការបានដឹងថា ខ្លួនមាន ថវិកាសម្រាប់អនុវត្តគម្រោងរួចជាស្រេច ចំណែកឯ ក្រុមប្រឹក្សាឃុំវិញពុំបានដឹងជាមុនថា ខ្លួនមានថវិកា សម្រាប់អនុវត្តគម្រោងឡើយ។ ប្រសិនបើនៅពេល ដែលក្រុមប្រឹក្សាឃុំអាចរកចំណូលខ្លួនឯងបាន ហើយអាចព្យាករណ៍អំពីថវិការបស់ខ្លួនបាន ក្រុមប្រឹក្សាឃុំ អាចប្រើប្រាស់បទពិសោធន៍ ដែលខ្លួនទទួលបានខាងលើនេះបាន។ ប្រការនេះទាក់ទងនឹងលទ្ធភាពផ្តល់ហិរញ្ញប្បទាន សម្រាប់ការផ្តល់សេវាកម្មនានារបស់ក្រុមប្រឹក្សាឃុំ។

## ជំនួយមិនមែនហិរញ្ញវត្ថុដល់ក្រុមប្រឹក្សាឃុំ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បាន រៀបរាប់អំពីរចនាសម្ព័ន្ធរដ្ឋបាល តួនាទី មុខងារ និង អំណាចនៃរដ្ឋបាលឃុំសង្កាត់។ លើសពីនេះទៀត រចនាសម្ព័ន្ធនៅថ្នាក់ជាតិ រហូតដល់ថ្នាក់ខេត្ត ស្រុក ដើម្បីគាំទ្រកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន ក៏ត្រូវ បានបង្កើតឡើងដែរ។ ហើយជាមួយគ្នានេះដែរ ស្មៀន ឃុំ សង្កាត់ ក៏ត្រូវបានតែងតាំងឡើង ដោយរាជរដ្ឋាភិបាល ដើម្បីជួយការងាររដ្ឋបាលឃុំ សង្កាត់ និង ធានាឱ្យមានអនុលោមភាពតាមច្បាប់ ព្រមទាំង ជាច្រកទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់លើ។ ដូច្នេះ ក្រុមប្រឹក្សាឃុំ បានទទួលនូវជំនួយមិនមែនហិរញ្ញវត្ថុ យ៉ាងច្រើនសន្ធឹក ដើម្បីធ្វើឱ្យដំណើរការអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យបានប្រព្រឹត្តទៅដោយរលូន និង ដោយមានប្រសិទ្ធភាព។ ក៏ប៉ុន្តែ ក្រុមប្រឹក្សាឃុំ ខ្នាពោធិ៍ ប្រហែលជាដូចក្រុមប្រឹក្សាឃុំដទៃទៀតដែរ ពុំមានការដឹកនាំដ៏រឹងមាំមួយឡើយ។ គេបានរាយការណ៍ អវិជ្ជមានអំពីភាពជាអ្នកដឹកនាំ នៅក្នុងក្រុមប្រឹក្សា ឃុំ។ តើនរណាដែលមានតួនាទី នៅសាលាឃុំ អាចជួយធ្វើឱ្យមានការអនុវត្តន៍ការងារបានល្អ?

ដោយមិនទាន់និយាយដល់ជំទប់ សមាជិក ក្រុមប្រឹក្សា និង ស្មៀន អ្នកសម្របសម្រួលស្រុក តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត និង អង្គការ មិនមែនរដ្ឋាភិបាលត្រូវគេមើលឃើញថា ជាតួអង្គនៅ ក្រៅសាលាឃុំ ដែលអាចជួយគំនិត និង បច្ចេកទេស ដោយផ្ទាល់យ៉ាងច្រើនដល់សាលាឃុំ ទៅតាមមុខនាទី រៀងៗខ្លួន។ មានសេចក្តីរាយការណ៍ថា អាជ្ញាធរស្រុក មានឥទ្ធិពលមកលើលោកមេឃុំ ច្រើនជាងអង្គភាព រដ្ឋបាលមូលដ្ឋាន ប៉ុន្តែបច្ចុប្បន្ននេះ អាជ្ញាធរស្រុក មាន តួនាទីមានកម្រិត ក្នុងការជួយគាំទ្រឃុំ។ ចំណែកឯ អង្គការមិនមែនរដ្ឋាភិបាលវិញ ជួយក្រុមប្រឹក្សាឃុំតែ ក្នុងរង្វង់ ឬ ក្នុងក្របខណ្ឌការងារ ដែលអង្គការនោះ ត្រូវធ្វើជាមួយក្រុមប្រឹក្សាឃុំប៉ុណ្ណោះ។ ឧទាហរណ៍ សមាគមមិត្តអ្នកត្រួសត្រាយ បានផ្តល់យោបល់កាលពី ឆ្នាំ ២០០៦ ឱ្យក្រុមប្រឹក្សាឃុំពិនិត្យលទ្ធភាពអនុញ្ញាត ឱ្យជំទប់ទី១កាន់លុយវិញ ក្រោយពីស្មៀនដកបានថវិកា ពីរតនាគារខេត្ត។ ការផ្តល់យោបល់នេះ កើតឡើង នៅពេលដែលក្រុមប្រឹក្សាឃុំ លែងទុកចិត្តស្មៀន ដែល មិនបានប្រគល់លុយគ្រប់ចំនួន ទៅក្រុមប្រឹក្សាឃុំ។ សមាគមបានតាមដានពិនិត្យឃើញថា មានការបន្លំ ហត្ថលេខារបស់លោកមេឃុំ ដើម្បីដកលុយពីរតនាគារខេត្ត។ ករណីមួយទៀតគឺសមាគមបានសិក្សាឱ្យយល់អំពីប្រព័ន្ធហិរញ្ញវត្ថុឃុំ និង បានសហការជាមួយ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ដើម្បីរកវិធីសាស្រ្តជួយ ក្រុមប្រឹក្សាឃុំ ជាពិសេសស្មៀន ឱ្យអាចដកលុយពី រតនាគារបានឆាប់។

ចំពោះស្មៀនឃុំវិញ ក៏អាចមានតួនាទីសំខាន់ ដែរ។ ប្រធានសមាគមមិត្តអ្នកត្រួសត្រាយ កាលពី ថ្ងៃទី ១៥ វិច្ឆិការ ឆ្នាំ ២០០៧ បានមានប្រសាសន៍ថា" ស្មៀនថ្មីនេះគឺជាស្មៀនឃុំមានចំណេះដឹងច្រើន មាន សមត្ថភាព មានជីវភាពសមរម្យល្មម ហើយយកចិត្ត ទុកដាក់នឹងការងារ" ។ ស្មៀនឃុំថ្មីបានចូលមកជំនួស ស្មៀនឃុំចាស់ដោយពុំបានទទួលការបង្ហាញ ឬ ការផ្ទេរការងារពីស្មៀនឃុំចាស់ឡើយ ក្រោយពីស្មៀនឃុំចាស់ បានផ្លាស់ចេញ។

ស្មៀនឃុំថ្មីបានទទួលការបង្ហាត់បង្ហាញពីសមាគម ហើយសមាគមនេះក៏មានឆន្ទៈជួយពង្រឹងសមត្ថភាពដល់ស្មៀនឃុំផងដែរ តាមរយៈគម្រោង សេវាកម្ម ដែលសមាគមបានផ្តល់ថវិកាឱ្យក្រុមប្រឹក្សា ឃុំ និង សកម្មភាពការងារផ្សេងទៀត ដែលសមាគម ធ្វើជាមួយក្រុមប្រឹក្សាឃុំ ។

ដូចគ្នានឹងស្មៀនឃុំដែរ ជំទប់ទី១ ក៏ជាមនុស្ស ដែលសមាគមចង់ជួយពង្រឹងសមត្ថភាពដែរ ។ លោក ជំទប់ទី១ មិនសូវចេះដូចលោកមេឃុំទេ ប៉ុន្តែ គាត់ មានឆន្ទៈ ហើយឧស្សាហ៍មកសាលាឃុំ ។ យោងតាម ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ជំទប់ ឬ ចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ ក្នុងការអនុវត្តភារកិច្ច ដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ ។

**ប្រការ១២: ប្រកាសស្តីពីតួនាទី ភារកិច្ច និង សិទ្ធិ របស់ស្មៀនឃុំ សង្កាត់**

ក្នុងករណីដែលសេចក្តីសម្រេច វិធានការ និង ឯកសារនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ បានសម្រេចរួចហើយ ឬ ដែលបានដាក់ស្នើសុំ ការសម្រេចពីក្រុមប្រឹក្សាគ្មានលក្ខណៈត្រឹមត្រូវ ឬ មិនសមស្របតាមនីតិវិធី និង ច្បាប់ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើការកត់សម្គាល់នូវកំហុសឆ្គង ទាំងនោះ ហើយ អាចស្នើសុំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការកែសម្រួលឱ្យបានសមស្រប ។

សេចក្តីកត់សម្គាល់ ឬ សំណើទាំងឡាយរបស់ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ ឬ តំណាង ស្របច្បាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់បដិសេធ មិនទទួលយកការកែសម្រួល ឬ វិធានការ ដែល នឹងធានាឱ្យមានលក្ខណៈសមស្របតាមនីតិវិធី និង ច្បាប់ ស្មៀនឃុំ សង្កាត់ត្រូវធ្វើសេចក្តី រាយការណ៍ ជាបន្ទាន់ជូនក្រសួងមហាផ្ទៃ និង ចម្លងជូនមេឃុំ ចៅសង្កាត់មួយច្បាប់ ។

**មាត្រា ៤០: ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**

ជំទប់ ឬ ចៅសង្កាត់រង ជាជំនួយការរបស់ មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ និង ជំនួសមេឃុំ ចៅសង្កាត់ ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅ ពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬ ចៅសង្កាត់រង ត្រូវធ្វើការបែងចែក ភារកិច្ចដូចខាងក្រោម :

ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ទទួលជួយ មេឃុំ ចៅសង្កាត់ លើកិច្ចការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំទប់ទី២ ឬ ចៅសង្កាត់រងទី២ ទទួលជួយ មេឃុំ ចៅសង្កាត់ លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និង សណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬ ចៅសង្កាត់រងរបស់ខ្លួន ។

ដូច្នេះទាំងក្នុងទិដ្ឋភាពច្បាប់ និង ទិដ្ឋភាពជាក់ស្តែង មានជំនួយមិនមែនហិរញ្ញវត្ថុច្រើនណាស់ សម្រាប់ជួយដល់ក្រុមប្រឹក្សាឃុំ ។ ប៉ុន្តែអ្វីៗទាំងអស់ មិនស្ថិតនៅលើជំនួយទាំងនោះទេ ។ លោកមេឃុំគឺជា បុគ្គលសំខាន់ ហើយ ចាំបាច់បំផុតដើម្បីដឹកនាំក្រុមប្រឹក្សា ឃុំ និងការងារអភិវឌ្ឍន៏ជាច្រើន ។ ដោយធ្លាប់ធ្វើជា មេឃុំមួយអាណត្តិមកហើយ លោកមេឃុំពិតជាមាន បទពិសោធន៏នៅក្នុងការដឹកនាំ ទោះតិចក្តី ច្រើនក្តី ។ ការដឹកនាំត្រូវផ្សារភ្ជាប់នឹងការអនុវត្ត ។ ហើយ ទ្រឹស្តី និង ការប្រកាន់ភ្ជាប់នូវគោលការណ៏សំខាន់ៗរបស់ អ្នកដឹកនាំរឹតតែមានសារៈសំខាន់ ។ ទ្រឹស្តីគោលក្នុង ការដឹកនាំចង់ឱ្យអ្នកដឹកនាំធ្វើការសកម្ម ជាគំរូ និង បង្ហាញលទ្ធផល ។

ភាពជាអ្នកដឹកនាំៈ

- មិនមែនជាមុខតំណែង ប៉ុន្តែជាផលិតកម្ម
- មិនមែនជាការទេសនា ប៉ុន្តែជាការឱ្យគំរូ
- មិនមែនជាប្រជាប្រិយភាព ប៉ុន្តែជាលទ្ធផល

# ក្រុមប្រឹក្សាឃុំល្វា ដើរក្នុងទិសដៅត្រូវៈ សាកល្បងធ្វើគម្រោងសេវាកម្មមុនគេ[៨]

## លោក ញ៉ុក ឈួរ មានប្រសាសន៍ថា

*"... ខ្ញុំស្មានថា គម្រោងនេះ គឺត្រឹមតែចែកពូជស្រូវ ដល់ប្រជាពលរដ្ឋទៅ គឺចប់ហើយ ។ ... ដល់ពេល ធ្វើខ្លួនឯង បានដឹងថា ពិបាក" ។*

## ស្ថានភាពទូទៅឃុំល្វា

ឃុំមួយ ដែលស្ថិតនៅជាប់ផ្លូវជាតិលេខ៦ ពីទី រួមខេត្តសៀមរាបទៅស្រុកក្រឡាញ់ គឺឃុំល្វា ចម្ងាយ ៤ គ.ម ពីទីរួមស្រុកពួក ដែលមានផ្សារធំល្មមមួយ នៅទីនោះ ។ ប៉ុន្តែ ឃុំល្វាពុំមានផ្សារទេ ។ ឃុំល្វា មិនមែនត្រឹមតែជាឃុំមួយក្នុង ចំណោមឃុំទាំង ១៦ របស់ស្រុកពួកប៉ុណ្ណោះទេ ប៉ុន្តែ គឺជាឃុំដំបូងគេនៅក្នុង ខេត្តសៀមរាប ដែលបានប្រើថវិការបស់ខ្លួន ដើម្បី អនុវត្តគម្រោងសេវាកម្ម ( គម្រោងចែកពូជស្រូវ និង បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ និង ជីកំប៉ុស្តិ៍) ។

ឃុំនេះមានអំណោយផលខាងកសិកម្ម មាន ១២ ភូមិ និង មានប្រជាពលរដ្ឋសរុប ៩.៤៩៩ នាក់ ស្មើនឹង ១.៧៨៨ គ្រួសារ ។ ប្រជាពលរដ្ឋមួយចំនួនតូច ធ្វើស្រែ ប្រាំង ដោយប្រើប្រាស់ទំនប់តំកល់ទឹក ហើយភាគច្រើន បំផុតធ្វើស្រែ អាស្រ័យទឹកភ្លៀង ។ មានតែ៥ ភូមិធ្វើស្រែវស្សា ចំណែកឯ ៧ភូមិទៀត អាចធ្វើស្រែ ប្រាំងផង ស្រែវស្សាផង ដូចជា ភូមិល្វា ដូនទ្រ គំរូ ស្ទឹងព្រះស្រុក គោកស្រម៉ ទូលរវៀង និង ព្រហ៊្យូត ។ ទិន្នផលស្រូវ ជាមធ្យមបាន៣តោន ក្នុង១ហិកតា ។ ក្រៅពី ប្រកបរបរស្រែចម្ការ ប្រជាពលរដ្ឋមានមុខរបរ បន្ទាប់បន្សំ ដូចជា នេសាទ ធ្វើកន្ទេល ដាល់អំបុក ។ល ។

ក្នុងអាណត្តិទី១ ក្រុមប្រឹក្សាឃុំសម្រេចបាន គម្រោងហេដ្ឋារចនាសម្ព័ន្ធជាច្រើន ។ ក្រុមប្រឹក្សាយល់ ថា សមិទ្ធិផល ហេដ្ឋារចនាសម្ព័ន្ធមានស្ទើរគ្រប់តម្រូវការ រួចហើយ ដូច្នេះក្រុមប្រឹក្សាអាចងាកមកអនុវត្ត គម្រោងសេវាកម្មវិញម្តង ។ ទោះបីជាយ៉ាងណា ក៏ ក្រុមប្រឹក្សានៅតែបន្តអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែរ ។

---

[៨] ករណីសិក្សានេះសរសេរដោយលោក អ៊ឹម សុខធី សម្រាប់ គំរោងគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ (CCSP) ដើម្បីផ្សព្វផ្សាយអំពី បទពិសោធន៍ និង មេរៀន ដែលក្រុមប្រឹក្សាឃុំទទួលបានកន្លងមក ទាក់ទងនឹងដំណើរការកសាងផែនការ និង ថវិកា ការអនុវត្ត គម្រោង និង ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ ។ ករណីសិក្សា នេះផ្តោតលើគម្រោងសេវាកម្ម ដែលក្រុមប្រឹក្សាឃុំ បានប្រើថវិកា របស់ខ្លួន ទោះបីជាថវិកាផ្តល់ឱ្យដោយអង្គការ ឬ ដោយ មូលនិធិឃុំសង្កាត់ ។ករណីសិក្សានេះ បង្ហាញអំពីស្ថានភាពជាក់ស្តែង ហើយ អ្នកនិពន្ធសន្មតទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារនៃករណីសិក្សានេះ ។ អ្នកជំនួយការស្រាវជ្រាវគឺលោក ឈឹម សុភាគ មន្ត្រីព័ត៌មានរបស់ CCSP ។ ករណីសិក្សានេះមិនអាចត្រូវបានចម្លង ទោះជាដោយផ្នែកឬទាំងមូលនោះទេ បើគ្មានការអនុញ្ញាតពីគំរោង គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ។ រក្សាសិទ្ធិ © គំរោងគាំទ្រក្រុមប្រឹក្សា ឃុំ សង្កាត់ ខែធ្នូ ឆ្នាំ២០០៧ ។

ជាក់ស្តែងក្នុងផែនការថវិកាឃុំឆ្នាំ២០០៧ក្រុមប្រឹក្សាគ្រោងចំណាយ១៩.៩៦៩.៤០០រៀលធ្វើលូកាត់ផ្លូវ១០កន្លែង និង ២២.២៧៥.០០០រៀល ធ្វើផ្លូវក្រាលក្រួសក្រហមប្រវែង ១.១៥០ ម។ ផ្លូវ នានានៅតាមភូមិនីមួយៗមានសភាពទ្រុឌទ្រោម។ លូ ស្ពានឈើមួយចំនួនទាមទារការជួសជុលបន្ថែម ដើម្បី បង្កលក្ខណៈងាយស្រួល ក្នុងការធ្វើដំណើរ និង ការដឹកជញ្ជូនរបស់ប្រជាពលរដ្ឋ។

នៅក្នុងឃុំនេះ គេឃើញមានអង្គការជាច្រើន បានធ្វើសកម្មភាព ក្នុងវិស័យសុខាភិបាល អប់រំ កសិកម្ម។ល។ អង្គការទាំងនោះរួមមាន អង្គការ ស្រែខ្មែរ អង្គការវ៉ាឆា អង្គការខ្មែរអភិវឌ្ឍន៍ខ្មែរ អង្គការកសិកម្ម និង ស្បៀងអាហារ និង អង្គការ ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ូណធភាំ។ មានសេចក្តី រាយការណ៍ថា លោកមេឃុំ ក៏ដូចជាសមាជិកក្រុមប្រឹក្សាដែរ យកចិត្តទុកដាក់ និង សកម្ម ក្នុងកិច្ចសហការល្អ ជាមួយអង្គការ។

## ប្រវត្តិលោកមេឃុំ

ប្រធានក្រុមប្រឹក្សាឃុំ ដែលមានវ័យចំណាស់ មានភាពចាស់ទុំ និង ជាមនុស្សគួរឱ្យរាប់អាន និង គោរព របស់ឃុំល្វា គឺ លោក ញ៉ុក ឈួរ។ គាត់មាន អាយុ ៦៨ ឆ្នាំ ជាឪពុក មានកូន ៦ នាក់។ គាត់បាន ឈប់ពីការសិក្សាត្រឹមថ្នាក់ទី៨ចាស់ (ថ្នាក់ទី៤បច្ចុប្បន្ន) នៅឆ្នាំ១៩៥៧។ គាត់ធ្លាប់ជាជំទប់ទី១ នៅឆ្នាំ១៩៦៣ នៅសម័យសង្គមរាស្ត្រនិយម មានស្រុកកំណើតនៅ ភូមិល្វា ឃុំល្វា។ ក្រោយឆ្នាំ១៩៧៩ គាត់បាន វិលត្រឡប់មករស់ នៅក្នុងភូមិកំណើតរបស់គាត់វិញ។ ពី ឆ្នាំ ១៩៧៩ ដល់ ឆ្នាំ ១៩៩២ គាត់គឺជាសមាជិក អចិន្ត្រៃយ៍ឃុំល្វា។ ក្រោយពីបានស្ថិតនៅក្នុងជីវភាពជា កសិករបាន ៧ឆ្នាំមក គាត់បានក្លាយជាមេភូមិល្វា ពីឆ្នាំ ២០០១ ដល់ ឆ្នាំ២០០២។ ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ អាណត្តិទី១ បានធ្វើឱ្យរូបគាត់ក្លាយជា ជំទប់ទី១។ បន្ទាប់ពីលោកមេឃុំអាណត្តិទី១ បានទទួល មរណភាព លោក ញ៉ុក ឈួរ បានឡើងជាមេឃុំ ជំនួស។ ក្នុងអាណត្តិទី២នេះទៀត គាត់បានជាប់ឆ្នោត ជាប្រធានក្រុមប្រឹក្សាឃុំល្វា ដែលមានសមាជិកចំនួន ៧នាក់ មកពីគណបក្សប្រជាជនកម្ពុជាទាំងអស់។ គាត់ បានសម្រេចចិត្តឈរឈ្មោះ ជាបេក្ខជនក្រុមប្រឹក្សាឃុំ គឺមិនមែនដោយសារត្រឹមតែហេតុផលការចាត់តាំង ពី គណបក្សប៉ុណ្ណោះទេ។ បទពិសោធន៍ការងារក្នុង ការដឹកនាំ និង ប្រជាប្រិយភាពរបស់គាត់ បាននាំឱ្យ គាត់សម្រេចចិត្តឈរឈ្មោះបោះឆ្នោត។ គាត់យល់ ឃើញថា គាត់ធ្លាប់មានបទពិសោធន៍ក្នុងការដឹកនាំ និង មានទំនាក់ទំនងល្អ និង មានភាពរួសរាយរាក់ទាក់ ជាមួយប្រជាពលរដ្ឋ។ គាត់ធ្លាប់ត្រូវបានគេប្រគល់ ភារកិច្ចឱ្យចូលរួម នៅក្នុងគណៈកម្មការបុណ្យកសាង ផ្លូវ ក្នុងតួនាទីជាអ្នកប្រមូលបច្ច័យ ដោយសារគេទុកចិត្តគាត់។ ដោយបានរួមជាមួយ គណៈកម្មការ គាត់ អាចប្រមូលបច្ច័យបាន សម្រាប់ការកសាងផ្លូវលំ។ គាត់គឺជាមនុស្សមានឆន្ទៈ និង មនសិការ។ គាត់បាន និយាយត្រង់ថា "តាមចិត្តខ្ញុំ ខ្ញុំមិនគួរធ្វើជាមេឃុំទេ ព្រោះខ្ញុំចាស់ហើយ។ ... ប៉ុន្តែ ខ្ញុំចង់ឃើញឃុំល្វា មាន មុខមាត់ មាន ការអភិវឌ្ឍន៍" ។

សមាជិកក្រុមប្រឹក្សាឃុំទាំងអស់៧រូប គឺមកពីគណបក្សប្រជាជនកម្ពុជាតែមួយ។ ពួកគេមាន សាមគ្គីភាព ផ្ទៃក្នុង និង មានទំនាក់ទំនងគ្នាល្អ។ លោក មេឃុំមិនប្រកាន់ឬកពារ ហើយ សមាជិកក្រុមប្រឹក្សា ចូលរួមយោបល់ និង ជួយកិច្ចការសាលាឃុំ។

## ឃុំល្វាត្រូវការធនធានមនុស្ស

លោកមេឃុំបានគិតអំពីការអភិវឌ្ឍ ប្រកប ដោយចិរភាព ដោយចង់ឃើញឃុំល្វា ជាឃុំ ដែលសំបូរ ដោយអ្នកចេះ អក្សរ (សំដៅលើការបណ្តុះបណ្តាល ធនធានមនុស្ស)។ គាត់ត្រូវការធនធានមនុស្ស ដើម្បី ចូលរួមក្នុងការអភិវឌ្ឍន៍នៅ មូលដ្ឋាន។ អាស្រ័យ ហេតុនេះ គាត់ចង់ឱ្យក្មេង១នៅក្នុងភូមិទាំងអស់ បាន ចូលរៀន ប៉ុន្តែកុមារមិនបានចូលរៀនអស់ ហើយ មួយ ចំនួនបានបោះបង់ចោលសាលារៀន។ កុមារខ្លះបាន ឈប់រៀនតាំងពីថ្នាក់ទី ២ ថ្នាក់ទី៣ ម្លេះ។ ទីតាំង សាលារៀន ទៅភូមិនីមួយ១ មានចម្ងាយជាមធ្យម ១០ គ.ម។

ឥឡូវនេះ សាលារៀនមានចំនួនកើនឡើង ច្រើន គឺមានសាសាបឋមសិក្សា ៩ ខ្នង ក្នុង១២ ភូមិ ប៉ុន្តែ មិនអាច បំពេញបាននូវសេចក្តីត្រូវការយ៉ាងច្រើនទេ។ អនុវិទ្យាល័យមួយកន្លែង ទើបចាប់ផ្តើមបើក ហើយដូច្នេះ កុមារក្នុងឃុំល្វា អាចមានឱកាសបានបន្ត ការសិក្សានៅទីនោះ។ កម្មវិធីវិនិយោគឃុំ៣ឆ្នាំរំកិល ២០០៧-២០០៩ បានលើកយកគម្រោង ឧបត្ថម្ភសិស្ស ក្រីក្រជាអាទិភាពខ្ពស់ ដើម្បីដាក់នៅក្នុងសិក្ខាសាលា សមាហរណកម្មផែនការថ្នាក់ស្រុកការយកចិត្តទុកដាក់ របស់ក្រុមប្រឹក្សាឃុំ មិនមានតែចំពោះការលើក គម្រោងប៉ុណ្ណឹងទេ។ ក្រុមប្រឹក្សាបានសម្រេចបង្កើតស្ថាប័ននានា ដើម្បី ជួយគាំទ្រវិស័យអប់រំ។ មាន គណៈកម្មាធិការជាច្រើន ត្រូវបានបង្កើតឡើង ដូចជា គណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នា គណៈកម្មការ ទ្រទ្រង់សាលារៀន ជាដើម។

លោកមេឃុំ ក៏ដូចជាក្រុមប្រឹក្សា ហាក់បីដូចជា មានទស្សនៈវិស័យវែងឆ្ងាយ ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន របស់ខ្លួនឱ្យ លឿនទៅមុខ និង ប្រកបដោយចិរភាព។ ប៉ុន្តែ តួនាទី និង ការពាក់ព័ន្ធរបស់ឃុំ មិនទាន់មាន ភាពច្បាស់លាស់ទេ បើគេពិនិត្យតាមទិដ្ឋភាពច្បាប់ លទ្ធភាពថវិកា និង សមត្ថភាពរបស់ក្រុមប្រឹក្សា។

និយាយដោយឡែក តួនាទីរបស់ក្រុមប្រឹក្សា ឃុំ ក្នុងវិស័យអប់រំ មានត្រឹមតែជាការផ្តល់ជំនួយ ក្នុង ការពិនិត្យ និង ការសម្របសម្រួលដើម្បីជំរុញឱ្យ វិស័យអប់រំ អាចជួយលើកស្ទួយការអភិវឌ្ឍធនធាន មនុស្សប៉ុណ្ណោះ។ ពោលគឺក្រុម ប្រឹក្សាឃុំពុំបានចូលរួម ដោយផ្ទាល់ និង យ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យ អប់រំនៅមូលដ្ឋានទេ។ ក្នុងកម្រិតណាក៏ដោយ ដែល ក្រុមប្រឹក្សាឃុំអាចធ្វើបាន ក្នុងពេលបច្ចុប្បន្ននេះ ក្រុមប្រឹក្សាឃុំព្យាយាមលើកកម្ពស់វិស័យអប់រំ ដោយលើកយក គម្រោងនានាទៅដាក់បញ្ចូល ក្នុងផែនការ វិនិយោគឃុំ ក៏ដូចជាដើម្បីស្វែងរកការគាំទ្រគម្រោង នៅក្នុងសិក្ខាសាលា សមាហរណកម្មផែនការថ្នាក់ស្រុកផងដែរ។

## ការកៀរគររកធនធានសម្រាប់ឃុំ

ក្រុមប្រឹក្សាឃុំមានការទទួលខុសត្រូវ ចំពោះភារកិច្ចជាច្រើន ទាក់ទងនឹងការគ្រប់គ្រងការអភិវឌ្ឍន៍ និង ការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ ប្រជាពលរដ្ឋ។ ភារកិច្ចទាំងនោះរួមមាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការការពារធនធានធម្មជាតិ និង បរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កិច្ចការ ទូទៅនៅក្នុងឃុំ និង សេវាកម្មចាំបាច់ផ្សេងទៀត ។

នៅចំពោះមុខភារកិច្ច ដែលមានច្រើនបែបនេះ ក្រុមប្រឹក្សាឃុំ មិនអាចប្រើប្រាស់ធនធានមានកម្រិត របស់ខ្លួនដើម្បីបំពេញសេចក្តីត្រូវការចាំបាច់ទាំងអស់ របស់ប្រជាពលរដ្ឋ ក៏ដូចជាក្នុងមូលដ្ឋានបានទេ ។ ជា រៀងរាល់ឆ្នាំ ក្រុមប្រឹក្សា" ឃុំធ្វើទំនាក់ទំនងជាមួយមន្ទីរ អង្គការ នៅពេលសិក្ខាសាលាសមាហរណកម្មផែនការ ថ្នាក់ស្រុក ។

ម្យ៉ាងវិញទៀត ក្រៅពីការប្រឹងប្រែងរបស់ ខ្លួន នៅក្នុងពេលសិក្ខាសាលានោះ ក្រុមប្រឹក្សាឃុំល្វា នៅបានប្រឹងប្រែងកៀងគររកធនធានពីប្រភពខាងក្រៅ សម្រាប់ការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ ក្រុមប្រឹក្សា ឃុំបានប្រើវិធីសាស្ត្រដូចជាផ្តល់ភាពរាក់ទាក់ មានសមានចិត្ត និង ផ្តល់កិច្ចសហការល្អជាមួយមន្ទីរ និង អង្គការសង្គមស៊ីវិល ដើម្បីកៀងគររកប្រភពពីខាង ក្រៅ ។ លើសពីនេះ កត្តាភូមិសាស្ត្រ និង សន្តិសុខ ក៏ អាចជាកត្តាទាក់ទាញផងដែរ ។

អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ គេសង្កេត ឃើញមានអង្គការខ្លះ បានមកទំនាក់ទំនងផ្ទាល់ជាមួយ ក្រុមប្រឹក្សាឃុំ ។ អង្គការបានចូលមកទំនាក់ទំនង ជាមួយលោកមេឃុំ ដើម្បីធ្វើសកម្មភាពនៅក្នុងឃុំ ។ លោកមេឃុំបានស្វាគមន៍ និង ចូលរួមនៅក្នុង ការប្រជុំនានា ដែលអង្គការបានអញ្ជើញ ។ ពេលខ្លះ លោកមេឃុំចាត់តំណាងឱ្យចូលរួមប្រជុំជំនួស ។ លោក មេឃុំបានកត់ត្រារបៀបវារៈអំពីការអភិវឌ្ឍ និង ការជួយប្រជាពលរដ្ឋនៅក្នុងគំនិតរបស់គាត់ ។ នៅពេលប្រាស្រ័យទាក់ទងជាមួយអង្គការ គាត់មិនភ្លេចស្នើ សុំឱ្យអង្គការជួយប្រជាពលរដ្ឋ ឱ្យបានកាន់តែច្រើន នោះទេ។ ជាតួយ៉ាង ក្នុងឆ្នាំ២០០៧ នេះ ខណៈពេល ដែលអង្គការខ្មែរអភិវឌ្ឍន៍ខ្មែរ (ហៅកាត់ថា កាកូ) ពិភាក្សាជាមួយគាត់អំពីការជ្រើសរើសភូមិ ចំនួនបី នៅក្នុងឃុំល្វា សម្រាប់គម្រោងអនក្ខរកម្ម គាត់បាន ស្នើដោយទទូចទៅអង្គការកាកូ ឱ្យអនុវត្តគម្រោងនេះ នៅ៤ភូមិ ។ យោងតាមប្រសាសន៍របស់ប្រធានអង្គការ កាកូ លោកមេឃុំបានមានប្រសាសន៍ថា បើប្រជាជន ចេះ គាត់មានភាពងាយស្រួលដឹកនាំប្រជាជន ។

## មានគំនិត ហ៊ានសាកល្បងគម្រោងសេវាកម្ម

ឃុំល្វា គឺជាឃុំសាកល្បងដំបូងបំផុតរបស់ ខេត្តសៀមរាប ក្នុងការអនុវត្តគម្រោងសេវាកម្ម ដោយប្រើមូលនិធិឃុំ ក្នុងឆ្នាំ ២០០៧ នេះ ។ គម្រោង សេវាកម្មបានលើកឡើងជារៀងរាល់ឆ្នាំ ក្នុងអាណត្តិទី១ ប៉ុន្តែ ពុំមានការអនុវត្តទេដោយសារពុំទាន់មាននីតិវិធី សម្រាប់អនុវត្តច្បាស់លាស់ផង និង ដោយសារគ្មាន អ្នកជួយត្រួសត្រាយផង ។

ក្រោយពីមានការណែនាំ និង ជំរុញលើកទឹកចិត្តពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុមប្រឹក្សាឃុំល្វានៅតែបន្តសម្រេចចិត្ត លើកយក គម្រោងសេវាកម្មប្រភេទនេះ (ការផ្ដល់ពូជស្រូវ និង កូនឈើហូបផ្លែ) ដាក់ក្នុងកម្មវិធីវិនិយោគឃុំ ដើម្បី អនុវត្ត ក្នុងឆ្នាំ២០០៧។ ប៉ុន្តែ គម្រោងនេះពុំទទួលបាន ការគាំទ្រពីមន្ទីរជំនាញ អង្គការ និង សប្បុរសជនទេ នៅក្នុងសិក្ខាសាលា សមាហរណកម្មផែនការថ្នាក់ស្រុក។

ជាធម្មតា នៅក្រោយសិក្ខាសាលារួចហើយ គណៈកម្មាធិការកសាងផែនការ និង ថវិកា (គផថ)[៩] ត្រូវយកគម្រោង ដែលមិនបានទទួលការគាំទ្រ មកចាត់អាទិភាព ហើយកំណត់ដើម្បីដាក់បញ្ចូលក្នុង ផែនការថវិកាឃុំ។ ការដាក់បញ្ចូល នេះគឺអាស្រ័យលើ អាទិភាពគម្រោង ដែល គផថ បានចាត់អាទិភាពពី ជំហានដំបូងៗ និង លទ្ធភាពថវិកា ដែលអាច មាន ដែលឃុំសង្ឃឹមទទួលបានពីថវិកាវិភាជន៍ពីថ្នាក់ជាតិ។ តាមនីតិវិធី គផថ អាចដឹងថា ថវិការបស់ឃុំមានចំនួន ប៉ុន្មានពីថវិកាវិភាជន៍ពីថ្នាក់ជាតិ នៅពេលរាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ បានឱ្យដឹងពីលទ្ធភាពផ្ទេរ ថវិកាឃុំ សម្រាប់ឆ្នាំក្រោយ នៅកំឡុងខែ ៩ ខែ ១០ ឬ ខែ ១១។

ការពិភាក្សាគ្នាក្នុងជំហានទី៩នៃដំណើរការកម្មវិធីវិនិយោគឃុំគផថបានសម្រេចជ្រើសរើសយកគម្រោងចែកចាយ ពូជស្រូវ និង បណ្ដុះបណ្ដាល បច្ចេកទេសដំណាំស្រូវ និង ជីកំប៉ុស្ត និង គម្រោង ចែកចាយដំណាំឈើហូបផ្លែ ទៅក្នុងផែន ការថវិកាឃុំ។ តើ គផថ មានហេតុផល ឬ មានសំអាងអ្វីខ្លះ បានជា សម្រេចចិត្តដូចនេះ?

ហេតុផលសំខាន់ៗ របស់ក្រុមប្រឹក្សាឃុំល្វា ដែលបានសម្រេចចិត្តអនុវត្តគម្រោងសេវាកម្មនេះ រួម មានៈ ទី(១) គម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំល្វាមាន គ្រប់គ្រាន់ហើយ ទី(២) ក្រុមប្រឹក្សាឃុំអាចមានថវិកា គ្រប់គ្រាន់សម្រាប់ អនុវត្ត គម្រោងនេះ ដោយការបូក បញ្ចូលថវិកាអតិរេកក្នុងឆ្នាំចាស់ ទី(៣) ក្រុមប្រឹក្សា ឃុំបានសង្កេតឃើញច្បាស់ថា មានតម្រូវ ការខ្លាំងពី ប្រជាពលរដ្ឋ ទី(៤) ប្រជាជនមានដី ដែលមាន គុណភាពអំណោយផល សម្រាប់អនុវត្តគម្រោង និង ទី(៥) ក្រុមប្រឹក្សាឃុំខ្លួនឯងបានស្ទាបស្ទង់ពិនិត្យមើល ពីលទ្ធភាពអនុវត្តគម្រោង តាំងពីឆ្នាំ ២០០៦ ម្លេះ។

កត្តាជំរុញផ្សេងៗទៀត បានកើតចេញពី ការលើកទឹកចិត្ត និង ការផ្ដល់មតិរបស់អង្គភាព រដ្ឋបាលមូលដ្ឋានខេត្ត តាមរយៈអ្នកសម្របសម្រួល និង ការយល់ឃើញផ្ទាល់របស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សា ឃុំចង់បន្សល់ទុកនូវស្លាកស្នាម សមិទ្ធិផល និង ស្នាដៃ របស់ខ្លួន នៅក្នុងឃុំសម្រាប់កូនចៅជំនាន់ក្រោយ ទៀត។ ពេលគេឃើញ ឬ ហូបអង្ករ ឬ ផ្លែឈើ នោះ ប្រជាពលរដ្ឋ ព្រមទាំងកូនចៅជំនាន់ក្រោយផង អាច នឹកឃើញដល់ជំនាន់ក្រុមប្រឹក្សាឃុំល្វាអាណត្តិទី១។

---

[៩] គផថ មានតួនាទីជួយ និង ផ្ដល់យោបល់ក្រុមប្រឹក្សាឃុំ ក្នុងការកសាងផែនការ និង ថវិកាឃុំ ដែលគេធ្វើឡើងជា រៀងរាល់ឆ្នាំ។ គផថ ជាទូទៅ ដឹកនាំដោយមេឃុំ និង សមាជិកក្រុមប្រឹក្សា។ ជារឿយៗ គផថ ត្រូវបានគេនិយាយ យោងសំដៅថាជា ក្រុមប្រឹក្សាឃុំ ដែលដឹកនាំដោយប្រធាន ក្រុមប្រឹក្សាឃុំ និង ជាមេឃុំ។

ប៉ុន្តែ គួរឱ្យភ្ញាក់ផ្អើល ពេលឮលោកមេឃុំ បន្លឺ សំលេងថា "បើដឹងថា ហួសនិស្ស័យ ធំពេក មិនហ៊ាន ដាក់គម្រោងនេះទេ ។ ... ខ្ញុំស្មានថា គម្រោងនេះ គឺ ត្រឹមតែចែកពូជស្រូវដល់ប្រជាពលរដ្ឋទៅ គឺចប់ហើយ ។ ... ដល់ពេលធ្វើខ្លួនឯងបានដឹងថា ពិបាក" ។ តាម ការពិតជាក់ស្តែង ការអនុវត្តគម្រោងនេះមិនចប់ត្រឹម ការចែកពូជស្រូវទេ ។ វាត្រូវការការបំពេញបែបបទ ការធ្វើផែនការជ្រើសរើសពូជ និង កសិករស្ម័គ្រចិត្ត ការបណ្តុះបណ្តាលបច្ចេកទេស ការតាមដានត្រួតពិនិត្យ និង ការដកថវិកា សម្រាប់ចំណាយ ។

ជាធម្មតា ចំពោះគម្រោងទាំងឡាយ ដូចជា ការថែរក្សាផ្លូវលំ ការសំអាតអនាម័យក្នុងផ្សារ ឬ នៅតាមទីកន្លែងប្រជុំជន ជាដើម គឺក្រុមប្រឹក្សាឃុំ អាចដើរតួនាទីដោយផ្ទាល់បាន ដោយសាររបៀប ឬវិធីសាស្ត្រ នៅក្នុងការផ្តល់សេវាទាំងនេះមានលក្ខណៈ សាមញ្ញ ហើយសមស្របទៅនឹងសមត្ថភាពរបស់ ក្រុមប្រឹក្សាឃុំ ។

## ការកសាងផែនការជាមួយកសិករស្ម័គ្រចិត្ត

ដោយស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ គផថ បានលើកយកគម្រោងសេវាកម្មដដែល ដាក់ក្នុង ផែនការរបស់ឃុំ ។ អ្នកភូមិហាក់ដូចជាមិនធ្មើយណាយ នឹងការលើកគម្រោងដដែល ទោះបីជាគម្រោងនោះ មិនទាន់បានអនុវត្តក៏ដោយ ។ អ្នកភូមិមួយរូប បាន និយាយដោយទឹកមុខរីករាយថា "ឆ្នាំក្រោយលើក ទៀត បើមិនបាន មិនអាក់អន់ចិត្តទេ" ។

រហូតដល់ឆ្នាំ ២០០៦ ទោះបីជាគម្រោង ចែកពូជស្រូវ និង ដំណាំឈើហូបផ្លែមិនបានទទួល ការគាំទ្រនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការ ថ្នាក់ស្រុកទៀតក៏ដោយ ក៏លើកនេះក្រុមប្រឹក្សាឃុំបាន សម្រេចថា ត្រូវសាកល្បងអនុវត្តគម្រោងសេវាកម្ម នេះ ដោយប្រើថវិកាឃុំ ដែលជាថវិកាអតិរេកឃុំឆ្នាំ ចាស់ ។

នៅពេលលើកផែនការដំបូង គផថ មិនបាន គិតឱ្យបានច្បាស់ថា តើត្រូវផ្តល់ពូជស្រូវប្រភេទអ្វី ឡើយ ។ នៅពេលចូលដល់ដំណាក់កាលសិក្សាគម្រោង លម្អិត ក្រុមប្រឹក្សាឃុំបានកាត់បន្ថយទំហំគម្រោងពី ការចែកពូជស្រូវចំនួន ២.៥០០ គីឡូក្រាម ស្មើនឹង ១០.០០០.០០០រៀល មកត្រឹម ១.៤០០ គីឡូក្រាម ស្មើនឹង ៤.២០១.០០០ រៀល ។ ការកាត់បន្ថយចំនួនគីឡូក្រាមនេះ ដោយសារក្រុមប្រឹក្សាឃុំយល់ឃើញ ថាមិនគួរអនុវត្តគម្រោងធំទេ នៅក្នុងដំណាក់កាលសាកល្បង ។ ក្រុមប្រឹក្សាឃុំសុខចិត្តទុកលុយឱ្យនៅសល់ ។ មកទល់នឹងពេលបច្ចុប្បន្ននេះ ក្រុមប្រឹក្សាឃុំ មិនទាន់បានគ្រោងថា ត្រូវប្រើថវិកា ដែលនៅសល់នេះ ទៅធ្វើអ្វីនៅឡើយទេ ។ ជំហានបន្ទាប់ ក្រុមប្រឹក្សាឃុំបានស្នើឱ្យមេភូមិ ជ្រើសរើសកសិករស្ម័គ្រចិត្តនៅគ្រប់ភូមិ ដើម្បីចូលរួម ប្រជុំនៅសាលាឃុំ ។ នៅខែមិថុនា ការប្រជុំបាន ចាប់ផ្តើម ដោយពិភាក្សាអំពីការជ្រើសរើសយកពូជស្រូវ ។ ដោយមានការពន្យល់ពីមន្ត្រីបច្ចេកទេស នៃការិយាល័យកសិកម្មស្រុក និង ការបង្ហាញអំពី គម្រោងដល់កសិកររួចមក កសិករ ដែលបានចូលរួម បានសម្រេចចិត្តជ្រើសរើសយកពូជស្រូវចំនួនពីរ គឺពូជ ស្រូវសែនពិដោរ និង ពូជស្រូវរំដួល ។

មានមូលហេតុ ជាច្រើន ដែលនាំឱ្យមានការសម្រេចចិត្តដូចនេះ។ អង្ករ សែនពិដោរ និង រំដួល មានទីផ្សារលក់នៅខេត្ត សៀមរាប។ ស្រូវពូជទាំងពីរនេះ ងាយស្រួលដាំ ហើយ ប្រើរយៈពេលខ្លីអាចឱ្យផលបាន។ កសិករអាចដាំបាន នៅគ្រប់រដូវ (ពូជស្រូវរំដួល) ហើយ ផ្តល់ទិន្នផលខ្ពស់ រហូតដល់ ៦តោន ក្នុង១ហិកតា ហើយអប្បបរមា ៣តោនក្នុង ១ហិកតា។

បន្ទាប់មកទៀត ក្រុមប្រឹក្សាឃុំ ក៏បានរៀបចំការប្រជុំម្តងទៀតនៅសាលាឃុំ។ ការប្រជុំលើកនេះ គឺពិភាក្សាជាមួយកសិករស្ម័គ្រចិត្ត អំពីផែនការវគ្គបណ្តុះបណ្តាលលម្អិត សម្រាប់ ៧០ គ្រួសារ ក្នុង៧ភូមិ។ រួមជាមួយកសិករស្ម័គ្រចិត្ត ទាំង មេឃុំ មេភូមិ និង មន្ត្រីបច្ចេកទេសពិភាក្សា អំពី មុខវិជ្ជារៀន រយៈពេលសិក្សា ចំនួនវគ្គ ចំនួនសិក្ខាកាម និង ទីកន្លែងរៀន។ នៅចុងបញ្ចប់នៃការប្រជុំនេះ ពួកគេសម្រេចបាន ផែនការវគ្គបណ្តុះបណ្តាលលម្អិត។

បន្ទាប់ពីកសិករបានរៀនចប់ ក្រុមប្រឹក្សាឃុំ បានរកទិញពូជស្រូវ និង បានដឹកជញ្ជូនមកសាលាឃុំ។ ក្រោយពីបានដឹកមកសាលាឃុំ ពិធីចែកពូជស្រូវដល់ កសិករ បានធ្វើឡើង ដោយមានការចូលរួមពីមន្ត្រី សាលាខេត្តផងដែរ។

ជារួម ដំណើរការកសាងផែនការនៅឃុំល្វា មិនបានធ្វើឡើងត្រឹមតែ នៅក្នុងដំណើរការកម្មវិធីវិនិយោគឃុំប៉ុណ្ណោះទេ ប៉ុន្តែអ្នកទទួលផលថែមទាំង ត្រូវបានផ្តល់ឱកាសឱ្យចូលរួមបញ្ចេញយោបល់ និង ធ្វើសេចក្តីសម្រេចចិត្ត ទៅក្នុងដំណាក់កាលលម្អិត នៃ ការអនុវត្តគម្រោងថែមទៀតផង។

## ការអនុវត្តន៍គម្រោង

យោងតាមដីកាបញ្ជូនត្រូវឆ្លើយ របស់សាលា ខេត្ត បញ្ជូនមកប្រធានមន្ទីរកសិកម្មខេត្ត ចុះថ្ងៃទី ៥ មិថុនា ២០០៧ មួយថ្ងៃក្រោយមក ដោយផ្អែកលើ ឯកសារយោង (ទម្រង់ព័ត៌មានគម្រោងសេវាកម្ម របស់ឃុំ ផ្ញើរមកអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត) មន្ទីរកសិកម្មខេត្ត បានឆ្លើយថា មន្ទីរឯកភាព ព្រោះ គម្រោងដាំដើមឈើហូបផ្លែ និង ផ្តល់ពូជស្រូវ ដល់កសិករក្រីក្រ ពុំមានប៉ះពាល់លើផ្នែកបច្ចេកទេស និង គោលនយោបាយឡើយ។ ដូច្នេះ ក្រុមប្រឹក្សាឃុំល្វា អាចដំណើរការអនុវត្តគម្រោងនេះបាន។ ដោយសារគម្រោងសេវាកម្មរបៀបនេះ ថ្មី ហើយស្ថិតក្នុងការសាកល្បងនៅថ្នាក់ឃុំ និង ម្យ៉ាងដោយសារពុំទាន់ការណែនាំឱ្យជាក់លាក់ស៊ីជម្រៅ ដូច គ្នានឹងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ[១០] ទាំង ក្រុមប្រឹក្សាឃុំ ទាំងមន្ត្រីគាំទ្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការថ្នាក់ខេត្ត បានយកចិត្តទុកដាក់ យ៉ាងខ្លាំង ហើយ ព្យាយាមគិតគូរអំពីនីតិវិធី និង ការផលិតឯកសារនានា ដើម្បីគាំទ្រឱ្យការអនុវត្ត សាកល្បងមួយនេះទទួលបានជោគជ័យ និង ទុកជា មេរៀនបទពិសោធន៍ សម្រាប់ការអនុវត្តនៅឃុំដទៃ ទៀត ក្នុងប្រទេសកម្ពុជា។ ការលំបាក ឬ ភាពមន្ទិល ជាច្រើនបានកើតឡើងនៅជុំវិញការអនុវត្តគម្រោង សេវាកម្ម ដូចជា អំពីការទទួលខុសត្រូវជាក់លាក់ របស់ក្រុមប្រឹក្សាក្នុងការផ្តល់សេវាកម្ម ការដេញថ្លៃ ការអនុវត្តថវិកា និង ការតាមដានត្រួតពិនិត្យ។

[១០] សូមមើល សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង មូលនិធិឃុំ សង្កាត់។ សៀវភៅនេះភាគច្រើនពន្យល់អំពី ការអនុវត្តលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែក្នុងនោះ ក៏ រៀបរាប់អំពីការអនុវត្តគម្រោងសេវាកម្មដែរ។

*ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ*

ការទទួលខុសត្រូវជាក់លាក់របស់ក្រុមប្រឹក្សា ឃុំក្នុងការគ្រប់គ្រងការផ្តល់សេវាកម្មណាខ្លះ នៅមិន ទាន់មានភាពច្បាស់លាស់ទេ។ រហូតមកដល់ពេលនេះ ការពាក់ព័ន្ធរបស់ឃុំ ក្នុងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន មានត្រឹមការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដោយក្រុមប្រឹក្សាឃុំចុះកិច្ចសន្យាប្រគល់ឱ្យផ្នែក ឯកជនជាអ្នកសាងសង់ ឬ ជាអ្នកផ្តល់សេវាកម្ម។

អ្នកទទួលការភាគច្រើនមានមូលដ្ឋានស្ថិតនៅ ស្រុក ឬ ខេត្ត ហើយបានចុះបញ្ជីការនៅរដ្ឋបាលខេត្ត ដែលគឺជាអ្នកបញ្ជាក់អំពីសមត្ថភាពអនុវត្តន៏គម្រោង របស់អ្នកទទួលការ។ គេជ្រើសរើសអ្នកទទួលការ តាមរយៈដំណើរការដេញថ្លៃ។ អ្នកទទួលការ ដែល ដេញថ្លៃបាន ចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ ដែលមានតួនាទីផងដែរ ក្នុងការតាមដានត្រួតពិនិត្យ ការអនុវត្តគម្រោង។ ជាធម្មតា មន្ត្រីគាំទ្របច្ចេកទេស នៅថ្នាក់ខេត្ត ជួយក្រុមប្រឹក្សាឃុំ ក្នុងការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង និង ការគ្រប់គ្រង កិច្ចសន្យា។

ប្រសិនបើគេក្រឡេកមកមើលគម្រោងសេវាកម្មវិញជាទូទៅមន្ទីរជំនាញនានានៅជុំវិញខេត្តជាអ្នកអនុវត្តគម្រោងសេវាកម្មនៅក្នុងឃុំ តាមរយៈ មូលនិធិវិនិយោគខេត្ត។ ចំពោះគម្រោងសេវាកម្ម របស់ឃុំ ដែលប្រើកញ្ចប់ថវិការបស់ឃុំ គេកម្រឃើញ មានណាស់។ ដូច្នេះហើយ តាំងពីពេលដំបូង គេអាច នឹងគិតភ្លាមបានថា ចំពោះគម្រោងចែកពូជស្រូវ និង គម្រោងចែកកូនឈើហូបផ្លែ នេះ ក្រុមប្រឹក្សាឃុំអាច ស្នើឱ្យមន្ទីរកសិកម្មជាអ្នកទទួលការអនុវត្ត ដែលអាច ធ្វើឡើងតាមរយៈកិច្ចសន្យាទទួលការរវាងមន្ទីរ និង ក្រុមប្រឹក្សាឃុំ។ ប៉ុន្តែ ផ្ទុយទៅវិញ ការិយាល័យ កសិកម្មស្រុក ដែលស្ថិតក្នុងមូលដ្ឋាន នៅក្បែរទីតាំង អនុវត្តគម្រោងក្នុងឃុំល្វា គឺជាអ្នកទទួលការអនុវត្ត គម្រោងលើការងារបណ្តុះបណ្តាលកសិករ។ ក្រៅពីនេះ មន្ត្រីការិយាល័យកសិកម្មស្រុក ដែលដើរតួនាទីផងដែរ ជាមន្ត្រីបច្ចេកទេស ជួយផ្តល់យោបល់ និង តាមដានត្រួតពិនិត្យ ការអនុវត្តន៏គម្រោងជាមួយក្រុមប្រឹក្សា។

*ការដេញថ្លៃ*

ប្រសិនបើការផ្គត់ផ្គង់សេវាកម្ម អាចធ្វើបាន តាមរយៈការដេញថ្លៃ ហើយអាចរកបាននៅមូលដ្ឋាន ឃុំផ្ទាល់នោះគឺជាប្រការល្អណាស់។ ក៏ប៉ុន្តែ នៅក្នុង ឃុំល្វា គេបានជួបការលំបាកក្នុងការរកអ្នកផ្គត់ផ្គង់ ឬ កសិដ្ឋានណាមួយ ដែលអាចផ្គត់ផ្គង់ពូជស្រូវ និង កូន ឈើហូបផ្លែ តាមចំនួនកំណត់ ដើម្បីចែកជូនកសិករ ក្រីក្រ។ អាស្រ័យហេតុនេះ សាលាឃុំល្វាបានដាក់ លិខិតទៅសាលាខេត្ត ដើម្បីស្នើសុំលើកលែងលទ្ធកម្ម នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ ។ មួយថ្ងៃ ក្រោយមក ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំដដែល សាលាខេត្តបានចេញលិខិតមួយ ជូនក្រុមប្រឹក្សាឃុំល្វា ដោយអនុញ្ញាតតាមសំណើ ដោយគ្រាន់តែត្រូវធ្វើ កិច្ចសន្យាដោយផ្ទាល់ជាមួយ កសិករក្នុងមូលដ្ឋាន ជិតខាងឱ្យបាន

[១១] ជាធម្មតា ក្រោយពីប្រកាសផ្សព្វផ្សាយរកផ្គត់ផ្គង់ កាលណាគេនៅតែពុំអាចរកផ្គត់ផ្គង់បានចំនួនពីរលើក នោះ ក្រុមប្រឹក្សាឃុំនឹងស្នើសុំជ្រើសរើសអ្នកផ្គត់ផ្គង់ ឬ អ្នក ទទួលការទៅគណៈកម្មាធិការប្រតិបត្ត នៃគណៈកម្មាធិការ អភិវឌ្ឍន៍ជនបទខេត្ត ក្រុង។ ការស្នើសុំលើកលែងលទ្ធកម្ម គឺជាករណីពិសេសមួយនៅខេត្តសៀមរាប។

ច្បាស់លាស់ដើម្បីទុកជាឯកសារ ។ នេះ គឺជាដំណោះស្រាយមួយ ដើម្បីបញ្ចប់ភាពទាល់ច្រក ដែលនាំទៅដល់ការកកស្ទះក្នុងការអនុវត្តគម្រោង ។ ប៉ុន្តែ គេអាចមានចម្ងល់អំពីថ្លៃទិញ និង គុណភាព ទំនិញ ( ស្រូវពូជ និង កូនឈើហូបផ្លែ) ដែលទិញមក សម្រាប់ចែកជូនកសិករក្រីក្រ ។

ទាំងនៅមុនពេលដាក់សំណើ ទៅសាលាខេត្ត អំពីការលើកលែងលទ្ធកម្ម និង ក្រោយពេលទទួល បានដំណឹងអំពីការយល់ព្រមពីសាលាខេត្តក្រុមប្រឹក្សា ឃុំបានគិតគូររួចហើយអំពីថា តើត្រូវទៅទិញពូជស្រូវ នៅឯណា។ គណៈកម្មការលទ្ធកម្មឃុំបានប្រជុំពិភាក្សា ហើយបានសម្រេចថាទៅទិញនៅសហគមន៍អភិវឌ្ឍន៍កសិកម្ម ដែលជាសហគមន៍ផលិតស្រូវពូជ ស្ថិតនៅ ត្រែងញ៉ែរ ក្នុងស្រុកពួក មានចម្ងាយ ១៣ គ.ម ពី សាលាឃុំល្វា។ ដូច្នេះ ក្រុមប្រឹក្សាឃុំ ត្រូវគិតអំពីការដឹកជញ្ជូនផងដែរ ។

*ការអនុវត្តន៍ថវិកា*

មានពីរចំណុចដែលគួរឱ្យយកចិត្តទុកដាក់ ទាក់ទងនឹងថវិកានៅឃុំល្វា ។ឧទាហរណ៍ដំបូង ក្រុមប្រឹក្សាឃុំ បានគ្រោងថវិកាចំនួន ១០.០០០.០០០ រៀល សម្រាប់គម្រោងចែកស្រូវពូជ។ បន្ទាប់ពី សិក្សាគម្រោងលម្អិត គម្រោងនេះត្រូវចំណាយអស់ ៤.២០១.០០០ រៀល ។ ដូច្នេះ ថវិកាគឺនៅសល់ ៥.៧៩៩.០០០ រៀលទៀត ។ ចំពោះថវិកាដែលនៅ សល់នេះក្រុមប្រឹក្សាពុំទាន់បានគ្រោងថាគួរយកទៅ ធ្វើអ្វីទៀតទេ។ ផ្ទុយពីគម្រោងចែកពូជស្រូវ គម្រោង ចែកកូនឈើហូបផ្លែត្រូវការចំណាយថវិកាលើសពី ថវិកា ដែលបានប៉ាន់ស្មានក្នុងផែនការ ។ តម្លៃប៉ាន់ស្មាន ក្នុងផែនការមានចំនួន ៣.០០០.០០០ រៀល ហើយ តម្លៃប៉ាន់ស្មានក្រោយពីសិក្សាគម្រោងចប់ មានចំនួន ៦.៣៤២.០០០ រៀល ។ តើឃុំចាត់ចែងថវិកា ដែលលើស និង ខ្វះទាំងនេះ ដូចម្តេច?

ការគ្រោងថវិកា គឺជាចំណុចសំខាន់មួយ ។រីឯចំណុចសំខាន់មួយទៀត គឺការអនុវត្តថវិកា នៅពេល អនុវត្តគម្រោង ។ លិខិតលើកលែងលទ្ធកម្ម បាន អនុញ្ញាតឱ្យមានភាពងាយស្រួល ក្នុងការដកថវិកា ចំណាយលើការទិញស្រូវពូជ និង កូនឈើហូបផ្លែ។ ដូច្នេះ ឃុំល្វាបានចំណាយថវិកាលើផ្នែកនេះ។ ប៉ុន្តែ ខ្ទង់ចំណាយផ្សេងទៀតនៅពុំទាន់ដកបាន សម្រាប់ទូទាត់នៅឡើយ ។ ថវិកា ដែលមិនទាន់ទូទាត់សង រួមមាន ការចំណាយឧបត្ថម្ភគ្រូបណ្តុះបណ្តាល ការចំណាយលើ សម្ភារៈ ថតចម្លងឯកសារ និង ការតាមដាន ត្រួតពិនិត្យ ។

តាមការពិតទៅ ទាំងក្រុមប្រឹក្សាឃុំ និង អង្គភាពគាំទ្រឃុំបានព្យាករណ៍ថា អាចមានការលំបាក ខ្លះ នៅក្នុងពេលដំណើរការអនុវត្តន៍គម្រោង។ ដូច្នេះ ហើយបានជាទាំងអាជ្ញាធរខេត្ត និង ថ្នាក់ជាតិ រួមមាន ក្រសួងមហាផ្ទៃ ក្រសួងផែនការ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានមកទស្សនកិច្ច ជាច្រើនដង មកកាន់ សាលាឃុំដើម្បីស្វែងយល់ ក៏ដូចជាវិះរកវិធីផ្សេងៗ ដើម្បីកែលម្អការអនុវត្តគម្រោងសេវាកម្ម ដែលសព្វថ្ងៃ ពុំទាន់មានបទដ្ឋាន ឬ ការណែនាំជាក់លាក់ទាក់ទង ទៅនឹងគម្រោងសេវាកម្មឡើយ ។ ដោយសារមាន ការយកចិត្តទុកដាក់ និង អន្តរាគមន៍ពីអាជ្ញាធរខេត្ត ក្រុមប្រឹក្សាឃុំកាន់តែមានទឹកចិត្ត ហើយខិតខំអនុវត្ត គម្រោងនេះ ។

*ការតាមដានត្រួតពិនិត្យ*

តើការតាមដានត្រួតពិនិត្យ ក្នុងគម្រោង ហេដ្ឋារចនាសម្ព័ន្ធ និង គម្រោងសេវាកម្ម ដូចគ្នាឬទេ? កសិករបានរៀន អំពីបច្ចេកទេសកសិកម្មរួចហើយ ប៉ុន្តែ ចំណេះដឹងនៅមានកម្រិត ដូច្នេះ ត្រូវមានអ្នកជួយ គាំទ្រ ពិសេសលើការងារ អនុវត្តន៍ជាក់ស្តែង។ ក្រៅពី ការពិនិត្យមើលដល់ទីកន្លែងដើម្បីជួយណែនាំ គេក៏ត្រូវ ដឹងដែរថា ពូជស្រូវ ឬ កូនឈើ ដែលបានចែកជូន កសិករ ពិតជាបានឆ្លើយតបនឹងគោលបំណងគម្រោង និង តម្រូវការរបស់កសិករ។

ថ្វីត្បិតតែនេះគឺជាគម្រោងសេវាកម្ម ប៉ុន្តែ ក្រុមប្រឹក្សាឃុំល្វាបានយកចិត្តទុកដាក់លើការតាមដាន ត្រួតពិនិត្យ។ មិនត្រឹមតែក្រុមប្រឹក្សាឃុំទេ ប៉ុន្តែ ថែមទាំងអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តផង ក៏បាន តាមដានត្រួតពិនិត្យលើការងារ រីកចម្រើន ក្នុងការ អនុវត្តសេវាកម្មនេះដែរ តាមរយៈការចុះមកសាលាឃុំ ការប្រជុំជាមួយក្រុមប្រឹក្សាឃុំ និង ការចុះទៅពិនិត្យ មើលផ្ទាល់នៅវាលស្រែរបស់កសិករ។

ក្រុមប្រឹក្សាឃុំ បានចាត់ចែងឱ្យមានអ្នក ទទួលខុសត្រូវបីនាក់ដើម្បីតាមដានត្រួតពិនិត្យគម្រោង នៅ៧ភូមិ។ ជនបង្គោលទាំងបីនាក់នោះ គឺជា ជំទប់ទី១ សមាជិកក្រុមប្រឹក្សា និង មន្ត្រីការិយាល័យ កសិកម្មស្រុក។ តាំងពីការចាប់ផ្តើម នៅចុងខែ ឧសភា ឆ្នាំ ២០០៧ មកដល់ខែ វិច្ឆិការ ជនបង្គោលទាំងបី បានចុះទៅតាមភូមិ ដែលពួកគេទទួលបន្ទុក បានចំនួន ៣២ ដង។ មានភូមិបី ដែលគេបានចុះទៅពិនិត្យបាន ច្រើនជាងគេ គឺភូមិទួលរវៀង ៦ ដង បន្ទាប់មកភូមិ ស្ទឹងព្រះស្រុក ៥ដង និង ភូមិគំរូ ៥ដង។ ជាមធ្យម ការចុះតាមដាន មានចំនួន ៤ ដង ក្នុងមួយភូមិ។

## លទ្ធផលខ្លះៗចេញពីការអនុវត្តគម្រោង

ការអនុវត្តគម្រោងសេវាកម្ម ពិតជាមាន ការលំបាក ប៉ុន្តែក្រុមប្រឹក្សាឃុំមិនបានរួញរា ឬ ដកខ្លួន ថយចេញនោះទេ។ ផ្ទុយទៅវិញ ការព្យាយាមរបស់ ក្រុមប្រឹក្សាឃុំនៅតែមាន ដើម្បីរកវិធីកែលម្អតាមរយៈ សកម្មភាពតាមដានត្រួតពិនិត្យរបស់ខ្លួន ដែលបានផ្តល់ នូវព័ត៌មានសំខាន់ស្តីអំពីលទ្ធផល នៃគម្រោង។

ឆ្លងតាមរយៈការអនុវត្ត ដែលទើបបាន៧ ខែ (ឧសភា-វិច្ឆិការ ២០០៧) គោលបំណងរបស់គម្រោង ពុំអាចសម្រេចបានទាំងអស់ទេ។ ឧទាហរណ៍ គម្រោង ចែកពូជស្រូវ គឺចង់ឱ្យអ្នកភូមិទទួលបានបច្ចេកទេស ដំណាំស្រូវ ធ្វើជីកំប៉ុស្ត និង ពូជស្រូវល្អ សម្រាប់ បង្កបង្កើនផលតាមគ្រួសារ។ ប៉ុន្តែ លទ្ធផលបានបង្ហាញ ឱ្យឃើញថា គ្រួសារខ្លះមិនបានស្ទួងតាមបច្ចេកទេស ខណៈពេលដែលគ្រួសារកសិករខ្លះ នៅមានទម្លាប់ប្រើ ជីអាចម៍គោ។ មានភូមិមួយ គឺភូមិស្ទឹងព្រះស្រុក មានគ្រួសារទាំង១០ គ្រួសារ ពុំបានធ្វើជីកំប៉ុស្ត ហើយ ប្រើជីអាចម៍គោទាំង ១០ គ្រួសារ។ នៅភូមិខ្លះទៀត បានទទួលពូជស្រូវហើយ ប៉ុន្តែពុំអាចទទួលផលឱ្យបាន ច្រើន តាមបំណងប្រាថ្នាឡើយ ដោយសារមានទឹកលិច និងខូចសំណាប។ ឯគ្រួសារខ្លះទៀត ថ្វីត្បិតតែបាន ទទួលការបណ្តុះបណ្តាលការធ្វើជីកំប៉ុស្ត ប៉ុន្តែ ពុំបាន ធ្វើជីកំប៉ុស្តទេ ដោយសារខ្វះវត្ថុធាតុដើម ឬ ជីអន្លុង ជីចេញទឹក។

ជារួម លទ្ធផលគឺមិនបានសមតាមបំណង ទាំងអស់ ដែលកសិករ និង ក្រុមប្រឹក្សាឃុំចង់បានទេ។ ពេលលើកគម្រោងដំបូង គេគួរពិនិត្យផងដែរអំពី ការជន់លិចស្រែនិង ការខ្វះវត្ថុធាតុដើម សម្រាប់ធ្វើ កំប៉ុស្ត។ ក្នុងន័យនេះ គេគួរពិនិត្យមើលអំពីថាតើ គ្រួសារណា អាចមានលទ្ធភាពអនុវត្តការរៀនសូត្រ ទៅនឹងការធ្វើសែជ្រាក់ស្តែង។

របាយការណ៍ពីកសិករ ជនបង្គោល និង អ្នក ពាក់ព័ន្ធបញ្ជាក់ថា បញ្ហាដែលជួបប្រទះរួមមាន៖

- ពូជមិនសុទ្ធ ដូចជាស្រូវសែនពិដោរ សុទ្ធ ៦០% ពូជផ្ការំដួល សុទ្ធ ៨០%
- ពូជមិនសូវដុះ
- ការផ្តល់ពូជយឺតយ៉ាវហួសរដូវកាល
- នៅពេលសាបព្រួស ជួបប្រទះ ភាពរាំងស្ងួត ដល់ពេលស្រូវដុះ ទឹកជន់លិច ដល់ពេលទឹកស្រក ក្រាសីងាប់សំណាបអស់
- ការស្ទូងមិនបានតាមបច្ចេកទេស គ្រប់ៗគ្នា
- សមាជិកភាគច្រើនមិនធ្វើជីកំប៉ុស្ត

ទោះបីជាយ៉ាងណាក៏ដោយ ចំពោះគ្រួសារ កសិករ ដែលធ្វើតាមបច្ចេកទេសបានទទួលទិន្នផល ខ្ពស់។ ជាក់ស្តែង ១គុម្ពស្រូវ ដែលស្ទូងតែមួយដើម អាចបែកបាន ពី ១៥ ទៅ ២០ ដើម គឺដើមខ្ពស់ស្មើល្អ ហើយមានកួរស្រូវធំៗ។

## សន្និដ្ឋាន

ផែនការអភិវឌ្ឍន៍ឃុំ ដែលលើកឡើងហើយ លើកឡើងម្តងទៀតជារៀងរាល់ឆ្នាំ មិនបានធ្វើឱ្យ ប្រជាជននៅឃុំល្វា ខកចិត្តទេ។ ប្រជាជនមិនខកចិត្ត ហើយឥឡូវពួកគេបានទទួលនូវអ្វី ដែលក្រុមប្រឹក្សាឃុំ ភាគច្រើនកម្រផ្តល់ឱ្យ តែក្រុមប្រឹក្សាឃុំល្វាផ្តល់ឱ្យ គឺ គម្រោងសេវាកម្មចែកជូនពូជស្រូវ និង កូនឈើហូប ផ្លែ ដល់កសិករក្រីក្រ។ ការដឹកនាំនៅក្នុងឃុំមួយ ពី ៦ អាសនៈ មក៧អាសនៈ លើ៧អាសនៈ នៃអាសនៈ ក្រុមប្រឹក្សាឃុំទាំងអស់បានបង្កើតនូវស្ថាប័នមួយ ដែល ដឹកនាំដោយគណបក្សតែមួយ។ ការឈ្នះឆ្នោតនេះ មិនបានធ្វើឱ្យថយចុះប្រសិទ្ធភាពការងារក្រុមប្រឹក្សាឃុំ ល្វាទេ។ ក្រុមប្រឹក្សានេះនៅតែយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍន៍មូលដ្ឋានដោយមិនផ្តោតសំខាន់តែទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ តែថែមទាំងគម្រោងសេវាកម្មទៀតផង។ ក្រុមប្រឹក្សា ឃុំបានគិតគូរអំពីការអភិវឌ្ឍន៍ ក្នុងទស្សនៈវិស័យ វែងឆ្ងាយ ពិសេសក្នុងវិស័យអភិវឌ្ឍន៍ធនធានមនុស្ស។ ប៉ុន្តែ ក្នុងខណៈពេលនេះ គេពុំទាន់ឃើញមានតួនាទី ជាដុំកំភួនរបស់ឃុំនៅក្នុងវិស័យបណ្តុះបណ្តាលធនធាន មនុស្សនៅឡើយទេ។ ការអភិវឌ្ឍន៍ប្រកបដោយ ចិរភាព ត្រូវការសូចនាករសំខាន់ពីរយ៉ាងហោចណាស់ គឺការរីកចម្រើនសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ធនធានមនុស្ស។

**ព័ត៌មានគម្រោងសង្ខេប**

អ្នកភូមិ៧០គ្រួសារ មកពី៧ភូមិ រួមមាន៖ ភូមិ គោកស្រម៉ ព្រហូត ទួលរវៀង ស្ទឹងព្រះស្រុក គំរូ ស្នោរ និង ល្វា ទទួលបានស្រូវពូជចំនួន ១.៤០០ គីឡូក្រាម។ ក្នុងភូមិនីមួយៗ មាន១០គ្រួសារទទួលបានពូជស្រូវ ២០ គីឡូក្រាម។ គ្រួសារខ្លះយកពូជស្រូវសែនពិដោរ ហើយ គ្រួសារខ្លះទៀតយកពូជស្រូវរំដួល។គម្រោងនេះគឺជា ប្រភេទគម្រោងកសិកម្មស្ថិតក្នុងវិស័យសេដ្ឋកិច្ច។ តាមរយៈគម្រោងនេះ ក្រុមប្រឹក្សាឃុំចង់ឱ្យអ្នកភូមិ ទទួលបានបច្ចេកទេសដំណាំស្រូវការធ្វើជីកំប៉ុស្ត និង ពូជស្រូវល្អ សម្រាប់បង្កបង្កើនផលតាមគ្រួសារ។ ក្នុង ថវិកាចំនួន ៤.២០១.០០០ រៀល ក្រុមប្រឹក្សាឃុំគ្រោង ចំណាយភាគច្រើន ទៅលើការទិញពូជស្រូវ ការបណ្តុះបណ្តាល និង ការតាមដានត្រួតពិនិត្យ។

*ប្រភព៖ ទម្រង់ព័ត៌មានគម្រោងសេវាកម្ម ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧។*

# ឧបសម្ព័ន្ធៈ ឯកសារយោង

## ANNEX: REFERENCE

### ឯកសារជាភាសាខ្មែរ

Khmer Documents


- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ៈ *សៀវភៅណែនាំស្តីពីការតាមដានត្រួតពិនិត្យ និង វាយតម្លៃរបស់ ឃុំ សង្កាត់ លើការងារ អភិវឌ្ឍន៍មូលដ្ឋាន* ខែវិច្ឆិការ ឆ្នាំ ២០០៤។
- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ៈ *ការសិក្សាវាយតម្លៃបូកសរុបកំណែទម្រង់វិមជ្ឈការ នៅកម្ពុជាៈ គោលនយោបាយ និង ការអនុវត្តន៍* ភ្នំពេញ ២០០៤។
- គណៈកម្មាធិការកសាងផែនការ និង ថវិកាៈ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០០៧-២០០៩ ឃុំខ្នាពោធិ៍ ស្រុកសូត្រនិគម ខេត្តសៀមរាប ២០០៧។
- គណៈកម្មាធិការកសាងផែនការ និង ថវិកាៈ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០០៧-២០០៩ ឃុំល្វា ស្រុកពួក ខេត្តសៀមរាប ២០០៧។
- គណៈកម្មាធិការកសាងផែនការ និង ថវិកាៈ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០០៦-២០០៨ ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២០០៦។
- គណៈកម្មាធិការកសាងផែនការ និង ថវិកាៈ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០០៦-២០០៨ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ២០០៦។
- គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំល្វាៈ របាយការណ៍វាយតម្លៃផ្ទៃក្នុងលើកកិច្ចការឃុំ សង្កាត់អាណត្តិទី១ ឆ្នាំ ២០០២ - ២០០៧ ឃុំល្វា ស្រុកពួក ខេត្តសៀមរាប វិច្ឆិការ ២០០៦។
- គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំរលាប្អៀរៈ របាយការណ៍វាយតម្លៃផ្ទៃក្នុងលើកកិច្ចការឃុំ សង្កាត់អាណត្តិទី១ ឆ្នាំ ២០០២ - ២០០៧ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ២០០៦។
- គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំតាជេសៈ របាយការណ៍វាយតម្លៃផ្ទៃក្នុងលើកកិច្ចការឃុំ សង្កាត់អាណត្តិទី១ ឆ្នាំ ២០០២ - ២០០៧ ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២០០៦។
- កំណត់ហេតុការប្រជុំត្រួតពិនិត្យស្តីពីការអនុវត្តគម្រោងចែកចាយពូជស្រូវ ឃុំល្វា ស្រុកពួក ខេត្តសៀមរាប ចុះថ្ងៃទី ១៣ វិច្ឆិការ ២០០៧។
- របាយការណ៍ប្រចាំឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ២០០៧។

- របាយការណ៍ប្រចាំឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២០០៦។
- កំណត់ហេតុស្តីពីការប្រជុំបង្កើតគណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កក្កដា ២០០៧។
- ឯកសារពតិមានស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៦ សម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍មូលដ្ឋាន ឃុំតាជេស
- ឯកសារពតិមានស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៦ សម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍មូលដ្ឋាន ឃុំរលាប្អៀរ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០០១
- ប្រកាសស្តីពីតួនាទី ភារកិច្ច និង សិទ្ធិរបស់ស្មៀនឃុំ សង្កាត់
- អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- គំរោងសំណើ : អភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារក្រីក្រក្នុងសហគមន៍ ឃុំខ្នាពោធិ៍ ស្រុកសូទ្រនិគម ខេត្តសៀមរាប ២០០៥។
- សំណើគម្រោងៈ លើកស្ទួយជីវភាពសហគមន៍ ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២០០៦។
- សំណើគម្រោងៈ បង្កើនប្រាក់ចំណូលដល់គ្រួសារក្រីក្រក្នុងសហគមន៍ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ២០០៦។

## ឯកសារជាភាសាអង់គ្លេស
English Documents

- Rustin C, et all, ***The Challenges of Decentralization Design in Cambodia, Phnom Penh***, CDRI, 2004.
- Leonardo G. Romeo, Luc Spyckerelle, ***Decentralization Reforms and Commune-Level Services Delivery in Cambodia***, December 2003
- Inter-Ministrial Prakas on Commune/Sangkat Development Planning, Phnom Penh, Updated 28 January 2002
- Leny, ***The Route to Development: Experiences of Vihear Loung Commune in Development Planning and Budgeting***, Phnom Penh, The Asia Foundation, 2005
- Leny, ***"Number One Commune"***: ***Commune Development Planning and Budgeting in Tuol Ta Ek, Battambang,*** Phnom Penh, The Asia Foundation, 2005
- Carolina Gutiérrez de Taliercio, ***In Search of Public Order —From Mandate to Practice:The Case of Sra Ngae Commune in Takeo Province***, Phnom Penh, The Asia Foundation, 2005.
- Carolina Gutiérrez de Taliercio, ***Discerning Priorities: The Case of a Road Construction in Run-Ta-Ek, Siem Reap Province***, Phnom Penh, The Asia Foundation, 2005



អ្នកចូលរួមកំពុងរង់ចាំប្រជុំនៅសាលាឃុំ តាជេស



បទសម្ភាសជាមួយ ក្រុមប្រឹក្សាឃុំតាជេស គណៈកម្មាធិការកសាងផែនការ និងថវិកា អ្នកសម្របសម្រួលស្រុក នៅសាលាឃុំតាជេស




លោក ឈឹម សុភាគកំពុងអានសេចក្តីប្រកាសបិទលើក្តារព័ត៌មានសាលាឃុំ-រលាប្អៀរ



ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការកសាងផែនការនិងថវិកា ស្មៀន និង អ្នកសម្របសម្រួលស្រុក ក្នុងការពិភាក្សានៅសាលាឃុំ



អ្នកសម្របសម្រួលស្រុក (រូបទីមួយពីឆ្វេង) ទទួលបន្ទុកឃុំ រលាប្អៀរ និងមេឃុំ (រូបទីពីរពីឆ្វេង)



ជ្រូកពីររបស់ កសិករ ប៉ែន សម្ផស្ស ក្នុងភូមិត្រពាំងត្រាច




សាលាឃុំ ខ្នាពោធិ៍



បទសម្ភាសជាមួយ ជំទប់ឃុំ អ្នកសម្របសម្រួលស្រុក ស្មៀនឃុំ និង ប្រជាពលរដ្ឋ នៅសាលាឃុំ ខ្នាពោធិ៍




សាលាឃុំ ល្វា



លោក ញ៉ុក ឈួរ (រូបទីពីរពីស្តាំ) មេឃុំល្វា



ក្រុមពិភាក្សាជាមួយសមាជិកគណៈកម្មាធិការផែនការនិងថវិកា មេភូមិ និងអ្នកស្រុក



អ្នកចូលរួមបញ្ចេញមតិក្នុងក្រុមពិភាក្សា